**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការលែងលះ និងផលប៉ះពាល់

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា. **អ៊ុក សុភ័ណ្ឌា**

កញ្ញា. **ឡុង លីណា**

ណែនាំដោយ

លោកគ្រូ **នឹង ស៊ីនៀង**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការលែងលះ និងផលប៉ះពាល់

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **កញ្ញា. អ៊ុក សុភ័ណ្ឌា**

**កញ្ញា. ឡុង លីណា**

ណែនាំដោយ

លោកគ្រូ **នឹង ស៊ីនៀង**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំទាំងពីរឈ្មោះ **អ៊ុក សុភ័ណ្ឌ** និងឈ្មោះ **ឡុង លីណា** គឺជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២៤ ឆ្នាំសិក្សា២០២៣-២០២៤នៃសាកលវិទ្យាល័យភូមិនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

នាងខ្ញុំទាំងពីរសូមថ្លែងនូវកតញ្ញូធម៌ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **លោកឪពុក និង អ្នកម្តាយ** ដែលលោកទាំងពីរ បានផ្តល់កំណើតព្រមទាំងបានចិញ្ចឹមបីបាច់ថែរក្សាប្រកបដោយព្រហ្មវិហារធម៌ ថែមទាំងលះបង់កម្លាំងកាយ និងកម្លាំងចិត្តក្នុងការទំនុកបម្រុងគ្រប់បែបយ៉ាងទាំង ផ្នែកស្មារតី និងផ្នែកសម្ភារៈ ក្នុងគោលបំណងឱ្យរូបកូនក្លាយជាបញ្ញាជនមួយរូបដែលអាចជួយខ្លួនឯង គ្រួសារ និងអាចជាកម្លាំងចលកក្នុងការជួយលើកស្ទួយដល់សង្គមផងដែរ។

នាងខ្ញុំទាំងពីរសូមថ្លែងអំណរគុណដល់ **ឯកឧត្តម លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានខិតខំប្រឹងប្រែងអស់ពីសមត្ថភាព និងលទ្ធភាពក្នុងការដឹកនាំគ្រប់គ្រង និងប្រសិទ្ធភាពខ្ពស់ក្នុងការបណ្តុះបណ្តាលធនធានមនុស្សលើវិស័យច្បាប់។

នាងខ្ញុំទាំងពីរសូមថ្លែងអំណរគុណដល់លោកគ្រូ **ទឹង ស៊ីនៀង** ដែលជាលោកគ្រូណែនាំសារណា ដល់នាងខ្ញុំទាំងពីរនាក់ដោយលោកបានចំណាយពេលវេលាដ៏មានតម្លៃដើម្បីបង្ហាត់បង្ហាញអស់ពីកម្លាំងចិត្ត កម្លាំងកាយ ក្នុងការណែនាំ កែតម្រូវ ផ្តល់ជាយោបល់ និងផ្តល់ចំណេញដឹងជាច្រើនក្នុងការសរសេរសារណា មួយនេះតាំងពីដើមរហូតទទួលបានជោគជ័យ។

ចុងបញ្ចប់នាងខ្ញុំទាំងពីរ សូមប្រសិទ្ធិពរជ័យអោយជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន សុខភាព មាំមួន ជោគជ័យគ្រប់ភារកិច្ច និងសម្រេចបាននូវពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខ ពលៈ កុំបី ឃ្លាតឃ្លាឡើយ ដល់លោកអ្នកមានគុណ សាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានខិតខំបង្ហាត់បង្រៀនផ្តល់នូវដំបូន្មាន និងបទពិសោធន៍ជាច្រើនដល់រូបខ្ញុំទាំងអស់ គ្នាដើម្បីជាស្ពានក្នុងការបំភ្លឺផ្លូវជីវិត។

# អារម្ភកថា

ក្រោយពីបានទទួលបាន ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្រ្តអស់រយៈពេលបួនឆ្នាំ នៅសកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច នូវមុខវិជ្ជាជាច្រើនដែលទាក់ទងនឹងវិស័យច្បាប់នៅកម្ពុជាជាច្រើនដែលធ្វើឱ្យនាងខ្ញុំទាំងពីរបានទទួលបានចំណេះដឹងយ៉ាងទូលំទូលាយក្រោមការយកចិត្តទុកដាក់ពីសំណាក់ លោក-អ្នកគ្រូសាស្រ្តាចារ្យនានា។

ក្នុងនោះដែរ ការបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្រ្តនេះ នាងខ្ញុំទាំងពីរបានសម្រេចចិត្តយក ការសរសេរសារណាបញ្ចប់ការសិក្សាដែលមានប្រធានបទ "**ការលែងលះ និងផលប៉ះពាល់**" ។ ការជ្រើសរើសប្រធានបទនេះឡើងមកក្នុងគោលបំណងបង្ហាញពីសញ្ញាណទូទៅ និងប្រភេទនៃការលែងលះ ដែលស្ថិតក្នុងក្រមរដ្ឋប្បវេណី ព្រមទាំងផលប៉ះពាល់ពីការលែងលះនេះ និងជួយសម្រួលដល់អ្នកស្រាវជ្រាវនានា ក៏ដូចជាប្រជាពលរដ្ឋទូទៅផងដែរ ជាពិសេសនោះគឺ សិស្សនិស្សិតដែលកំពុងសិក្សាជំនាញ នីតិសាស្រ្តផ្ទាល់តែម្តង។

នាងខ្ញុំទាំងពីរនាក់សង្ឃឹមថា ការតាក់តែងសារណាមួយនេះឡើងមិនត្រឹមតែអាចចូលរួមចំណែកក្នុងការកសាងសមត្ថភាព និងអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យច្បាប់តែប៉ុណ្ណោះនោះទេ តែថែមទាំងបានចូលរួមអនុវត្តគោលនយោបាយកំណែទម្រង់ និងប្រព័ន្ធយុត្តិធម៌របស់រដ្ឋាភិបាលប្រកបដោយការផ្លាស់ប្តូរ និងប្រសិទ្ធភាពសំដៅឆ្ពោះទៅរកការចូលរួមចំណែកកសាងនីតិរដ្ឋនៅកម្ពុជាផងដែរ។

ទោះជាសារណានេះត្រូវបានចងក្រងសព្វគ្រប់យ៉ាងណាក្តីក៏អាចមានកំហុសដោយអចេតនានូវពាក្យពេចន៍ និងអក្ខរាវិរុទ្ធ។ នាងខ្ញុំទាំងពីរនាក់សូមអភ័យទោសទុកជាមុនរាល់កំហុសខុសឆ្គងដែលអាចកើតមានឡើង និងទទួលដោយក្តីសោមនស្សរីករាយនូវការរិះគន់ទាំងឡាយក្នុងន័យស្ថាបនា ដែលនាំឱ្យយើងឆ្ពោះទៅរកគោលដៅច្បាស់លាស់ និងត្រឹមត្រូវបាន។ ជាចុងក្រោយ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះសាធារណៈជនទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃស្វែងយល់ និងគាំទ្រនូវវណ្ណកម្មមួយនេះរបស់យើងខ្ញុំ។

# មាតិកា

ទំព័រ


**សេចក្តីផ្តើម** ........................................ ១

**ជំពូកទី១**

**ការលែងលះ**

**ផ្នែកទី១៖ សញ្ញាណទូទៅនៃការលែងលះ** ........................................ ៥

**១.១. និយមន័យនៃការលែងលះ** ........................................ ៥

**១.២. មូលហេតុនៃការលែងលះ** ........................................ ៦

**១.២.១. អំពើហិង្សា** ........................................ ៦

១.២.១.១. ហិង្សាលើរូបរាងកាយ ........................................ ៧

១.២.១.២. ហិង្សាលើផ្លូវចិត្ត ........................................ ៧

១.២.១.៣. ហិង្សាផ្លូវភេទ ........................................ ៧

១.២.១.៤. ហិង្សាលើផ្លូវសេដ្ឋកិច្ច ........................................ ៨

**១.២.២. ភាពក្រីក្រ** ........................................ ៨

១.២.២.១. ការសេពគប់មិត្ត ........................................ ៩

១.២.២.២. ការប្រើប្រាស់គ្រឿងញៀន ........................................ ៩

១.២.២.៣. ការសេពគ្រឿងស្រវឹង ........................................ ៩

១.២.២.៤. ការលេងល្បែងស៊ីសង ........................................ ១០

**១.២.៣. កង្វះចំណេះដឹង** ........................................ ១០

១.២.៣.១. ការមិនបានរៀនសូត្រ ........................................ ១០

១.២.៣.២. ខ្វះការអប់រំពីសង្គម ........................................ ១១

១.២.៣.៣. កង្វះព័ត៌មានអប់រំ ........................................ ១១

**១.២.៤. ភាពមិនស្មោះត្រង់** ........ ១២

១.២.៤.១. ផ្នែកសេដ្ឋកិច្ច ........ ១២

១.២.៤.២. ការផិតក្បត់ ........ ១២

**១.២.៥. ការប្រចណ្ឌ** ........ ១៣

**១.២.៦. កង្វះវិធីសាស្ត្រពិភាក្សាបញ្ហាគ្រួសារ** ........ ១៣

**១.២.៧. ការជៀតជ្រែកពីញាតិពន្ធ** ........ ១៤

**ផ្នែកទី២៖ ប្រភេទនៃការលែងលះ** ........ ១៤

**២.១. អ្នកមានសំបុត្រអាពាហ៍ពិពាហ៍** ........ ១៤

២.១.១. ករណីតាមការព្រមព្រៀង ........ ១៥

២.១.២. ករណីតាមការមិនព្រមព្រៀង ........ ១៦

**២.២. អ្នកគ្មានសំបុត្រអាពាហ៍ពិពាហ៍** ........ ១៨

២.២.១. ករណីតាមការព្រមព្រៀង ........ ១៩

២.២.២. ករណីតាមការមិនព្រមព្រៀង ........ ២០

## ជំពូកទី២

## ផលប៉ះពាល់នៃការលែងលះ

**ផ្នែកទី១៖ ផលប៉ះពាល់ក្នុងគ្រួសារ** ........ ២២

**១.១. ចំពោះកូន** ........ ២២

១.១.១. ផ្លូវចិត្ត ........ ២២

១.១.២. សុខភាព ........ ២៣

១.១.៣. ការសិក្សាអប់រំ ........ ២៤

១.១.៤. កិត្តិយស ........ ២៤

១.១.៥. ការរំលោភបំពានផ្លូវភេទ ........ ២៥

**១.២. ចំពោះប្ដី និងប្រពន្ធ**......២៥
១.២.១. ផ្លូវចិត្ត......២៥
១.២.២. សុខភាព......២៦
១.២.៣. ការងារ......២៧
១.២.៤. សេដ្ឋកិច្ច......២៧
១.២.៥. កិត្តិយស......២៨
១.២.៦. ទំនាក់ទំនងឪពុក-ម្ដាយនិងកូន......២៩
១.២.៦.១. ទំនាក់ទំនងរវាងឪពុក និងកូន......២៩
១.២.៦.២. ទំនាក់ទំនងរវាងម្ដាយ និងកូន......២៩
១.២.៧. ទំនាក់ទំនងចំពោះសាច់ញាតិពន្ធទាំងសងខាង......២៩
**ផ្នែកទី២៖ ផលប៉ះពាល់ក្នុងសង្គម**......៣០
២.១. សង្គមពោរពេញទៅដោយក្មេងកំព្រា......៣០
២.២. ស្ត្រីមេម៉ាយ និងបុរសពោះម៉ាយច្រើន......៣១
២.៣. កង្វះធនធានមនុស្ស......៣១
២.៤. ការប្រើប្រាស់គ្រឿងញៀង និងជួញដូរគ្រឿងញៀន......៣២
២.៥. ការអភិវឌ្ឍសេដ្ឋកិច្ច......៣៣
២.៦. ការបង្កើនអត្រាចំណាយរបស់សង្គម......៣៣
**សេចក្ដីសន្និដ្ឋាន**......៣៤
**អនុសាសន៍**......៣៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្ដីផ្ដើម

តាមទំនៀមទម្លាប់ប្រទេសជាច្រើនក៏ដូចជាប្រទេសកម្ពុជាមុនឈានដល់ការរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ គេតែងតែឆ្លងកាត់ពិធីកំជាប់ពាក្យ នៅក្នុងករណីជាច្រើន បើទោះបីក្រមរដ្ឋប្បវេណី មិនបានតម្រូវឱ្យមានការកំជាប់ពាក្យនៅមុនពេលមានការរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ក៏ដោយ ក៏វាត្រូវមានអានុភាពតាមផ្លូវច្បាប់នៅពេលដែលកំជាប់ពាក្យនោះត្រូវបានធ្វើឡើងនៅមុនពេលរៀបអាពាហ៍អាពាហ៍តាមផ្លូវច្បាប់។ យោងតាមមាត្រា ៩៤៤ នៃក្រមរដ្ឋប្បវេណី បានចែងថា គឺជាសេចក្ដីសន្យារវាងបុរស និងនារី ថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានាពេលអនាគត ។ មាត្រានេះចង់មានន័យថា បុរស និងនារីដែលមានបំណងរៀបអាពាហ៍ពិពាហ៍នឹងគ្នា អាចបង្ហាញឆន្ទៈដោយសេរីក្នុងការបង្កើតកំជាប់ពាក្យហើយចាំបាច់ត្រូវធ្វើពិធីកំជាប់ពាក្យតាមប្រពៃណី។ ចំណែកឯអាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាពិសេសមួយ ដែលខុសពីកិច្ចសន្យាធម្មតា។ ចំពោះកិច្ចសន្យាធម្មតាឱ្យតែសំណើ និងស្វីការត្រូវគ្នាក៏កិច្ចសន្យាត្រូវបានបង្កើតឡើងថាតើធ្វើជាលាយលក្ខណ៍អក្សរឬមិនធ្វើជាលាយលក្ខណ៍អក្សរក៏ដោយក៏ប៉ុន្តែកិច្ចសន្យាក្នុងរឿងអាពាហ៍ពិពាហ៍ត្រូវតែធ្វើឱ្យប្រិតប្រៀងបំផុត និងត្រូវគោរពតាមមាត្រា៩៥៥ នៃក្រមរដ្ឋប្បវេណី មានន័យថា កិច្ចសន្យាក្នុងរឿងអាពាហ៍ពិពាហ៍ មិនអាចធ្វើដោយផ្ទាល់មាត់បានទេ ថ្វីបើសំណើសុំរៀបអាពាហ៍ពិពាហ៍ ត្រូវគ្នាជាមួយនឹងស្វីការរៀបអាពាហ៍ពិពាហ៍មិនត្រូវបានបង្កើតឡើងឡើយ។ ហើយអាពាហ៍ពិពាហ៍នេះដែល គឺជាចំណងភ្ជាប់និស្ស័យរវាងមនុស្សពីរនាក់តាមប្រពៃណី ឬតាមផ្លូវច្បាប់ ដែលបានស្ម័គ្រចិត្តរួមរស់ជាមួយគ្នា បង្កើតជាគ្រួសារ និងបន្តជាខ្សែស្រឡាយពូជពង្សវង្សត្រកូល។ នៅក្នុងការរស់នៅ ចំណងអាពាហ៍ពិពាហ៍តែងតែមានបង្កប់នូវគោលបំណងផ្សេងៗគ្នា អាស្រ័យទៅតាមការយល់ឃើញរបស់ក្រុមមនុស្សនៅក្នុងសង្គម ដែលគោលបំណងទាំងនោះមានដូចជា ដើម្បីបំពេញនៅសេចក្ដីរីករាយត្រេកត្រអាលនៃកាមតណ្ហាបែបសភាវធម្មជាតិ ការបន្តពូជពង្សវង្សត្រកូល ការបន្តដំណើរជីវិតរស់នៅរួមសុខរួមទុក្ខជាមួយគ្នាប្រកបដោយកិត្តិយស ភាពថ្លៃថ្នូរ និងសណ្ដាប់ធ្នាប់ជាដើម។ ក៏ប៉ុន្តែ ជាយថាហេតុ មានប្ដីប្រពន្ធជាច្រើនបានប្រឈមមុខនិងទំនាស់វិបត្តិគ្រួសារ រស់នៅមិនចុះសម្រុងនិងគ្នា កើតមានអំពើហិង្សា ឬប្រព្រឹត្តសកម្មភាពមិនគប្បី និងឈានដល់ការបែកបាក់គ្រួសារក៏មាន ចំពោះការបែកបាក់គ្រួសារអាចជាដំណោះស្រាយនូវទុក្ខសោក ការឈឺចាប់ទាំងឡាយដែលកើតមាននៃអតីតគូស្នេហ៍ទាំងឡាយ ប៉ុន្តែវាក៏បានបង្កនូវផលវិបាកដល់សាមីខ្លួន គ្រួសារ និងសង្គមជាតិជាច្រើនដែរ។ ការបែកបាក់គ្រួសារអាចបង្កើតនូវបញ្ហាអវិជ្ជមាននៅក្នុងសង្គមជាពិសេសពាក់ព័ន្ធនឹងវប្បធម៌ សេដ្ឋកិច្ច និងការអភិវឌ្ឍ។

ដោយហេតុឃើញថានៅក្នុងសង្គមយើងបច្ចុប្បន្ននេះ មានបញ្ហាលែងលះកើតឡើងជាច្រើនដែលបណ្ដាលមកពីបញ្ហាផ្សេងៗដែធ្វើឱ្យសហព័ន្ធឈានទៅដល់ការបែកបាក់គ្នា ឬការលែងលះគ្នានេះ យើងទាំងពីរនាក់បានលើកយកប្រធានបទមួយមកបកស្រាយនោះគឺ **ការលែងលះ និងផលប៉ះពាល់** ដើម្បីយកមក

បកស្រាយឱ្យបានក្បោះក្បាយពីមូលហេតុនានាដែលឈានដល់ការលែងលះគ្នា ហើយនិងបញ្ហាប្រឈមផ្សេងៗពេលដែលលែងលះគ្នារួច។

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងសង្គមបច្ចុប្បន្ននេះ ចំណងអាពាហ៍ពិពាហ៍ក្នុងប្រទេសយើងនេះត្រូវបានបែកបាក់ ឬលែងលះគ្នាដោយសារមូលហេតុផ្សេងៗជាច្រើន ហើយក្នុងការបែកបាក់នេះដែលមានការបែកបាក់ដោយចំណងអាពាហ៍ពិពាហ៍ស្របទៅតាមច្បាប់ និងអាពាហ៍ពិពាហ៍មិនស្របទៅតាមច្បាប់។ ហេតុដូច្នេះហើយទើបរាជរដ្ឋាភិបាល តែងតែបង្កើតច្បាប់ដើម្បីគ្រប់គ្រងឱ្យទាន់ពេលវេលា និងជាពិសេសនោះដើម្បីការពារគូភាគីទាំងសងខាងកុំឱ្យមានការរំលោភបំពានគ្នាទៅវិញទៅមក ។ លើសពីនេះទៅទៀតរាជរដ្ឋាភិបាលយកចិត្តទុកដាក់ និងផ្តល់សិទ្ធិទីកន្លែងជាច្រើនទៀតតាមមូលដ្ឋាន ក្នុងការសម្របសម្រួលដល់គូភាគី (ប្តី/ប្រពន្ធ) មុនពេលសម្រេចចិត្តចូលទៅដោះស្រាយតាមផ្លូវតុលាការ ដើម្បីជៀសវាងកុំឱ្យមានការខាតបង់ប្រយោជន៍ធំៗជាច្រើនដល់គូភាគីបណ្តាលមកពីការលែងលះនេះ។ បើក្រឡេកមើលពីអតីតកាលយើងដឹងថាប្រព័ន្ធច្បាប់ត្រូវបានបំផ្លិចបំផ្លាញស្ទើរតែទាំងស្រុងដោយសាសង្គ្រាមស៊ីវិល តែទោះជាយ៉ាងណានេះក្តី ក៏រាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន ខិតខំប្រឹងប្រែងលើកស្ទួយវិស័យយុត្តិធម៌នេះឱ្យមានការរីកលូតលាស់ឡើងវិញផងដែរ។ ជាលិទ្ធផលកើតចេញពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ហើយថែមទាំងមានកាឧបត្ថម្ភគាំទ្រពីប្រទេសជប៉ុនជាមិត្តទៀតនោះ ជាលទ្ធផលកម្ពុជាបានអនុម័តក្រមរដ្ឋប្បវេណី កាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ និងត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០៧។

ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧នេះ មានតួនាទីសំខាន់ណាស់ ព្រោះក្រមនេះ បានកំពុងដើរតួនាទីជាមូលដ្ឋានគ្រឹះក្នុងការដោះស្រាយវិវាទផ្សេងៗក្នុងនោះក៏មានការដោះស្រាយអំពីការលែងលះផងដែរ។ ក្រៅពីក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មានច្បាប់ផ្សេងៗទៀតដែលជាច្បាប់ជំនួយ ក្នុងការដោះស្រាយករណីលែងលះរួមមានច្បាប់ស្តីពីអាពាហ៍ពីពាហ៍ និងគ្រួសារ ឆ្នាំ ១៩៨៩ ច្បាប់ស្តីពីឯកពន្ធភាពចុះថ្ងៃទី ០១ កញ្ញា ឆ្នាំ ២០០៦ និងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និង កិច្ចការពារជនរងគ្រោះចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ ២០០៦ រួមទាំងច្បាប់នានាផ្សេងៗទៀតដែលពាក់ព័ន្ធ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

បច្ចុប្បន្ននេះឃើញមានប្តីប្រពន្ធ ជាច្រើនគូមានបញ្ហាការលែងលះគ្នាបណ្តាលមកពីមូលហេតុផ្សេងៗដែលធ្វើឱ្យសង្គមមានការព្រួយបារម្ភជាខ្លាំង តែទោះជាយ៉ាងណាក្តី ក៏ពួកគេបានសម្រេចចិត្តហើយថាពួកគេនិងលែងលះគ្នាឱ្យដាច់ស្រេចទៅតាមផ្លូវតុលាការ ដើម្បីកុំឱ្យមានបញ្ហានៅថ្ងៃក្រោយ។ ការដោះស្រាយតាមផ្លូវ

តុលាការប្ដីប្រពន្ធតែងតែមានការភ័យខ្លាចទៅលើប្រព័ន្ធយុត្តិធម៌ ជាពិសេសទៅលើស្ថាប័នតុលាការ ខ្លាចស្ថាប័ននេះមានការដោះស្រាយដោយមានភាពលំអៀង មិនស្របតាមនីតិវិធីច្បាប់ គ្មានតម្លាភាព ជាហេតុធ្វើឱ្យពួកគេមានផលវិបាក ក៏ដូចជាសង្គមកាន់តែខ្លាំងឡើង។ ហេតុផលទាំងនេះក៏ដោយសារស្ថាប័នតុលាការ ធ្វើការនៅខ្វះចន្លោះ ពិសេសមន្ត្រីពាក់ព័ន្ធដែលធ្វើការនៅក្នុងករណីលែងលះនេះតែម្ដងដែលតែងតែធ្វើការខ្ជីខ្ជារ។ តើមូលហេតុចំបងធំៗអ្វីខ្លះដែលនាំឱ្យមានលែងលះ? តើការលែងលះមានផលប៉ះពាល់អ្វីខ្លះដល់ក្រុមគ្រួសារ និងសង្គមជាតិ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងក្នុងការស្រាវជ្រាវរបស់ពួកយើងទាំងពីរនាក់នេះ គឺដើម្បីសិក្សាទៅលើបុព្វហេតុចម្បងនិងបន្ទាប់បន្សំដែលបណ្ដាលឱ្យមានការបែកបាក់(លែងលះ)គ្រួសារក្នុងចំណោមប្រជាពលរដ្ឋកម្ពុជា។ លើសពីនេះទៅទៀតគោលបំណងនៃការស្រាវជ្រាវក៏បានចូលរួមចំណែកបង្កើតនូវចំណេះដឹង និងព្រមទាំងដើម្បីស្វែងយល់ឱ្យបានស៊ីជម្រៅអំពីបញ្ហាដែលបង្កឱ្យមានការលែងលះនេះកើតឡើង និងផលប៉ះពាល់។ ចំពោះការស្រាវជ្រាវនេះដែល វាធ្វើឱ្យពួកយើងទាំងពីរនាក់មានការយល់ដឹងពីមូលហេតុដែលបង្កឡើង និងផលប៉ះពាល់ ព្រមទាំងនីតិវិធីខ្លះៗថែមមួយកម្រិតទៀតផងដែរ។ មិនតែប៉ុណ្ណោះ វាក៏ជាឯកសារមួយសម្រាប់តម្កល់ទុកក្នុងសាកលវិទ្យាល័យ ដើម្បីឱ្យនិស្សិតជំនាន់ក្រោយបានធ្វើការសិក្សាជាបន្ទាប់បន្សំ។ ប៉ុន្តែគោលបំណងចំបងយើងទាំងពីរនាក់គឺសិក្សាស្រាវជ្រាវ គឺផ្ដោតសំខាន់ទៅលើការលែងលះ និងផលប៉ះពាល់ហើយគោលបំណងនៃការសិក្សានេះព្យាយាមឆ្លើយទៅនឹងសំនួរថា តើហេតុអ្វីដែលបណ្ដាលឱ្យមានការបែកបាក់គ្រួសារក្នុងចំណោមប្រជាពលរដ្ឋកម្ពុជា?

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សារបស់យើងខ្ញុំទាំងពីរនាក់ផ្ដោតសំខាន់ ទៅលើមូលហេតុ ផលប៉ះពាល់ និងរួមបញ្ចូលប្រភេទការបែកបាក់ផងដែរ។ ប៉ុន្តែនេះ យើងខ្ញុំទាំងពីរមិនបានសរសេឱ្យបានស៊ីជ្រៅខ្លាំងពីនីតិវិធីការបែកបាក់ទាំងពីរប្រភេទនោះទេពីព្រោះប្រធានបទមិនបានឱ្យពួកយើងនិយាយអំពីនីតិវិធី នៃការបែកបាក់ទាំងពីរប្រភេទនោះទេ ហេតុនេះហើយពួកយើងផ្ដោតទៅលើតែប្រធានបទតែប៉ុណ្ណោះ។ កាលដែលកំណត់អំពីដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវដែលបានរៀបរាប់ខាងលើនេះធ្វើឱ្យយើងកាន់តែមានភាពងាយស្រួលក្នុងការស្រាវជ្រាវ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវមួយនេះមានសារៈសំខាន់ណាស់សម្រាប់អ្នកសិក្សាគ្រប់មជ្ឈដ្ឋាន ក៏ដូចសម្រាប់ប្រជាពលរដ្ឋទូទៅ បានសិក្សាស្វែងយល់ឱ្យកាន់តែស៊ីជម្រៅទៅលើ បញ្ហានៃការលែងលះក៏ដូចជាផលប៉ះពាល់នៃការ

លែងលះ។ លើសពីនេះទៅទៀតបានបន្សល់ទុកនូវឯកសារសម្រាប់អ្នកស្រាវជ្រាវ ព្រមទាំងនិស្សិតទាំងឡាយដែលមានបំណងចង់សិក្សាស្វែងយល់ពីប្រធានបទមួយនេះ។

## ៦.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ក្នុងប្រធានបទនេះផងដែលនាងខ្ញុំទាំងពីរនាក់បានធ្វើការបែងចែកជា ពីរជំពូករួមមាន៖

ជំពូកទី១ និយាយអំពីការលែងលះដែលផ្តោតទៅលើមូលហេតុដែលធ្វើឱ្យមានការលែងលះនិងនិយាយអំពីប្រភេទនៃការលែងលះនៅក្នុងសង្គមបច្ចុប្បន្ននេះ។

ជំពូកទី២ និយាយអំពីផលប៉ះពាល់ក្រោយពេលការលែងលះទៅលើគ្រួសារ និងសង្គម។

# ជំពូកទី ១

# ការលេខលេះ

# ជំពូកទី១

# ការលែងលះ

## ផ្នែកទី១ សញ្ញាណទូទៅនៃការលែងលះ

យើងដឹងហើយថា ការរៀបអាពាហ៍ពិពាហ៍ពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់បុរស និងស្រ្តី ដែលដែលជាពិធីមួយរៀបចំឡើងសម្រាប់ផ្សំផ្គុំបុរស និងស្រ្តីឱ្យក្លាយជាប្តីប្រពន្ធនឹងគ្នា ដែលត្រូវធ្វើតាមលក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់និងតាមគោលការណ៍ស្មគ្រចិត្តប្តីមួយ[1]ប្រពន្ធមួយផងដែល ហើយការរៀបពិធីអាពាហ៍ពិពាហ៍នេះត្រូវបានរៀបចំទៅតាមទំនៀមទំលាប់ប្រពៃណីដែលបានបន្សល់ទុកតាំងពីជំនាន់ដើមមក ដែលត្រូវលាតត្រដាងនៅចំពោះមហាជននិងដើម្បីឱ្យអ្នកដទៃទទួលស្គាល់ដឹងលឺ និងមិនអាចចូលមកពាក់ពន្ធ័នូវជីវិតឯកជនភាពរបស់អ្នកដែលបានរៀបការរួចនោះទេពីព្រោះសម្ព័ន្ធភាពស្នេហារបស់ពួកគេត្រូវបានប្រកាសទៅសាធារណៈជនថាពួកគេបានការពេញយ័ស្តតាមបែបប្រពៃណីជាតិរបស់ខ្លួនហើយពួកគេត្រូវបានការពារពេញលេញដោយច្បាប់ដូចនេះអាជ្ញាធរមូលដ្ឋាននៅតាមភូមិ ឃុំ សង្កាត់បានទទួលស្គាល់មង្គលការរបស់ពួកគេទៅតាមផ្លូវច្បាប់។ ប៉ុន្តែក្នុងសង្គមសព្វថ្ងៃនេះចំណងអាពាហ៍ពិពាហ៍ បែរជាជួបបញ្ហាល្អក់កករ ការរស់នៅមិនចុះសម្រុងនឹងគ្នា ដោយសារហេតុផលជាច្រើនយ៉ាងដូចជា ការប្រើប្រាស់អំពើហិង្សា ការជេរប្រមាថជាដើម ការផិតក្បត់ជាដើម ដែលអាចឈានទៅរកការចែកផ្លូវគ្នាតាមរយៈការលែងលះ។ ដូច្នេះ មានតែតុលាការទេដែលអាចសម្រេចរឿងលែងលះបាន។

### ១.១. និយមន័យនៃការលែងលះ

ការលែងលះ គឺជាការផ្តាច់ចំណង[2]អាពាហ៍ពិពាហ៍របស់ប្តីប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍ពេញច្បាប់ពេលដែលអ្នកទាំងពីរកំពុងរួមរស់នៅជាមួយគ្នា។ អាស្រ័យដោយសហពន្ធ័ទាំងសងខាងព្រមព្រៀងគ្នា ឬសហព័ន្ធណាម្ខាងដោយមិនអាចនៅរួមរស់ជាមួយគ្នាឱ្យមានសុភមង្គលតទៅទៀតបានក៏ធ្វើការសំណូមពរសុំដាច់សមគ្គសង្វាស នឹងត្រូវបានតុលាការសម្រេចតាមបញ្ញត្តិច្បាប់។ អានុភាពនៃការលែងលះកើតឡើងនៅពេលសាលក្រមចូលជាស្ថាពរ ហេតុនេះនាំឱ្យផ្តាច់ទំនាក់ទំនងទាំងស្រុងតាមផ្លូវច្បាប់នៃភាពជាប្តីប្រពន្ធ លែងមានទ្រព្យរួមប្តីប្រពន្ធ និងការបែងចែកកំណត់អ្នកដែលមានសិទ្ធិអំណាចមេបាចំពោះកូនក្នុងបន្ទុក (កូនជាអនីតិជន អាយុក្រោម១៨ឆ្នាំ)។

[1] ក្រមរដ្ឋប្បវេណី, លេខ នស រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៥៩។

[2] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា១៩៨៩,មាត្រា ៣៨។

## ១.២. មូលហេតុនៃការលែងលះ

យើងដឹងហើយថាការលែងលះគ្នា គឺជាការផ្តាច់ចំណងអាពាហ៍ពិពាហ៍របស់ប្តីប្រពន្ធដែលបានរៀបការពេញច្បាប់ ឬក្នុងពេលដែលរស់នៅជាមួយគ្នា។ ប្តីប្រពន្ធអាចប្តឹងសុំលែងលះគ្នាបានកាលបើមានមូលហេតុគ្រប់គ្រាន់[3]បញ្ជាក់ថា ខ្លួនពុំអាចរួមរស់ជាមួយគ្នាតទៅទៀតបានតទៅទៀត។ នៅក្នុងក្រមរដ្ឋប្បវេណីថ្មីរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ បានកំណត់អំពីគោលការណ៍ នៃការធានាសេចក្តីថ្លៃថ្នូររបស់បុគ្គល ភាពស្មើគ្នារវាងបុរស និងស្ត្រី ឬសិទ្ធិលើទ្រព្យសម្បត្តិជាដើម។ នេះសរបញ្ជាក់ឱ្យឃើញថា ក្រមបានគោរពនូវសេរីភាព នៃឆន្ទៈរបស់បុគ្គលដែលរួមមានដូចជា ការរៀបអាពាហ៍ពិពាហ៍ ឬការលែងលះ គឺសុទ្ធសឹងតែជាការព្រមព្រៀងដែលកើតចេញពីឆន្ទៈរបស់បុគ្គលម្នាក់ៗ ដោយមិនមានការបង្ខិតបង្ខំពីភាគីណាមួយឡើយ។ ជាកាពិតណាស់ក្រមរដ្ឋប្បវេណី របស់របស់យើងបានផ្តល់សិទ្ធិសេរីភាពពេញលេញដល់បុរស និងស្ត្រីឱ្យរៀបអាពាហ៍ពិពាហ៍បានប្រសិនបើ ពួកគេមានឆន្ទៈ[4]ដូចគ្នាក្នុងការបង្កើតចំណងអាពាហ៍ពិពាហ៍មួយនេះ ប៉ុន្តែអាពាហ៍ពិពាហ៍នោះ ត្រូវតែមិនមានការបង្ខិតបង្ខំឡើយ។ នៅពេលខ្លះចំណងអាពាហ៍ពិពាហ៍របស់អ្នកទាំងពីរ នឹងមានការរកាំរកូសដែលជាហេតុនាំឱ្យមានកាបែកបាក់ ហើយការបែកបាក់ប្រេះស្រាំទាំងនោះអាចកើតឡើងដោយមូលហេតុជាច្រើនយ៉ាងដែលបង្ហាខ្លះ នាំឱ្យទំនាក់ទំនងអាពាហ៍ពិពាហ៍របស់ពួកគេត្រូវបានបញ្ចប់ដោយគ្មានសង្ឃឹម នឹងមិនអាចបដិទានវិញបានឡើយ ហើយបញ្ហានោះបណ្តាលមកពីរឿងរាវផ្សេងដែលកើតឡើងនៅក្នុងគ្រួសារក្រោយរៀបអាពាហ៍ពិពាហ៍រួចបានមួយឆ្នាំងឬពីរឆ្នាំងឡើងទៅ ដូច្នេះហើយយើងបង្ហាញពីរបញ្ហាធំៗដែលតែងតែកើតមាននៅក្នុងសង្គមសឹងតែរាល់ថ្ងៃមានដូចជា៖

### ១.២.១. អំពើហិង្សា

អំពើហិង្សា សំដៅលើការរំលោភបំពាន ឬបង្ខិតបង្ខំផ្លូវចិត្ត ផ្លូវកាយ ផ្លូវភេទ ផ្លូវសេដ្ឋកិច្ច រួមបញ្ចូលទាំងការប្រមាថមាក់ងាយ ការគំរាមគំហែង ការដាក់ឱ្យនៅឯកោដាច់ពីគេឯង និងការរំលោភបំពានផ្នែកជីភាពសេដ្ឋកិច្ចពីសំណាក់បុគ្គលម្នាក់ ឬច្រើន ដើម្បីត្រួតត្រាទៅលើបុគ្គលផ្សេងៗទៀត។ ម៉្យាងទៀតអំពើហិង្សាក្នុងក្រុមគ្រួសារ[5] សំដៅលើហិង្សាដែលកើតមាននិងអាចកើតមានទៅលើ ប្តី ឬប្រពន្ធ កូនក្នុងបន្ទុក ជនទាំងឡាយណារស់នៅក្រោមដំបូលផ្ទះ និងក្នុងបន្ទុកគ្រួសារ។ អំពើហិង្សា រួមមាន ការប៉ះពាល់ដល់ជីវិត ការប៉ះពាល់ដល់

[3] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា១៩៨៩,មាត្រា ៣៩។

[4] ក្រមរដ្ឋប្បវេណី, លេខ នស រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៥៨ ចំណុច ក។

[5] ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ,លេខ នស/រកម/១០០៥/០៣១,២៤ តុលា ២០០៥,មាត្រា ២

បូរណភាពរូបកាយ ការធ្វើទារុណកម្ម ឬ ការធ្វើអំពើឃោរឃៅ ការឈ្លានពានខាងផ្លូវភេទ។ អំពើហិង្សាក្នុងគ្រួសារអាចកើតមាននៅក្នុងសង្គមយើងបច្ចុប្បន្ននេះក្នុងរូបភាពដូចជា៖

**១.២.១.១. ហិង្សាលើរូបរាងកាយ**

អំពើហិង្សាលើរាងកាយឬអំពើហិង្សាក្នុងគ្រួសារសំដៅដល់សកម្មភាពវាយដំ ឬបង្កឱ្យមានរបួសស្នាមលើផ្នែកនានានៃរាងកាយរបស់ដៃគូ។ តាមការមើលឃើញក្នុងសង្គមបច្ចុប្បន្ន អ្នករំលោភបំពានអាចជាប្តីឬប្រពន្ធ ហើយភាគច្រើនកើតឡើងដោយ បុរសជាអ្នកប្រព្រឹត្តទៅលើស្ត្រី ដោយយល់ថាខ្លួនជាម្ចាស់កម្មសិទ្ធិនៃជនដែលរងគ្រោះនោះ គេតែងតែយល់ថាខ្លួនរៀបការតាមប្រពៃណីឬរៀបការតាមផ្លូវច្បាប់គឺមានន័យថា ដៃគូរបស់ខ្លួនជាកម្មសិទ្ធិផ្តាច់មុខរបស់ខ្លួន ហើយខ្លួនអាចធ្វើការគ្រប់គ្រងវាយប្រដៅបានតាមតែចិត្ត។

ឧទាហរណ៍៖ នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤ វេលាម៉ោង១១:៣០នាទីលោក**សាន់ សុធារុធ** ដែលជាប្តីរបស់នាង**រ៉ារី វណ្ណិច**ដែលរស់នៅភូមិព្រៃរំដួល ឃុំក្រោលគោ ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង លោកបានជេរបញ្ចោរវាយដំ ទាត់ធាក់ ចាប់បោចសក់យកទៅបោកនឹងគ្រែ ហើយនាង**រ៉ារី វណ្ណិច**ដែលជាប្រពន្ធបានរំដោះខ្លួនរួចពីក្រញាំដៃបុរសជាប្តីរត់ចុះមកក្រោមផ្ទះ ប៉ុន្តែលោកប្តីចិត្តអប្រិយបានតាមចាប់បោចសក់អូសតាមកាំជណ្តើរឡើងលើផ្ទះវិញយ៉ាងសាហាវព្រៃផ្សៃបំផុត ហើយក៏មានបុគ្គលពេទ្យម្នាក់បានមកជួយហាមឃាត់។

**១.២.១.២. ហិង្សាលើផ្លូវចិត្ត**

អំពើហិង្សាផ្លូវចិត្ត គឺជាសកម្មភាពទាំងឡាយណាធ្វើឱ្យប៉ះពាល់ដល់ផ្លូវចិត្តដែលគេមិនអាចទទួលយកបានដូចជា ការប្រើពាក្យសំដីជេរបញ្ចោរ ដៀមដាម ប្រមាថ រើសអើង បញ្ឈឺ គំរាមកំហែងដកហូតសិទ្ធិសេរីភាព ការដែលសហព័ន្ធណាម្ខាងលួចផិតក្បត់ ការដែលសហព័ន្ធណាម្ខាងលួចទៅលេងល្បែងជាដើម នេះហើយជាហិង្សាផ្លូវចិត្តដែលធ្វើឱ្យដៃគូម្ខាងមានការខូចចិត្តនិងគ្រាំគ្រាចិត្តជាខ្លាំងអាចធ្វើឱ្យភាគីម្ខាងនោះនឹងមានបញ្ហាប៉ះពាល់ដល់ផ្លូវចិត្តបាន។

**១.២.១.៣. ហិង្សាផ្លូវភេទ**

បញ្ហាហិង្សាផ្លូវភេទសំដៅដល់ការបៀតបៀន ការធ្វើឱ្យឈឺចាប់ខាងផ្លូវភេទពីដៃគូដោយពុំមានការយល់ព្រម ឬដោយទើសទាល់ពីដៃគូម្ខាង ឬជាការបង្ខិតបង្ខំដៃគូឱ្យប្រព្រឹត្តការរួមភេទដែលពួកគេមិនចង់ធ្វើ។ បញ្ហានេះក៏គ្របដណ្តប់ដល់សកម្មភាពអវិជ្ជមានដូចជាភាពប្រងើយកន្តើយចំពោះតម្រេកតណ្ហារបស់ដៃគូ តែបែរទៅប្រព្រឹត្តសេវនកិច្ចចំពោះអ្នកដទៃ ឬ ការផិតក្បត់ជាដើម។ មានករណីខ្លះ ភាគីប្តី ឬប្រពន្ធមានតម្រេកកាមខ្ពស់ដែលពិបាកទ្រាំខ្លាំងមិនអាចគ្រប់គ្រងខ្លួនបានរហូតឈានដល់មានការប្រចុយប្រចាន លបលួចមានដៃគូក្រៅ

ផិតក្បត់ មានសហាយស្មន់ ឬទៅរកសេវាផ្លូវភេទខាងក្រៅ ដូចជានៅបនស្រី ឬបារ ខារ៉ាអូខេ ឬលួចសេពសន្ថវៈជាមួយនារីណាម្នាក់ផ្សេងទៀត ម្តងម្កាល ឬជារឿយៗជាដើម ។

**ឧទាហរណ៍៖** នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣ នៅលើគណនី Facebook ដែលមានឈ្មោះថា Nhoem Sokleng ជាស្ត្រីរងគ្រោះដោយសាប្តីជាមន្ត្រីនគរបាលប្រើអំពើហិង្សា បានសរសេរបន្ថែមទៀតថា នាងខ្ញុំបានរងអំពើហិង្សាពីប្តីឈ្មោះ ជាប៊ុនថេង ចាប់តាំងតែពីកូនខ្ញុំ២ខែរហូតកូនដល់បច្ចុប្បន្ន រងសំពាធសតិអារម្មណ៍រហូតប៉ះពាល់ផ្លូវចិត្ត លេបថ្នាំរាល់ថ្ងៃ។ តាមរយៈវីដេអូមួយឃ្លីប បុរសជាប្តីជាមន្ត្រីនគរបាលនៃក្រសួងមហាផ្ទៃបានកាន់កាំភ្លើងសំឡុតបាញ់សម្លាប់ប្រពន្ធបង្ហាញពីភាពកាចសាហាវឃោរឃៅ និងរូបថតទទួលរងការធ្វើទារុណកម្មយ៉ាងព្រៃផ្សៃ ជាមួយស្លាកស្នាមហើម ជាំមុខមាត់ ជើង និងដងខ្លួនស្ទើគ្រប់កន្លែងផងដែរ។ បើតាមស្តាប់សម្លេងក្នុងខ្លីបវីដេអូប៉ុន្មាននាទីនេះ ការជជែកគ្នារវាងស្ត្រីជាប្រពន្ធ និងបុរសជាប្តី គឺបញ្ហាអាចផ្តើមចេញពីការមិនចុះសម្រុងនឹងគ្នាដោយភាគីប្តីសុំរួមដំណេក ប៉ុន្តែភាគីខាងស្ត្រីជាប្រពន្ធបដិសេធព្រោះខ្លាចប្តីមានបញ្ហាសុខភាពក៏បង្កហិង្សាប្រតាយប្រតប់ជាពិសេសបុរសជាប្តីអាងខ្លួនមានកម្លាំងខ្លាំងខ្លាប្រព្រឹត្តលើភរិយារហូតដកកាំភ្លើងមកកំរាមកំហែងទៀត ។

### ១.២.១.៤. ហិង្សាលើផ្លូវសេដ្ឋកិច្ច

អ្នកនិពន្ធប្រើប្រាស់បច្ចេកសព្ទ "ហិង្សាសេដ្ឋកិច្ចគ្រួសារ" នៅក្នុងការសិក្សាពីព្រោះតែវាគ្របដណ្តប់លើសពីកង្វះខាតថវិកាសម្រាប់ផ្គត់ផ្គង់គ្រួសារ បង់ថ្លៃឈ្នួលផ្ទះ បង់ការប្រាក់ធនាគាជាដើម។ បញ្ហានេះកើតឡើងក្នុងទិដ្ឋភាពផ្សេងទៀតទាក់ទងនឹងហិរញ្ញវត្ថុគ្រួសារដូចជា ការរារាំងមិនឱ្យដៃគូទៅធ្វើការងាររកប្រាក់កម្រៃមកផ្គត់ផ្គង់គ្រួសារ និងការមិនផ្តល់ថវិកាជាប្រចាំសម្រាប់ចំណាយលើជីវភាពគ្រួសារជាដើម ។ ស្វាមីដែលខិតខំធ្វើការនឿយហត់នៅខាងក្រៅផ្ទះ បានមើលងាយមើលថោកចំពោះភរិយារបស់ខ្លួនដែលគ្មានការងារធ្វើ ឬធ្វើតែកិច្ចការផ្ទះ ដោយឡែកស្វាមីប្រឹងប្រែងរកប្រាក់កាក់ និងប្រគល់ជូនភរិយាក្នុងការចាត់ចែងការចាយវាយក្នុងគ្រួសារ។ បញ្ហាហិង្សាសេដ្ឋកិច្ចគ្រួសារនេះ ផ្សាភ្ជាប់ទៅនឹងសំនួរខ្មែរដ៏ពេញនិយមមួយដែលបានលើកឡើងថា "ទុក្ខស្រីប្តីកាន់លុយ"។

### ១.២.២. ភាពក្រីក្រ

ភាពក្រីក្រ គឺជាស្ថានភាពមួយដែលប្រជាជនគ្មានប្រាក់ចំណូលគ្រប់គ្រាន់ដើម្បីទទួលបានកម្រិតអប្បបរមានៃសេវាសុខភាព ម្ហូបអាហារ ផ្ទះសម្បែង សម្លៀកបំពាក់ និងការអប់រំដែលជាទូទៅគេទទួលស្គាល់ថាវាជាភាពចាំបាច់ ដើម្បីធ្វើឱ្យមានកម្រិតជីវភាពរស់នៅល្អប្រសើរ។ ភាពក្រីក្រក្នុងគ្រួសារជាកត្តាមួយដែលធ្វើឱ្យគ្រួសារភាគច្រើនត្រូវបានបែកបាក់គ្នានិងលែងលះគ្នានៅក្នុងសង្គមបច្ចុប្បន្ននេះ។ ភាពក្រីក្រដែលកើតមានឡើងនៅក្នុងក្រុមគ្រួសារក្នុងសង្គមបច្ចុប្បន្ននេះដោយសារតែការលេងល្បែង ខ្វះចំណេះដឹង ខ្វះការអប់រំ ការសេពគ្រឿងស្រវឹង

ការប្រើប្រាស់គ្រឿងញៀន កាសេបគប់មិត្តភក្តិ និងការចូលក្លឹបកំសាន្តជាដើម។ ទាំងអស់នេះហើយជាកត្តាដែលបណ្តាលមានភាពក្រីក្រក្នុងគ្រួសារកើតឡើងដែលបណ្តាលឱ្យមានការលែងលះកើតឡើងសឹងតែងជារាងរាល់ថ្ងៃ។

**១.២.២.១. ការសេពគប់មិត្ត**

យើងដឹងហើយថាការសេពគប់មិត្ត គឺជារឿងសំខាន់ណាស់ សេពគប់មិត្តត្រូវ ជីវិតអ្នកមានតែភាពល្អប្រសើរតែបើសេពគប់មិត្តខុសនឹងនាំឱ្យអ្នកវិនាស។ ការសេពគប់មិត្តគឺជារឿងសំខាន់មិនអាចមើលរំលងបាន ជាពិសេសក្នុងពេលសម័យបច្ចុប្បន្ននេះ។ មនុស្សឆ្លាតវៃ គឺជាមនុស្សដែលចេះអង្កេត ចង់ចេះចង់ដឹង ជាពិសេសចេះបដិសេធនឹងមនុស្សដែលអាចជះឥទ្ធិពលមិនល្អ ហើយសេពគប់ជាប់លាប់តែជាមួយបុគ្គលដែលមានប្រាជ្ញា បុគ្គលមានចំណេះដឹង និងប្រឹងប្រែងក្នុងកិច្ចការងារត្រឹមត្រូវ។ នៅក្នុងគ្រួសារបើប្តី/ប្រពន្ធមានការសេពគប់មិត្តមិនល្អនឹងផ្តល់ផលប៉ះពាល់ចំពោះយើងនិងក្រុមគ្រួសារយើងជាខ្លាំង ព្រោះបើយើងចូលចិត្តដើរជាមួយមិត្តដែលចេះ ដើរផឹកស៊ី លេងល្បែងស៊ីសង ចូលចិត្តចូលក្លឹមកំសាន្ត និងការសេពគ្រឿងញៀនជាដើមនោះប្រាកដណាស់ យើងនឹងក្លាយជាមនុស្សដែលបែបនោះដែលជាមិនខានហើយហេតុធ្វើឱ្យក្រុមគ្រួសាររបស់យើងគ្មានសុភមង្គល ធ្លាក់ខ្លួនក្រីក្រ និងមានការឈ្លោះទាស់ទែងគ្នារហូតឈានដល់ការលែងលះគ្នា។ ដូច្នេះហើយមុននឹងរាប់អានសេពគប់នរណាម្នាក់ ត្រូវតែមើលឱ្យបានច្បាស់លាស់ វាមិនខុសអីពីការជ្រើសរើសគូជីវិតឡើយ។

**១.២.២.២. ការប្រើប្រាស់គ្រឿងញៀន**

នៅក្នុងសង្គមយើងបច្ចុប្បន្នការប្រើប្រាស់គ្រឿងញៀនគឺជាមូលហេតុធំមួយ ដែលនាំឱ្យក្នុងគ្រួសារជួបបញ្ហានូវការប្រើប្រាស់អំពើហិង្សាចំពោះអ្នកនៅក្នុងបន្ទុកគ្រួសារ ការបាត់បង់សម្ថភាពក្នុងការបំពេញការងារ បាត់បង់អាជីពការងារ ប្រាក់ចំណូលថយចុះ ការដើរចោលផ្ទះ និងការប្រើប្រាស់អំពើហិង្សាទៅលើអ្នកដ៏ទៃជាដើម បញ្ហាទាំងអស់នេះហើយដែលធ្វើឱ្យក្រុមគ្រួសារប្រឈមនិងភាពក្រីក្រកើតឡើង។

**១.២.២.៣. ការសេពគ្រឿងស្រវឹង**

ការសេពគ្រឿងស្រវឹងក៏ជាកត្តាដែលធ្វើឱ្យក្រុមគ្រួសារជួបនូវវិបត្តសេដ្ឋកិច្ចផងដែល។ ប្រសិនបើមានសហព័ន្ធណាម្ខាងចូលចិត្តផឹកនូវគ្រឿងស្រវឹងវា និងផ្តល់គុណវិបត្តិមួយចំនួនដល់សុខភាព ប៉ះពាល់ដល់ផ្លូវកាយ និងផ្លូវចិត្ត ជាពិសេសអាចធ្វើឱ្យប៉ះពាល់ដល់ខួរក្បាលបាត់បង់ការចងចាំ វង្វេងវង្វាន់អាចឈានដល់ការកើតជំងឺផ្លូវចិត្ត និងមានជំងឺប្រចាំកាយធ្ងន់ធ្ងរណាមួយ។ លើសពីនេះទៀត ការសេពសុរាបង្កបញ្ហាសព្វបែបយ៉ាងដូចជាគ្រោះថ្នាក់ចរាចរណ៍ ប្រើអំពើហិង្សាក្នុងគ្រួសារជាដើម និងបង្កើតភាពអសន្តិសុខក្នុងសង្គម។ ហេតុដូច្នេះឪពុកម្តាយដែលសេពគ្រឿងស្រវឹងច្រើនជះឥទ្ធិពលដល់ក្រុមគ្រួសារ រាប់ទាំងឪពុកម្តាយ-កូន និងការ

ប្រតិបត្តិក្នុងនាមជាឪពុកម្តាយ ដែលទាំងនេះជះឥទ្ធិពលយ៉ាងខ្លាំងទៅលើការវិវត្តក្នុងវ័យកុមារភាពរបស់កូនៗ និងបាត់បង់ប្រាក់ចំណូលក្នុងគ្រួសារជាហេតុធ្វើឱ្យមានការបែកបាក់គ្រួសារកើតមានឡើង។

#### ១.២.២.៤. ការលេងល្បែងស៊ីសង

ក្រឡេកមើលក្នុងសង្គមបច្ចុប្បន្ននេះការលេងល្បែងនៅតែមានទោះច្បាប់ហាមឃាត់ និងមានការចាត់វិធានការយ៉ាងតឹងរឹតយ៉ាងណាក៏ដោយមនុស្សដែលញៀននឹងល្បែងប្រៀបដូចមនុស្សដែលញៀននឹងបារី ស្រាអញ្ចឹងទោះបីជាមនុស្សទាំងនោះបានដឹងអំពីផលប៉ះពាល់ក៏ដោយក៏មនុស្សទាំងនោះមិនអាចផ្តាច់វាបានដែរ។ ការលេងល្បែងធ្វើឱ្យយើងវិនាសហិនហោចទ្រព្យសម្បត្តិដោយមិនដឹងខ្លួន មានការជំពាក់បំណុលគេ រត់គេចពីផ្ទះសំបែង ពីស្រុកកំណើត លក់ផ្ទះលក់ដីស្រែចំការលក់ទ្រព្យសម្បត្តិផ្សេងៗដែរមាន។ ក្នុងក្រុមគ្រួសារមួយចំនួនប្តី/ប្រពន្ធដែលញៀននឹងការលេងល្បែងដែលមិនអាចដកខ្លួនចេញបានឃើញថាក្នុងក្រុមគ្រួសារនោះគ្មានសុភមង្គលនោះទេសហព័ន្ធទាំងពីរតែងតែឈ្លោះគ្នាប្រើអំពើហិង្សាដាក់គ្នា និងធ្វើឱ្យជីវភាពក្នុងក្រុមគ្រួសារក្រលំបាកគ្មានផ្ទះគ្មានដីរស់នៅ ជំពាក់បំណុលគេកូនមិនបានរៀនសូត្រដូចគេឯងបាន។ ហេតុដូចនេះហើយទើបធ្វើឱ្យសហព័ន្ធណាម្ខាងមិនអាចទ្រាំរស់នៅជាមួយគ្នាបន្តទៅទៀតបាន។

### ១.២.៣. កង្វះចំណេះដឹង

កង្វះចំណេះដឹងជាកត្តាមួយដែលធ្វើឱ្យប្តីប្រពន្ធទាំងសងខាង ជួបនៅបញ្ហាបែកបាក់គ្នា ឬការលែងលះគ្នា។ ប្រសិនបើយើងកង្វះចំណេះដឹងយើងមិនអាចដឹងគ្រប់ជ្រុងជ្រោយនោះទេ យើងមិនបានអាន និងមិនបានចូលរួមក្នុងសង្គមប្រាកដណាស់អ្នកនឹងមិនមានព័ត៌មានច្រើន ពេលដែលអ្នកមិនមានព័ត៌មានច្រើន នោះអ្នកមិនមានគំនិតច្រើន ពេលដែលអ្នកមិនមានគំនិតច្រើននោះអ្នកនិងមិនមានយោបល់ឬប្រាជ្ញាច្រើន នៅពេលដែលអ្នកមិនមានប្រាជ្ញាច្រើន នោះអ្នកនឹងក្លាយជាមនុស្សអាត្មានិយមជ្រុលប្រកាន់មាំក្នុងទិដ្ឋិ ឆាប់ជឿដោយខ្វះការពិចារណា រហ័សវាយតម្លៃមនុស្ស និងភាពផ្សេងៗ។ បើក្រឡេកមើលសង្គមយើងបច្ចុប្បន្នឃើញថាប្តីនិង ប្រពន្ធដែលមិនមានចំណេះដឹងភាគច្រើនពួកគាត់តែងតែឈ្លោះប្រកែក ជេរប្រទេចគ្នាទៅវិញទៅមកដោយចង់យកឈ្នះគ្នារាងៗខ្លួន ដោយមិនចេះរកវិធីសាស្ត្រដោះស្រាយនិយាយលួងលោមភាគីណាម្ខាងឱ្យឈប់ខឹងឬ អត់ចេះអំណត់អត់ធន់នូវពាក្យសម្តីគ្នា និងបង្កឱ្យមានអំពើហិង្សាកើតឡើង។ បញ្ហាដែលបណ្តាលឱ្យមានកង្វះចំណេះដឹងនេះផងដែលបណ្តាលមកពី ការមិនបានរៀនសូត្រ ខ្វះព័ត៌មានអប់រំ និងខ្វះការអប់រំពីសង្គម។

#### ១.២.៣.១. មិនបានរៀនសូត្រ

ការដែលមិនបានរៀនសូត្រវាធ្វើឱ្យមនុស្សមិនមានចំណេះដឹងឬមិនមានប្រាជ្ញាក្នុងខ្លួនពិបាកក្នុងការរកការងារធ្វើ។ អ្នកដែលមិនបានរៀនសូត្រមិនអាចចេះសរសេរអក្សរ មិនចេះអានអក្សរ មិនចេះរៀបពាក្យសម្តីនិយាយឱ្យសមគួរ ឬមិនចេះនិយាយស្តីគួរសមទៅកាន់អ្នកដទៃ ធ្វើអ្វីមិនដឹងខុសមិនដឹងត្រូវ កាយវិការឆ្មើងឆ្មៃ

ប្រព្រឹត្តអំពើអាក្រក់ទៅលើអ្នកដទៃ ចេះលួច ចេះឆក់ ចេះប្លន់ គិចវេសមិនចេះទទួលកំហុសដែលខ្លួនបាន ប្រព្រឹត្ត។ នៅក្នុងក្រុមគ្រួសារបច្ចុប្បន្នឃើញមានថាប្តី/ពន្ធដែលមិនបានរៀនសូត្រពួកគាត់តែងតែប្រើពាក្យសម្តី មិនសមគួរដាក់គ្នា មានការជេរប្រទិចគ្នា និយាយពាក្យ ហែង អញដាក់គ្នា ខឹងគ្នាបន្តិចបន្តួចមិនចេះអត់ឱនឱ្យគ្នា ទៅវិញទៅមកបង្កើតទៅជារឿងធំ ពីមួយថ្ងៃទៅមួយថ្ងៃមានតែការឈ្លោះគ្នាយូរៗទៅនឹងឈានដល់ការបែកបាក់ គ្នា។

**១.២.៣.២. ខ្វះការអប់រំពីសង្គម**

តាមវចនានុក្រមសម្តេចសង្ឃរាជជួនណាតបានផ្តល់ន័យពាក្យ "អប់រំ" ថាជាការហាត់ចិត្ត បង្វិលចិត្ត ជួសជុលចំពោះវិជ្ជាឬកិរិយាមាយាទ ហ្វឹកហាត់ឱ្យស្ទាត់ជំនាញជាងមុន តែឱ្យបានល្អប្រពៃជាងមុនជាលំដាប់ ខំប្រឹងបំពេញឧបនិស្ស័យឱ្យបរិបូណ៌ខំកសាងសន្សំបុណ្យកុសលរក្សាទុកពុំឱ្យមានហ្មង មិនឱ្យមានថ្នាំងថ្នាក់ បន្ទំបារមី ព្រះបរមពោធិសត្វបានអប់រំបន្ទំបារមីអស់កាលយូរអង្វែង។ បើយោងតាមវិចនានុក្រម Cambridge Dictionary ពន្យល់ថា ដំណើរការនៃការបង្រៀន ឬកាសិក្សាជាពិសេស នៅក្នុងសាលា ឬមហាវិទ្យាល័យ ឬ ចំណេះដឹង ដែលយើងទទួលបាន។ ការអប់រំបានន័យថា ការសិក្សាដើម្បីទទួលបានចំណេះដឹង និងការយល់ដឹងកាន់តែស៊ីជម្រៅលើមុខវិជ្ជាផ្សេងៗដែលត្រូវយកមកអនុវត្តក្នុងជីវិតប្រចាំថ្ងៃ។ ការអប់រំមិនត្រូវបានកំណត់ចំពោះតែចំណេះដឹងពីសៀវភៅប៉ុណ្ណោះទេ ប៉ុន្តែវាក៏អាចទទួលបានតាមរយៈបទពិសោធន៍ជាក់ស្តែងនៅខាងក្រៅថ្នាក់រៀនផងដែរ។ ក្រៅពីនេះក៏មានការលើកឡើងបន្ថែមទៀតថា ការអប់រំ គឺកិច្ចដំណើរការអភិវឌ្ឍ ការសិក្សាឬផ្លូវចិត្ត និងអាកប្បកិរិយាមនុស្សដែលមានការអប់រំ។ ប្រសិនបើមនុស្សខ្វះការអប់រំពីសង្គមនោះនឹងធ្វើឱ្យមនុស្សមានអំពើអសីលធម៌កើតមានផ្សេងៗ ដូចជាអំពើហិង្សា ចោរកម្ម លួចឆក់ប្លន់ ចាប់រំលោភ ឃាតកម្ម ចាប់ជម្រិត និងជួបប្រទះនូវអនក្ខរជន ទុរគតជន និងភាពក្រីក្រតោកយ៉ាកជាដើម។

**១.២.៣.២. កង្វះព័ត៌មានអប់រំ**

ខ្វះព័ត៌មានអប់រំ គឺជាបញ្ហាប្រឈមមួយដែរដែលធ្វើឱ្យប្រជាពលរដ្ឋខ្វះការយល់ដឹងផ្សេងៗដែរប្រជាពលរដ្ឋមិនបានសិក្សារៀនសូត្របានគ្រប់ជ្រុងជ្រោយជាហេតុធ្វើឱ្យមានបញ្ហាប្រឈមផ្សេងៗកើតឡើងនៅក្នុងក្រុមគ្រួសារ និងប្រទេសជាតិជាដើម។ បើក្រឡេកមើលក្នុងសង្គមយើងបច្ចុប្បន្ននេះឃើញថាមានការផ្តល់ព័ត៌មានបានយ៉ាងរហ័សទាន់ចិត្តតាមប្រព័ន្ធsocial media ប៉ុន្តែព័ត៌មានភាគច្រើនមិនមែនជាព័ត៌មានអប់រំនោះទេច្រើនតែជាព័ត៌មានការជេរប្រទិចគ្នា ការនិយាយហែកកេរ្តិ៍គ្នា ការដេញវាយកាប់គ្នា និងការផ្សព្វផ្សាយពាណិជ្ជកម្មមិនល្អដូចជាការផ្សព្វផ្សាយស្រាបៀរ ជាដើមដែលធ្វើឱ្យយុវជនយុវនារីគ្រប់រូបត្រូវខូចអនាគត និងធ្វើឱ្យប្រទេសជាតិគ្មានការអភិវឌ្ឍជឿនលឿន។ ចំពោះនៅក្នុងក្រុមគ្រួសារដែលមិនបានទទួលបានការអប់រំតាំងតែពីកុមារភាពឬការទទួលបានការអប់រំតិចតួចវាជាកត្តាប្រឈមរួចទៅហើយ ហើយប្រសិនបើពួកគាត់ខ្វះព័ត៌មាន

អប់រំទៀតនោះពួកគាត់នឹងប្រឈមកាន់តែខ្លាំងក្នុងការរស់នៅក្នុងគ្រួសារដូចដែលយើងបាននិយាយពីបញ្ហានៃកង្វះចំណេះខាងលើរួចមក ។ ដូច្នេះហើយមន្ត្រីគ្រប់ពាក់ព័ន្ធត្រូវផ្សព្វផ្សាយព័ត៌មានអប់រំឱ្យបានច្រើនដើម្បីឱ្យប្រជាពលរដ្ឋទាំងអស់ទទួលបានចំណេះដឹងបន្ថែមធ្វើឱ្យពួកគាត់បង្កើននូវសុភមង្គលនៅក្នុងក្រុមគ្រួសារ និងនៅក្នុងសង្គមមានសុខសន្តិភាព។

### ១.២.៤. ភាពមិនស្មោះត្រង់

ភាពមិនស្មោះត្រង់ជាកត្តាមួយដែរ ដែលធ្វើឱ្យសហព័ន្ធមិនអាចរួមរស់ជាមួយគ្នាបន្តទៀតបាន។ ភាពមិនស្មោះត្រង់សំដៅទៅលើការលួចលាក់ ធ្វើទង្វើផ្សេងៗដែលមិនគប្បី ដែលមិនឱ្យសហព័ន្ធណាម្ខាងបានដឹង។ ប្ដី និងប្រពន្ធត្រូវតែមានភាពស្មោះត្រង់និងគ្នាទៅវិញទៅមកទើបមានសុភមង្គលក្នុងក្រុមគ្រួសារ។ ប្រសិនបើក្រុមគ្រួសារមួយមិនមានភាពស្មោះត្រង់នឹងគ្នានោះទេវានិងមានភាពរកាំរកូសក្នុងគ្រួសារធ្វើឱ្យក្នុងគ្រួសារគ្មានសុភមង្គលមានតែការឈ្លោះទាស់ទែងគ្នាពីមួយថ្ងៃទៅមួយថ្ងៃនិងឈានដល់ការលែងលះគ្នាធ្វើឱ្យកូនព្រាត់ពីម្ដាយឬព្រាត់ពីឪពុក ព្រាត់ពីបងប្អូន និងព្រាត់ពីយាយតាជាដើម។

#### ១.២.៤.១. ការលួចលាក់ផ្នែកសេដ្ឋកិច្ច

ការលួចលាក់ផ្នែសេដ្ឋកិច្ច គឺជាការលួចលាក់លុយដែលមិនឱ្យសហព័ន្ធណាម្ខាងបានដឹងដោយយកលុយនោះនៅប្រើប្រាស់ផ្សេងៗដូចជាការលួចទិញរបស់របរសម្រាប់ខ្លួនឯង លួចលាក់ឱ្យស្រីខាងក្រៅ លួចលាក់ឱ្យឪពុកម្ដាយ បងប្អូនជាដើម។ បញ្ហាទាំងអស់នេះជាបញ្ហាមិនមិនស្មោះត្រង់ផ្នែកសេដ្ឋកិច្ចដែលធ្វើឱ្យសហព័ន្ធណាម្ខាងមិនអាចរួមរស់ជាមួយគ្នាបាននឹងឈានដល់ការសុំលែងលះគ្នា។

#### ១.២.៤.២. ការផិតក្បត់

ប្រទេសជប៉ុនបានឱ្យនិយមន័យ អំពើផិតក្បត់ គឺជាការមានចំណងផ្លូវភេទនឹងបុគ្គលផ្សេងៗ ក្រៅពីសហព័ន្ធ។ និយមន័យនៃយុត្តិសាស្ត្រប្រទេសជប៉ុននេះ គឺមានន័យដូចនិយមន័យនៃច្បាប់ស្ដីពីឯកពន្ធភាព នៅប្រទេសកម្ពុជាដែរ "អំពើផិតក្បត់" គឺជាការរួមសូវនៈកិច្ចរវាងបុរសដែលមានចំណងអាពាហ៍ពិពាហ៍មុនមិនទាន់រលាយ ជាមួយស្ត្រីដទៃក្រៅពីប្រពន្ធរបស់ខ្លួន ឬការរួមសវនៈកិច្ចរវាងស្ត្រី ដែលមានចំណងអាពាហ៍ពិពាហ៍មុនមិនទាន់រលាយជាមួយបុរសដទៃក្រៅពីប្ដីប្រពន្ធរបស់ខ្លួន។[6] ដូច្នេះហើយការផិតក្បត់នេះវាជាភាពមិនស្មោះត្រង់ទៅលើសហព័ន្ធណាម្ខាងផងដែរដែលសហព័ន្ធនោះខំប្រឹងលាក់បាំងទៅលួចមានចំណងមេត្រីភាពនៅខាងក្រៅដែលខ្លួនមិនទាន់បានផ្ដាច់នៅចំណងអាពាហ៍ពិពាហ៍មុន។

[6] ច្បាប់ស្ដីពីឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ២៩ តុលា ២០០៦, មាត្រា៧។

**ឧទាហរណ៍៖** បុរសម្នាក់ធ្វើការជំនួញជួញដូរ ដោយដឹកអីវ៉ាន់ពីប្រទេសថៃមកកម្ពុជា ដោយរវល់តែឡើងចុះជាមួយមុខរបរ ស្រាប់តែនាងជាប្រពន្ធលួចបង្កាត់ភ្លើងស្នេហ៍ជាមួយបុរសផ្សេងទៀតគ្រាប្តីមិននៅផ្ទះអស់រយៈពេល៤ខែ។ ខាងប្តីតាមដានរាល់សកម្មភាពទង្វើផិតក្បត់របស់ប្រពន្ធដឹងរឿងទាំងប្រពន្ធលួចរៀបការ សែនព្រេនស្ងាត់ៗជាមួយប្រុសស្នេហ៍ដោយទ្រាំងលែងបាននូវទង្វើ បុកចាក់ដោតទម្លុះបេះដូងទើបនៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៨ នៅវេលាម៉ោង៧យប់ ប្តីតាមទាន់ប្រុសស្នេហ៍កំពុងនៅក្នុងផ្ទះរបស់ខ្លួន លេខ៣៦សេ២០ ផ្លូវបេតុង ភូមិនត្រពាំងក្រសាំង១ សង្កាត់ត្រពាំងក្រសាំង ខណ្ឌពោធិ៍សែនជ័យ ហើយក៏បានស្រែកឆោឡោប្រកែកសម្តីមួយប្រាវផ្អើលអ្នកភូមិ សមត្ថកិច្ចចុះទៅអន្តរាគមន៍ ហៅនាំភាគីទាំងបីនាក់ទៅសាកសួរនៅប៉ុស្តិ៍។

### ១.២.៥. ការប្រចណ្ឌ

ការប្រចណ្ឌគឺ ជាចំណុចដែលបណ្តាលឱ្យមានប្រតិកម្មធំធេងបំផុតដែលឈានទៅរកការលែងលះក្នុងចំណោមគូជីវិតជាច្រើន ពីព្រោះការស៊ូទ្រាំរស់នៅក្នុងភាពលំបាកផ្លូវចិត្តគ្មានអ្វីឡើយ ។ កាប្រចណ្ឌ គឺជាការដែលមិនឱ្យតម្លៃលើដៃគូស្នេហាដោយភ័យខ្លាចដៃគូផិតក្បត់ទៅមានក្រៅ ដែលបញ្ហានេះបានធ្វើឱ្យដៃគូម្ខាងទៀតតែងតែរងនូវសម្ពាធផ្លូវចិត្ត ពិបាកទ្រាំក្នុងការទប់ទល់នឹងកំហឹង ឬការព្រួយបារម្ភរបស់ខ្លួន។ ការប្រចណ្ឌនេះ បានក្លាយទៅជាមូលហេតុចម្បងដែលចូលរួមដល់ការបែកបាក់គ្រួសារ។

**ឧទាហរណ៍៖** បុរសម្នាក់ឈ្មោះ សុខ ខេងមានអាយុ ៤០ឆ្នាំដែលជាប្តីរបស់ជនរងគ្រោះឈ្មោះ អុល សំអុនមានអាយុ ៣៩ឆ្នាំជាកម្មការិនីរោងចក្ររស់នៅភូមិក្រាំងតាចរ ឃុំរុងរឿង ស្រុកថ្ពង ត្រូវបុរសជាប្តីកាប់នឹងពូថៅព្រមទាំងអារកសម្លាប់នៅក្នុងផ្ទះ។ សមត្ថកិច្ចបានឱ្យដឹងថា មុនពេលកើតហេតុ បុរសជាប្តីបានផឹកស្រាក្លែមសាច់ឆ្កែ លុះស្រវឹងធ្លាក់ភ្នែកកើតគំនិតប្រចណ្ឌប្រពន្ធជាមួយអ្នកដទៃ បានធ្វើសកម្មភាពយកពូថៅកាប់លើប្រពន្ធកំពុងតែដេកលង់លក់លើផ្ទះ និងអារកផ្តាច់ជីវិត។បន្ទាប់ពីប្រហាប្រពន្ធរួចជនល្មើសបានរត់ចូលក្នុងព្រៃហើយកម្លាំងសមត្ថកិច្ចបានឡោមព័ទ្ធព្រៃ និងរុករកប៉ុន្តែឃាតករប្រហែលភ័យក្លាចសមត្ថកិច្ចចាប់ខ្លួន ក៏សម្រេចចិត្តបញ្ចប់ជីវិតដោយចងកសម្លាប់ខ្លួនតែម្តង។

### ១.២.៦. កង្វះវិធីសាស្ត្រពិភាក្សាបញ្ហាគ្រួសារ

កត្តាកង្វះវិធីសាស្ត្រពិភាក្សាបញ្ហាគ្រួសារសំដៅដល់ភាពរកាំរកូសនៃទំនាក់ទំនងគ្រួសារដែលបង្កមកពីការមិនពេញចិត្តពីដៃគូម្ខាងទៀត ការពុំព្រមទទួលយកហេតុផល យោបល់ អាកប្បកិរិយា ឥរិយាបថ ឬអ្វីៗដែលដៃគូខ្លួនមាន។ ទិដ្ឋភាពនេះក៏សំដៅដល់ការប្រកាន់លើគំនិតរៀងខ្លួន ការមិនស្តាប់គំនិតដៃគូពេលពិភាក្សា ឬដោះស្រាយបញ្ហាក្នុងគ្រួសារជាដើម។ ក្រោយរៀបអាពាហ៍ពិពាហ៍រួច គ្រួសារខ្លះមានការឈ្លោះប្រកែកគ្នាជាញឹកញាប់ ដែលធ្វើឱ្យដៃគូពិបាកគោរពគ្នាទៅវិញទៅមកបំផុត។ ប្តីនិងប្រពន្ធខ្លះ មិនចុះសម្រុងគ្នាអាស្រ័យដោយបញ្ហាជាច្រើនដូចជា ការទុកដាក់និងចាយវាយប្រាក់កាស ការមិនឯកភាពគ្នាលើទីកន្លែងរស់នៅ និង បញ្ហាជា

ច្រើនទៀត។ កាលពីមិនទាន់រៀបការ ម្ខាងៗមិនសូវហ៊ានបញ្ចេញចរិត ទស្សនៈ គំនិតពិតរបស់ខ្លួនដល់ដៃគូររបស់ខ្លួនទាំងស្រុងឡើយ ដោយម្នាក់ៗតែងតែបង្ហាញនូវកាយវិការទន់ភ្លន់ ភាពមានសុជីវធម៌ និងមិនហ៊ានប្រកែកជំទាស់នឹងដៃគូរបស់ខ្លួននោះឡើយ។ ប៉ុន្តែក្រោយពីរៀបការរួច ភាគីនីមួយៗ រមែងបញ្ចេញនូវសារជាតិពិតរបស់ខ្លួន ជួនកាលបង្ខំឱ្យដៃគូ ទទួលយកនូវអ្វីៗដែលខ្លួនបានសម្តែងឬមាន ដោយពុំបានពន្យល់ហេតុផលគ្រប់គ្រាន់ក៏មាន។ កត្តាកង្វះខាតនូវវិធីសាស្ត្រក្នុងការពិភាក្សា ពន្យល់ហេតុផលឱ្យភាគីម្ខាងយល់ស្របឬសម្របសម្រួលគ្នារបៀបនេះ បានក្លាយជាបញ្ហាចម្បងមួយដែលឈានដល់ការលែងលះ ឬបែកបាក់គ្រួសារ។[7]

### ១.២.៧. ការជ្រៀតជ្រែកពីញាតិពន្ធ

ក្នុងការរស់នៅ បើទោះបីជារៀបការរួច ក៏ឪពុកម្តាយនិងបងប្អូនតែងតែនៅខ្វល់ខ្វាយ គិតគូពីសេចក្តីសុខទុក្ខការរីកចម្រើន និងវិនាសរបស់សាច់ឈាមខ្លួនជានិច្ច ផ្ទុយទៅវិញ ក៏កើតមានផងដែលនូវករណីសាច់ញាតិជ្រៀតជ្រែកហួសប្រមាណដល់ជីវិតគ្រួសារប្តីប្រពន្ធ។ ក្នុងសង្គមខ្មែរគេច្រើនពោលថា ប្តី ឬប្រពន្ធអាចរកបាន ប៉ុន្តែឪពុកម្តាយ និងបងប្អូន មិនអាចរកបានទេ។ អ្វីដែលកាន់តែពិបាកទ្រាំនោះគឺពាក្យសំដីម្តាយក្មេក និងសាច់ថ្លៃនិយាយឆ្កឹះឆ្កៀលរឿងអំពីអ្វីដែលយើង មិនបានប្រព្រឹត្តប្រាប់ទៅកាន់ញាតិមិត្តជិតឆ្ងាយ។ ប្តី ឬប្រពន្ធខ្លះមិនសូវអើពើអំពីធុរៈក្នុងគ្រួសារខ្លួន ប៉ុន្តែបែរជាគិតគូរដោះស្រាយតែរឿងសាច់ញាតិរបស់ខ្លួនមិនចេះចប់មិនចេះហើយឱ្យតែមានការទទូចនិងហៅរក។[8]

## ផ្នែកទី២៖ ប្រភេទនៃការលែងលះ

ច្បាប់ស្តីអំពីអាពាហ៍ពិពាហ៍និងគ្រួសារ ប្រទេសកម្ពុជាចែងថា ប្តីឬប្រពន្ធអាចប្តឹងសុំលែងលះបាន ប្រសិនបើមានមូលហេតុដែលធ្វើឱ្យពិបាកនិងបន្តការរស់នៅជាមួយគ្នាជាប្តីប្រពន្ធទៅទៀតបាន។ ចំពោះការលែងលះនៅក្នុងសង្គមបច្ចុប្បន្ននេះមានពីរបែបគឺ **មានសំបុត្រអាពាហ៍ពិពាហ៍ និងគ្មានសំបុត្រអាពាហ៍ពិពាហ៍។**

### ២.១. អ្នកមានសំបុត្រអាពាហ៍ពិពាហ៍

យ៉ាងណាក៏ដោយ ដើម្បីរំលាយចំណងអាពាហ៍ពិពាហ៍មួយដែលបានកើតឡើង ក៏ត្រូវអាស្រ័យទៅលើលក្ខខណ្ឌច្បាប់ដែលកំណត់តម្រូវផងដែរ។ ស្ថានភាពនេះហើយដែលធ្វើឱ្យមានចំណងអាពាហ៍ពិពាហ៍គូភាគីត្រូវបានបញ្ចប់។ សហព័ន្ធដែលមិនអាចរួមរស់នៅជាមួយគ្នាបន្តទៅទៀតបានដោយសារតែនៅក្នុងគ្រួសារមានភាពរកាំរកូស មានកើតនូវអំពើហិង្សា មានការផិតក្បត់គ្នា ឬក៏កើតមានទំនាស់ផ្សេងៗ ឬក៏បង្កឱ្យមានការជះឥទ្ធិពលអវិជ្ជមានជាច្រើនទៅលើភាគីផ្ទាល់កូន ឬញាតិជាដើម ដែលធ្វើឱ្យសហព័ន្ធណាម្ខាងមិនអាចទ្រាំតស៊ូរួមរស់

[7] កាលិកបត្រស្រាវជ្រាវមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម, លេខទី២, ច្បាប់លេខ២, ខែធ្នូ២០២៣,ទំព័រ៤២-៤៥។

[8] កាលិកបត្រស្រាវជ្រាវមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម, លេខទី២, ច្បាប់លេខ២, ខែធ្នូ២០២៣,ទំព័រ៤២-៤៥។

ជាមួយគ្នាបន្តទៀតបាន ។ ហេតុដូច្នេះ ហើយសហព័ន្ធណាម្ខាងដែលទទួលបានការវាយប្រហាផ្សេងៗដែលមិនអាចទ្រាំនូវទង្វើនោះបាន សហព័ន្ធនោះអាចដាក់ពាក្យសុំលែងលះបាន។ សហព័ន្ធដែលធ្វើការដាក់ពាក្យបណ្ដឹងត្រូវធ្វើឡើងដោយជាលាយលក្ខណ៍អក្សរដោយត្រូវរៀបរាប់អំពីមូលហេតុដែលសហព័ន្ធសុំលែងលះគ្នាហើយត្រូវចុះហត្ថលេខាដោយសហព័ន្ធដែលជាអ្នកប្ដឹង។ សហពន្ធ័ដែលជាអ្នកប្ដឹងហៅថាភាគីដើមបណ្ដឹង ឬ សហពន្ធ័ដែលទទួលរងការបណ្ដឹងហៅថាចុងចម្លើយ ចំពោះការសរសេរពាក្យបណ្ដឹងលែងលះត្រូវសរសេររៀបរាប់ចំណុចដូចដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី និងសរសេរពីមូលហេតុឱ្យបានច្បាស់លាស់។

ការលែងលះគ្នាត្រូវបានគេចាត់ទុកជាសាលក្រម ឬសាលដីការរបស់តុលាការដែលប្រកាសថា ចំណងអាពាហ៍ដែលបានគោរពទៅតាមផ្លូវច្បាប់ត្រូវបានបញ្ចប់ ជាហេតុធ្វើឱ្យសហព័ន្ធទាំងពីរលែងមានចំណងអាពាហ៍ពិពាហ៍ជាមួយគ្នាទៅទៀតបាន។ សាលក្រម ឬសាលដីកា ជាសេចក្ដីសម្រេចរបស់តុលាការ ដែលធ្វើការពិចារណាទៅលើភស្តុតាងដែលជាប់ពាក់ព័ន្ធ និងបញ្ហាតុលាការត្រូវសម្រេចក្នុងរឿងវិវាទនៃអាពាហ៍ពិពាហ៍។ ការលែងលះដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍នេះដែរមានពីរករណីដូចគ្នាទៅនឹងការមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ផងដែរគឺ **ករណីតាមការព្រមព្រៀង និងករណីតាមការមិនព្រមព្រៀង។**

### ២.២.១. ករណីតាមការព្រមព្រៀង

ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារមាត្រា៤០ នៃប្រទេសកម្ពុជាអនុញ្ញាតឱ្យមានកាលែងលះដោយការព្រមព្រៀង ដោយបញ្ញត្តិថា ប្ដីប្រពន្ធអាចលែងលះគ្នាបានដោយស្ម័គ្រចិត្តបាន។ ការលែងលះដោយការព្រមព្រៀងនេះ ភាគីនៃអាពាហ៍ពិពាហ៍អាចដាក់ពាក្យបណ្ដឹងលែងលះទៅតុលាការបាន ក្នុងទម្រង់ជាពាក្យសុំលែងលះទៅកាន់តុលាការមានសមត្ថកិច្ច ហើយត្រូវបានធ្វើឡើងក្នុងករណីដែលប្ដីប្រពន្ធទាំងពីរបានឯកភាពគ្នាក្នុងការលែងលះ និងបានព្រមព្រៀងគ្នាលើចំណុចមួយចំនួនទាក់ទងនឹងសិទ្ធិ និងករណីកិច្ចផ្សេងៗ ដែលកើតឡើងក្នុងអំឡុងពេលអានុភាពអាពាហ៍ពិពាហ៍។ បើភាគីទាំងពីរអស់និស្ស័យ និងគ្នាឬមិនអាចរស់នៅជាមួយគ្នាបានទៀត គេមិនអាចបង្ខំមនុស្សដែលមិនចង់រស់នៅជាមួយគ្នាឱ្យរស់នៅជាមួយគ្នាបានទេ ច្បាប់គោរពនូវការសម្រេចចិត្តរបស់ភាគីទាំងពីរក្នុងការព្រមព្រៀងលែងលះគ្នា។ ប៉ុន្តែការព្រមព្រៀងនេះមិនត្រូវមានការបង្ខិតបង្ខំពីភាគីណាម្ខាងពីការគំរាមគំហែង ឬតតិយជនឡើយ[៩]។ ដូច្នេះហើយភាគីទាំងសងខាង អាចឯកភាពគ្នាដោយស្ម័គ្រចិត្តក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍ហើយដាក់ពាក្យសុំលែងលះ ដោយភ្ជាប់នូវកិច្ចព្រមព្រៀងលែងលះដោយស្ម័គ្រចិត្តទៅកាន់សាលាដំបូងរាជធានី/ខេត្ត។ បញ្ញត្តិ មាត្រា ៩៧៩ អនុញ្ញាតអោយភាគីអាចដាក់ពាក្យបណ្ដឹងលែងលះទៅតុលាការបាន ហើយបើតុលាការ រកឃើញថា ភាគី មានឆន្ទៈព្រមព្រៀងគ្នាពិតប្រាកដ ក្នុងការ

[៩]សៀវភៅគ្រួសារ និងអាពាហ៍ពិពាហ៍ [ទំព័រ ៩០]

រំលោយចំណងអាពាហ៍ពិពាហ៍ តុលាការ ត្រូវតែសម្រេចឱ្យភាគីលែងលះគ្នាតាមដីការសម្រេចលែងលះ (មាត្រា ៣-២ នៃច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនបណ្តឹង)។ ការលែងលះនាំឱ្យមានការផ្លាស់ប្តូរជាខ្លាំងនូវទំនាក់ទំនងបុគ្គល ដូចនេះទោះមានការព្រមព្រៀងគ្នា រវាងភាគីក្នុងការលែងលះ ភាគីមិនអាចបង្កើតកិច្ចសន្យាលែងលះក្រៅផ្លូវតុលាការឬគ្រាន់តែប្រើវិធីដាក់លិខិត ជូនដំណឹងទៅសាលាឃុំ សង្កាត់បានទេ ចាំបាច់ត្រូវតែ មានសេចក្តីសម្រេចរបស់តុលាការ ទើបការលែងលះមានអានុភាពតាមផ្លូវច្បាប់[10]។ ក្រុមប្រឹក្សា ឃុំសង្កាត់គឺជាអ្នកដើរតួនាទីបឋមក្នុងការផ្សះផ្សារ ការបញ្ចុះបញ្ចូលធ្វើយ៉ាងណាឱ្យគូភាគីសះជាហ្នឹងគ្នាតែបណ្តោះ។ ហេតុនេះដើម្បីចេញដីការសម្រេចក្តី តុលាការពុំចាំបាច់ឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ឡើយ ពីព្រោះរឿងក្តីនេះជាប្រភេទរឿងក្តីដែលមិនមានភាពស្មុគស្មាញ និងគ្មានចំណុចវិវាទដោយហេតុថាភាគីបានព្រមព្រៀងគ្នារួចរាល់ក្នុងកាលែងលះ។

### ២.២.២. ករណីតាមការមិនព្រមព្រៀង

ការលែងលះដោយមិនមានការព្រមព្រៀង ឬការលែងលះតាមបណ្តឹងទាមទារ គឺជាការលែងលះដោយពុំមានការព្រមព្រៀងទាំងសងខាង មានន័យថាសហព័ន្ធណាម្ខាងមានការទាមទារលែងលះ ហើយចំពោះសហព័ន្ធម្ខាងទៀតមិនមានឆន្ទៈក្នុងការលែងលះ។

នៅពេលដែលប្តីប្រពន្ធមិនអាចរស់នៅចុះសម្រុងនិងគ្នា ឬក៏មានការប្រើប្រាស់អំពើហិង្សាណាមួយទៅលើហព័ន្ធណាម្ខាង ប្តី ឬប្រពន្ធអាចដាក់ពាក្យសុំលែងលះនៅក្រុមប្រឹក្សាឃុំ សង្កាត់នៃលំនៅឋានរបស់ខ្លួនបានដើម្បីដោះស្រាយ។ ក្រោយពេលដែលក្រុមប្រឹក្សា ឃុំ សង្កាត់ ទទួលពាក្យបណ្តឹងជាផ្លូវការដែលភាគីទាមទារការលែងលះ នោះក្រុមប្រឹក្សា ឃុំសង្កាត់ នឹងត្រូវមាននីតិវិធីផ្សះផ្សារ ឬបញ្ចុះបញ្ចូលឱ្យគូភាគីសះជាគ្នាក្នុងកំឡុងពេល១៥ (ដប់ប្រាំ)ថ្ងៃ[11] ប្រសិនបើក្រុមប្រឹក្សាឃុំ សង្កាត់ពុំអាចផ្សះផ្សារ ឬបញ្ចុះបញ្ចូលឱ្យសះជាគ្នាពុំបាននោះទេ ត្រូវចាត់ទុកថាមានពាក្យបណ្តឹងលែងលះគ្នាកើតឡើង ហើយក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបញ្ជូនពាក្យបណ្តឹងនោះទៅតុលាការជាបន្ទាន់។ ចំពោះការដាក់ពាក្យបណ្តឹងលែងលះទៅតុលាការនេះដែលត្រូវធ្វើឡើងស្របតាមមាត្រា៧៥នៃក្រមនីតិវិធីរដ្ឋប្បវេណីដោយរួមបញ្ចូលនូវចំណុចដូចជា ១.ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះនិងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ២.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និង អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ[12]។ នៅក្នុងពាក្យ

[10] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី (ភាគទី៥ គន្លឹទី៧) ២០១០,មាត្រា៩៧៩។

[11]ក្រមរដ្ឋប្បវេណី, លេខ នស រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨២។

[12]ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧៥។

បណ្ដឹង ដើមចោទគប្បីសរសេរបញ្ជាក់ឱ្យច្បាស់លាស់នូវអង្គហេតុ ដែលជាមូលហេតុនៃការទាមទារ និងតាមចំណុចដែលត្រូវសរសេរបញ្ជាក់ភស្តុតាង គប្បីសរសេរបញ្ជាក់នូវអង្គហេតុសំខាន់ៗក្នុងចំណោមអង្គហេតុទាំងមូលដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងភស្តុតាង ហើយពាក្យបណ្ដឹងលែងលះនេះដែលត្រូវសរសេរអំពីមធ្យោបាយទប់ទាល់និងការពារខ្លួនផងដែរ។

ចំពោះនៅពេលដែរតុលាការទទួលបានពាក្យបណ្ដឹង តុលាការត្រូវចាត់តាំងចៅក្រមមួយរូបដើម្បីធ្វើការផ្សះផ្សាម្ដងទៀត។ ការផ្សះផ្សានេះដែលគឺមិនមែនផ្សះផ្សារដើម្បីឱ្យភាគីសះជាគ្នាដោយការលះបង់ការទាមទារ ឬទទួលស្គាល់ការទាមទារនោះទេ គឺផ្សះផ្សារដើម្បីឱ្យមានការដកពាក្យបណ្ដឹងលែងលះវិញ ហើយរួមរស់នៅជាប្ដីប្រពន្ធវិញ។ ទោះបីសហព័ន្ធម្ខាង ទាមទារលែងលះគ្នាខ្លាំងយ៉ាងណាក៏ដោយ តុលាការអាចនឹងធ្វើការផ្សះផ្សាដោយឆន្ទានុសិទ្ធិ។ពិសេសក្នុងករណីពិនិត្យឃើញថា ប្ដីប្រពន្ធមានកូនជាអនីតិជន ឬក្នុងករណីប្ដីប្រពន្ធម្ខាងទៀតជួបប្រទះការលំបាកផ្នែកសេដ្ឋកិច្ច។ ចំពោះការផ្សះផ្សារនេះដែរ ក្នុងក្រមរដ្ឋប្បវេណីមិនបានចែងលំអិតអំពីនីតិវិធីដែកត្រូវផ្សះផ្សាដោយតុលាការទេ ប៉ុន្តែ មាននៅក្នុងច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ មានការចែងលម្អិតអំពី នីតិវិធីដែលត្រូវផ្សះផ្សាដោយតុលាការ។ ហេតុដូច្នេះហើយ ប្រសិនបើភាគីនៅតែមិនត្រូវរ៉ូវគ្នាចំពោះការផ្សះផ្សារនេះទេ តុលាការនិងធ្វើការវិនិច្ឆ័យ ហើយធ្វើការប្រកាសសាលក្រម[13] ថាពួកគេមិនមានចំណងអាពាហ៍ពិពាហ៍ទៀតទេ។

ក្នុងករណីប្ដីប្រពន្ធមានកូន ហើយពុំអាចសម្រេច ឬពិភាក្សាគ្នាបានទេ ច្បាប់បានធ្វើការផ្ដល់អំណាចឆន្ទានុសិទ្ធិទៅតុលាការ ដើម្បីកំណត់អ្នកមានអំណាចមេបាក្នុងការអប់រំថែរក្សាដោយគិតដល់ផលប្រយោជន៍របស់កូនមានន័យថា បើតុលាការស៊ើបអង្កេតឃើញថាសហព័ន្ធម្ខាងមាន ជីវភាពធូរធារដែលមានលិទ្ធភាពក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនបានល្អដោយមិនឱ្យខូចខាតប្រយោជន៍កូន នោះតុលាការមានឆន្ទានុសិទ្ធិ[14]ក្នុងការប្រគល់កូនឱ្យទៅសហព័ន្ធនោះថែរក្សា។ ក្នុងកំឡុងពេលនៃនីតិវិធីលែងលះគ្នា ចៅក្រមអាចចេញវិធានការកំណត់ថាតើឪពុក ឬម្ដាយដែលត្រូវថែរក្សាកូនជាបណ្ដោះអាសន្ន (ចំពោះករណីកូនមិនទាន់ដឹងក្ដី)។ កូនដែលទើបធំដឹងក្ដីតុលាការនិងឱ្យកូនជាអ្នកសម្រេចចិត្តដោយខ្លួនឯងថាចង់នៅជាមួយម្ដាយ ឬនៅជាមួយឪពុក។ ប្រសិនបើកូនថាចង់នៅជាមួយឪពុក ឬម្ដាយនោះតុលាការមានសិទ្ធិសម្រេចតាមការសម្រេចរបស់កូន។ អំណាចមេបាមានសិទ្ធិ និងករណីកិច្ច ត្រូវបីបាច់រក្សារូបកាយរបស់កូនដែលជាអនីតិជន និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ។ ក្នុងករណីនេះទោះម្បីចំណងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ក៏ដោយ ក៏ប៉ុន្តែចំណង

[13]ក្រមរដ្ឋប្បវេណី, លេខ នស រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៨៤ កថាខណ្ឌទី២។

[14]ក្រមរដ្ឋប្បវេណី, លេខ នស រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០៣៧ កថាខណ្ឌទី៣។

ឪពុកម្ដាយជាមួយកូនមិនអាចកាត់ផ្ដាច់បានឡើយ សហព័ន្ធដែលមើលថែរក្សាកូន ត្រូវតែផ្ដល់លទ្ធភាពឱ្យទៅភាគីម្ខាងទៀតបានមកសួរសុខទុកកូនមានគ្រប់ពេលវេលា ដោយមិនឱ្យមានភាពស្មុគស្មាញ ឬ រារាំងដល់សហពន្ធ័ម្ខាងទៀតមិនឱ្យប្រាស្រ័យទាក់ទងជាមួយកូនឡើយ និងមានករណីកិច្ចទទូលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន។សិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន[15] គឺ ជាសិទ្ធិដែលត្រូវផ្ដល់ឱ្យឪពុក ឬម្ដាយដែលពុំមានអំណាចមេបា ក្រោយការលែងលះ អាចធ្វើទំនាក់ទំនង ឬតាមដានស្ថានភាពរស់នៅរបស់កូន ដែលត្រូវបានធានាជាអប្បបរមា ក្នុងន័យមនោសញ្ចេតនា និងក្ដីស្រលាញ់របស់ឪពុកម្ដាយចំពោះកូន ក្នុងទម្រង់មួយដែលមានលក្ខណៈសមស្របតាមការព្រមព្រៀងរបស់ឪពុកម្ដាយ ឬតាមការកំណត់របស់តុលាការ។ ប្រសិនបើការចូលជួមកូនពុំបានសម្រេច តុលាការត្រូវកំណត់អំពីរបៀបចូលជួបប្រាស្រ័យទាក់ទង និងសោហ៊ុយដែលចាំបាច់ដែលត្រូវទទូលបន្ទុក ដើម្បីថែរក្សាកូនតាមការទាមទាររបស់ឪពុកម្ដាយ។

ក្នុងករណីមួយទៀតបើប្ដីប្រពន្ធមិនមានការព្រមព្រៀងលើការបែងចែកទ្រព្យសម្បត្តិ តុលាការនឹងធ្វើការបែងចែកទៅតាមច្បាប់កំណត់ការបែងចែកទៅលើកិច្ចសន្យាអំពីទ្រព្យសម្បត្តិ នៅមុនឬក្រោយអាពាហ៍ពិពាហ៍ ប្រសិនបើប្ដីប្រពន្ធមិនបានធ្វើកិច្ចសន្យាពិសេសចំពោះទ្រព្យសម្បត្តិនោះទេតុលាការ និងធ្វើការបែងចែកទៅតាមក្រមរដ្ឋប្បវេណីមាត្រ៩៧២(ទ្រព្យសម្បត្តិដោយឡែក)បន្ថែមពីលើទ្រព្យសម្បត្តិដោយឡែកនីមួយៗមានសិទ្ធិទទូលយកមួយភាគពីរ(១/២)នៃទ្រព្យសម្បត្តិរួម។ ប៉ុន្តែបើមានករណីពិសេសនឹងមានការទាមទាររបស់ប្ដីប្រពន្ធណាម្ខាងតុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួមទៅលើស្ថានភាពផ្សេងៗដូចជាទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬការបង្កើនទ្រព្យអំឡុងពេលអាពាហ៍ពិពាហ៍កម្រិតជីភាពរស់នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្ត និងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយ និងផលប្រយោជន៍របស់កូនជាអាទិ៍[16]។ ចំពោះគេហកិច្ចត្រូវចាត់ទុកថាមានតំលៃស្មើនឹងការងារដែលធ្វើក្រៅផ្ទះដែរ។ដូច្នេះហើយដើម្បីឱ្យសាលក្រម អាចយកទៅអនុវត្តបាន តុលាការត្រូវកំណត់វិធីបែងចែកទ្រព្យឱ្យបានច្បាស់លាស់នៅក្នុងសេចក្ដីសម្រេច ដូចជា ការបែងចែកវត្ថុជាក់ស្ដែង ការបែងចែកជាតម្លៃថ្នូរ និងការបែងចែកដោយផ្ទូរជាប្រាក់។

## ២.២. អ្នកគ្មានសំបុត្រអាពាហ៍ពិពាហ៍

នៅក្នុងប្រទេសយើងនេះឃើញមាននៅតាមទីជនបទភាគច្រើនប្រជាជននៅទីនោះច្រើនតែប្រារព្ធពិធីរៀបអាពាហ៍ពិពាហ៍តាមទំនៀមទម្លាប់ប្រពៃណី ប៉ុន្តែពួកគាត់មិនមានការទៅចុះសំបុត្រពាហ៍ពិពាហ៍នៅតាម

---

[15]ក្រមរដ្ឋប្បវេណី, លេខ នស រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០៤០។

[16] សេចក្ដីពន្យល់អំពីក្រមរដ្ឋប្បវេណី (ភាគ៦) ២០១២។

ច្បាប់កំណត់នោះទេ។ នៅក្នុងច្បាប់ចែងថា អាពាហ៍ពិពាហ៍ នឹងមានអានុភាព ដោយការដាក់[17] ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ នឹងការចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។ នៅពេលដែលនីតិវិធីខាងលើត្រូវបានបំពេញរួចរាល់ មន្ត្រីអត្រានុកូលដ្ឋាននឹង ចេញសំបុត្រអាពាហ៍ពិពាហ៍ជូនអ្នកដាក់ពាក្យសុំ។ ការរួមរស់នៅជាមួយគ្នាដោយមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ គេហៅថា អនីតិសង្វាស។ បើលមើលពីរូបភាពខាងក្រៅមើលពីទំនាក់ទំនង វាពុំមានលក្ខណៈខុសគ្នាពីការរួមរស់នៅជាមួយគ្នាជាប្ដីប្រពន្ធស្របច្បាប់ទេនោះគ្រាន់តែការរួមរស់នៅជាមួយគ្នាមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ ។ ប៉ុន្តែវាអាចឱ្យប្ដីប្រពន្ធនោះបាត់បង់នូវសិទ្ធិ ឬផលប្រយោជន៍ដូចប្ដីប្រពន្ធដែលច្បាប់ទទួលស្គាល់។ ផលវិបាកតាមផ្លូវច្បាប់ដែលកើតឡើងដោយសារមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ ប្រឈមទៅនឹងការបាត់បង់ ឬត្រូវបានរំលាយគ្រប់ពេលវេលាដោយមិនបានឆ្លងកាត់តាមផ្លូវតុលាការ នេះហៅថាទំនាក់ទំនងបង្កើតឡើងដោយសេរីហើយអាចរំលាយទៅវិញដោយសេរី ចំណូលដែលប្ដីប្រពន្ធទទួលបានក្នុងកំឡុងពេលរួមរស់ជាមួយគ្នា គឺមិនមែនជាទ្រព្យសម្បត្តិរួមឡើយ វាជាទ្រព្យសម្បត្តិដោយឡែករៀងៗខ្លួន (អ្នកដែលរកបានជាម្ចាស់នៃផលប្រយោជន៍នោះ) ប្ដីប្រពន្ធដែលពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ស្របច្បាប់មិនអាចក្លាយជាទាយាទក្នុងការស្នងមរត៌ក នៅពេលដែលភាគីម្ខាងទៀតទទួលមរណភាពឡើយ ប្ដីប្រពន្ធមិនអាចតាក់តែង និងចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធដែលច្បាប់ទទួលស្គាល់ ដែលមានខ្លឹមសារកំណត់អំពីទ្រព្យរួម និងដោយឡែក ឱ្យមានភាពច្បាស់លាស់ស្របទៅតាមឆន្ទៈរបស់ប្ដីប្រពន្ធឡើយ ប្ដីប្រពន្ធមិនមានករណីកិច្ចរួមរស់ជីវភាពជាមួយគ្នាឡើយ បានន័យថាប្ដីនឹងប្រពន្ធមិនមានចំណងតាមផ្លូវច្បាប់ ដែលតម្រូវឱ្យរួមរស់នៅតែជាមួយគ្នារហូតនោះទេ ប្រសិនបើប្ដីប្រពន្ធរួមសេវនកិច្ចជាមួយអ្នកដទៃ ក្រៅពីប្ដី ឬប្រពន្ធរបស់ខ្លួន ប្ដី ឬប្រពន្ធនោះមិនត្រូវបានចាត់ទុកថាបានប្រព្រឹត្តបទផិត ប្ដីប្រពន្ធដែលមានកូនសិទ្ធិក្នុងការគ្រប់គ្រងគឺជាអំណាចមេបា ជាគោលការក្នុងច្បាប់ម្ដាយជាអ្នកមានអំណាចមេបា[18]ដែលត្រូវចិញ្ចឹមបីបាច់កូន ប៉ុន្តែឪពុកម្ដាយអាចពិភាក្សាថាឪពុកក៏អាចធ្វើអាណាព្យាបាលកូនបានដែរ ។ល។ ក្នុងករណីលែងលះនេះដែលមានពីរករណីគឺ **ករណីតាមការព្រមព្រៀង និងករណីតាមការមិនព្រមព្រៀង។**

### ២.២.១. ករណីតាមការព្រមព្រៀង

ដើម្បីរំលាយចំណងអាពាហ៍ពិពាហ៍មួយដែលមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ប៉ុន្តែមានការស្នើសុំរៀបអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអាត្រានុកូលដ្ឋានឃុំ សង្កាត់សាមី ដែលខ្លួនរស់នៅ និងការរៀប

---

[17]ក្រមរដ្ឋប្បវេណី, លេខ នស រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៥៥ ។

[18]ក្រមរដ្ឋប្បវេណី, លេខ នស រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៨៧។

អាពាហ៍ពិពាហ៍ទៅតាមប្រពៃណីទំនៀមទំលាប់តាំងពីបុរាណកាលមកក្នុងករណីនេះ ភាគីជាប្តីប្រពន្ធអាចសុំធ្វើការលែងលះគ្នាបាននៅ ក្រុមប្រឹក្សាឃុំសង្កាត់ ខាងលំនៅឋាន ឬទីសំណាក់ដែលខ្លួនរស់នៅ គ្រាន់តែភាគីទាំងសងខាងដឹកដៃគ្នាទៅក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាទីសុំណាក់ដែលខ្លួនរស់នៅដោយមិនចាំបាច់ភ្ជាប់នៅឯកសារផ្សេងៗទៅជាមួយ ហើយភាគីទាំងសងខាងធ្វើការស្នើរសុំឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើលិខិតបញ្ជាក់ការលែងលះដោយមានការផ្តិតមេដៃដើម្បីឱ្យក្រុមប្រឹក្សាឃុំ សង្កាត់បានដឹងលឺតែប៉ុណ្ណោះ។ ហើយការលែងលះនេះដែរទោះមិនមានសំបុត្រអាពាហ៍ពិពាហ៍គូភាគីទាំងសងខាងអាចប្រាប់ពីមូលហេតុដែលមិនអាចរស់នៅជាមួយគ្នាបានបន្តទៅទៀតបានដោយប្រការណាមួយ ដែលក្រុមប្រឹក្សាឃុំ សង្កាត់ គិតថាវាមិនសមទំនងក្រុមប្រឹក្សាអាចធ្វើការផ្សះផ្សារពួកគាត់ផងដែរ។ ប៉ុន្តែនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ មិនបានចែងអំពីនីតិវិធីសម្រាប់ ការលែងលះគ្នាសម្រាប់ការរៀបអាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវតាម លក្ខណច្បាប់ទេ។ ហេតុនេះហើយប្រសិនបើមានការលែងលះហើយប្តឹងទៅតុលាការ នោះតុលាការមិនអាចទទួលពាក្យបណ្តឹងនោះទេ គេនិងឱ្យគូភាគីដោះស្រាយដោយខ្លួនឯង ពីព្រោះច្បាប់មិនមានចែងអំពីដំណោះស្រាយទៅលើអ្នកដែលមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍នោះទេ តែទោះយ៉ាងណាក៏ដោយក្នុងករណីនេះគូភាគីអាចធ្វើការសុំលែងលះនៅក្រុមប្រឹក្សាឃុំសង្កាត់បានដូចដែលបានរៀបរាប់ខាងលើ។

### ២.២.២. ករណីតាមការមិនព្រមព្រៀង

ក្នុងករណីមិនព្រមព្រៀងនេះដែរបើគូភាគីណាម្ខាងធ្វើការសុំលែងលះ តែភាគីម្ខាងទៀតមិនយល់ព្រម ក៏ការលែងលះនេះក៏ប្រព្រឹត្តទៅបានផងដែរព្រោះថានៅក្នុងច្បាប់គេមិនទទួលស្គាល់ការរៀបពាហ៍ពិពាហ៍ដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ស្របទៅតាមច្បាប់ជាអាពាហ៍ពិពាហ៍ពេញលក្ខណៈនោះទេ។ ការមានឈ្មោះជាប្តីប្រពន្ធដែលស្របទៅតាមច្បាប់កំណត់គឺជាការដែលបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍ទៅតាមច្បាប់កំណត់ទោះម្បីជា សហព័ន្ធនោះមិនបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីក៏ដោយ។ ក្នុងករណីដែលគូភាគីជាអនីតិសង្វាសហើយមានកូន ករណីនេះប្រសិនបើឪពុកចង់ក្លាយជាអាណាព្យាបាលរបស់កូន នោះនៅក្នុងច្បាប់តម្រូវឱ្យឪពុកមានការពិភាក្សាជាមួយម្តាយរបស់កូន។ ប្រសិនបើម្តាយរបស់កូនមិនយល់ព្រមឱ្យឪពុកក្លាយជាអាណាព្យាបាលរបស់កូនបានទេតុលាការនឹង ធ្វើការសម្រេចដោយយោងទៅលើស្ថានភាពគូភាគីថាតើអ្នកណាផ្តល់ផលប្រយោជន៍ដល់កូនច្រើនជាង។ ចំពោះអំណាចមេបានេះដែលប្រសិនឪពុកទទួលបានអំណាចមេបាម្តាយមិនអាចក្លាយជាអំណាចមេបារបស់កូនបានទេ ប្រសិនបើម្តាយក្លាយជាអំណាចមេបារបស់កូនឪពុកមិនអាចក្លាយជាអំណាចមេបារបស់កូនបានផងដែរ។ នៅក្នុងច្បាប់ចែងថា ស្ត្រីដែលសម្រាលកូន គឺជាម្តាយរបស់កូនប្រសិនបើឪពុកចង់ក្លាយជាអំណាចមេបារបស់កូន អាចធ្វើការពិភាសារជាមួយម្តាយរបស់កូនបានដោយមាន

ការយល់ព្រមពីរម្ដាយរបស់កូន។ ការទទួលស្គាល់កូន[19]ត្រូវធ្វើឡើងដោយការជូនដំណឹងទៅមន្ត្រីអាត្រានុកូលដ្ឋាន និងមានការយល់ព្រមពីម្ដាយ និងមានការចុះហត្ថលេខាលើលិខិតទទួលស្គាល់នោះ។ប៉ុន្តែប្រសិនបើកូននោះមានឪពុកស្របតាមច្បាប់រួចហើយពុំអាចទទួលស្គាល់កូននោះបានឡើយ។

ក្នុងករណីដែលឪពុកមិនព្រមទទួស្គាល់កូន ពេលដែលកូនធំដឹងក្តីបានដឹងថាជាឪពុករបស់ខ្លួន កូនអាចដាក់ពាក្យបណ្ដឹង[20]ទាមទារឱ្យទទួលស្គាល់បាន ក្នុងកំឡុងពេល១ (មួយ)ឆ្នាំ ដោយចាប់ពីពេលបានដឹងថាជាឪពុក។ បណ្ដឹងឱ្យទទួលស្គាល់នេះជាបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលដែលមានកូន ឬ បច្ឆាញាតិផ្ទាល់នៃកូនជាដើមចោទ និង មានឪពុកជាចុងចម្លើយ[21]។ ប៉ុន្តែនៅក្នុងស្ថានភាពជាក់ស្តែង ភាគច្រើនម្ដាយជាអ្នកដាក់ពាក្យប្ដឹង នៅពេលដែលកូនជាអនីតិជននៅឡើយ។

[19]ក្រមរដ្ឋប្បវេណី, លេខ នស រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៩៧។

[20]ក្រមរដ្ឋប្បវេណី, លេខ នស រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០០១ ។

[21] សេចក្តីកំណត់មាត្រានីមួយៗនៃ ក្រមរដ្ឋប្បវេណី (ភាគ៥ គន្ថីទី៧)២០១០។

# ជំពូកទី ២

# ផលប៉ះពាល់នៃការលែងលះ

# ជំពូកទី ២
# ផលប៉ះពាល់នៃការលែងលះ

## ផ្នែកទី១ ផលប៉ះពាល់ក្នុងគ្រួសារ

ការលែងលះ គឺជាដំណាក់កាលលំបាកបំផុតនៃជីវិតប្តីប្រពន្ធហើយ ការលែងលះអាចប៉ះពាល់ដល់ទាំងមនុស្សដែលលែងលះគ្នា និងកូនដែលពួកគេអាចមានទាំងរយៈពេលខ្លី និងរយៈពេលវែង។ បន្ទាប់ពីលែងលះគ្នាគូស្នេហ៍មួយគូនេះតែងតែជួបប្រទះនូវផលប៉ះពាល់ រួមទាំងការថយចុះនៃសុភមង្គល ការផ្លាស់ប្តូរស្ថានភាពសេដ្ឋកិច្ច និងបញ្ហាផ្លូវចិត្ត។ ផលប៉ះពាល់លើកុមារអាចរួមមានបញ្ហាការសិក្សា អាកប្បកិរិយានិងផ្លូវចិត្ត។ តាមការសិក្សាណែនាំថាកុមារដែលមានឪពុកម្តាយលែងលះគ្នាទំនងជាបង្ហាញបញ្ហាអាកប្បកិរិយាបែបនេះជាងកុមារដែលមានឪពុកម្តាយមិនលែងលះ។ ចំណែកឯទ្រព្យសម្បត្តិដែលសហពន្ធទាំងពីរបានរកស៊ីជាមួយគ្នាកន្លងមករួមទាំងអានុភាពទៅលើកូនទាក់ទងនឹងអំណាចមេបាក៏មានការលំបាកក្នុងការបែងចែង និងមានភាពស្មុគស្មាញផងដែរ។ យ៉ាងណាមិញ ក្នុងករណីការលែងលះភាគច្រើនឃើញថា ភាគីខាងប្រពន្ធហាក់បីដូចជាមានផលប៉ះពាល់ជាងភាគីខាងប្តីព្រោះថា ស្ត្រីមានភាពទន់ខ្សោយជាងបុរសក្នុងការស្វែងរកប្រាក់ចំណូលផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃ ជាពិសេសក្នុងសង្គមកម្ពុជាបច្ចុប្បន្នស្ត្រីភាគច្រើនហាក់បីដូចជាពឹងផ្អែកលើចំណូលខាងប្តីច្រើនជាងចំណូលខ្លួនឯង។ រីឯផលប៉ះពាល់ចំពោះសាច់ញាតិទាំងសងខាងក៏មានតិចតួចដែរ។

### ១.១. ចំពោះកូន

កូនៗ និងគ្រួសារនីមួយៗតែងមានភាពខុសប្លែកពីគ្នាដោយមានភាពខ្លាំង និងខ្សោយខុសៗគ្នា បុគ្គលិកលក្ខណៈ និងនិស្ស័យខុសៗគ្នានិងកម្រិតធនធានសង្គម អារម្មណ៍ និងសេដ្ឋកិច្ច ក៏ដូចជា ស្ថានភាពគ្រួសារខុសគ្នាមុនពេលលែងលះ។ ទោះបីជាមានភាពខុសប្លែកគ្នាទាំងនេះក៏ដោយ ការលែងលះត្រូវបានបង្ហាញថា នឹងកាត់បន្ថយសមត្ថភាពអនាគតរបស់កុមារក្នុងគ្រប់វិស័យនៃជីវិត រួមទាំងទំនាក់ទំនងគ្រួសារ ការអប់រំ សុខុមាលភាពផ្លូវអារម្មណ៍ និងអនាគតរបស់ពួកគេ។

#### ១.១.១. ផ្លូវចិត្ត

ការលែងលះគ្នាមានឥទ្ធិពលមិនល្អទៅលើកូនៗ ពេលដែលឪពុកម្តាយលែងលះហើយពួកគេអាចក្លាយទៅជាអ្នកទទួលរងគ្រោះក្នុងគ្រួសារ។ ពួកគេមានភាពឈឺចាប់ក្នុងចិត្ត ហើយអាចធ្លាក់ចូលទៅក្នុងភាពតក់ស្លុតនៅពេលឃើញឪពុកម្តាយបែកបាក់ជារៀងរហូត។ កូនៗតែងតែមានភាពឈឺចាប់ក្នុងចិត្ត អាចបាត់បង់ការចាប់អារម្មណ៍ទៅលើសកម្មភាពផ្សេងៗដូចជាមានភាពតានតឹងការផ្លាស់ប្តូរអារម្មណ៍និងឆាប់ខឹង ការព្រួយបារម្ភមានទុក្ខព្រួយនិងខកចិត្តដោយសារពួកគេមិនមានការគាំទ្រផ្នែកស្មារតីពេញលេញពីឪពុកម្តាយរបស់ពួកគេ។ ការលែងលះបង្កើតភាពរំជើបរំជួលអារម្មណ៍សម្រាប់ក្រុមគ្រួសារទាំងមូល។ ប៉ុន្តែសម្រាប់កូនៗស្ថានភាពបែប

នេះគួរឲ្យព្រួយបារម្មណ៍ និងភ័យខ្លាចជាងអ្វីដែលគ្រួសារកំពុងមើលឃើញផ្ទាល់ទៅទៀត។ កុមារតូចៗជារឿយៗ ពួកគេប្រហែលជាបារម្ភថាបើឪពុកម្តាយរបស់ពួកគេបានឈប់ស្រឡាញ់គ្នាទៅវិញទៅមក ប្រហែលថ្ងៃណាមួយ ឪពុកម្តាយប្រហែលជាឈប់ស្រឡាញ់ខ្លួនផងដែរ។ ក្មេងៗនៅសាលារៀនប្រហែលជាបារម្ភថាការលែងលះគឺជាកំហុសរបស់ពួកគេ។ ពួកគេប្រហែលជាភ័យខ្លាចថាពួកគេមិនមានសីលធម៌ ឬពួកគេអាចសន្មត់ថាពួកគេបានធ្វើអ្វីខុស។ ក្មេងជំទង់អាចមានកំហឹងខ្លាំងចំពោះការលែងលះនិងជម្ងឺបាក់ទឹកចិត្តផងដែរ។ កូនៗជាច្រើនបន្ទោសខ្លួនដោយសារឪពុកម្តាយលែងលះគ្នា។ ពួកគេគិតថាពួកគេជាដើមហេតុដែលនាំឲ្យពួកគាត់លែងលះ ឬមកពីពួកគេមិនបានជួយទប់ស្កាត់កុំឲ្យពួកគាត់លែងលះគ្នា។ ការពិបាកដែលមកពីការលែងលះគ្នាប្រហែលជាអាចបន្តមានរហូតដល់ពួកគេធំពេញវ័យ។ នេះអាចធ្វើឲ្យពួកគេមិនសូវឲ្យតម្លៃចំពោះខ្លួន ហើយពិបាកទុកចិត្តអ្នកឯទៀត។ ពេលពួកគេរៀបការ ពួកគេក៏ប្រហែលជាអាចនឹងលែងលះគ្នាដែរ បើពួកគេមានបញ្ហាជាមួយគ្នា។ ពួកគេប្រហែលជា បន្ទោសទៅលើមាតា ឬបិតាម្នាក់ចំពោះការរំលាយអាពាហ៍ពិពាហ៍ឬពួកគេប្រហែលជាមិនសប្បាយចិត្តនឹងឪពុក ម្តាយម្នាក់ឬទាំងពីរនាក់ចំពោះភាពចលាចលក្នុងគ្រួសារ។ បញ្ហាផ្លូវចិត្ត ជាបញ្ហាមួយធ្ងន់ធ្ងរបើពុំមានការមើលថែ និងយកចិត្តទុកដាក់នោះទេវាអាចឈានទៅដល់ការកើតជាជំងឺស្រ្តេសហើយក៏អាចវិវត្តទៅរកជំងឺធ្លាក់ទឹកចិត្តបាន។

### ១.១.២. សុខភាព

ចំពោះផលប៉ះពាល់ផ្នែកសុខភាពទៅលើកូនៗនៅពេលដែលឪពុកម្តាយមានការបែកបាក់គ្នាគឺធ្វើឲ្យកូនខ្វះអ្នកថែទាំអ្នកសុខភាព ខ្វះអាហារបំប៉នសម្រាប់ការលូតលាស់ និងខ្វះអ្នកគាំទ្រផ្លូវចិត្តផងដែរ។ នៅពេលលែងលះគ្នា កូនៗត្រូវរស់នៅជាមួយឪពុក ឬម្តាយតែម្ខាង ប៉ុន្តែឪពុក ឬម្តាយក៏ត្រូវទៅរកចំណូលដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃ ដែលជាមូលហេតុនាំឱ្យឪពុកម្តាយមិនសូវមានពេលវេលាគ្រប់គ្រាន់ក្នុងការមើលថែនិងយកចិត្តទុកដាក់ទៅលើចំណីអាហាររបស់កូននោះទេ។ ម៉្យាងទៀតពួកគេមិន មានប្រាក់ដើម្បីទិញចំណីអាហារគ្រប់គ្រាន់ទាំងនោះទេហើយនៅពេលដែលមានជម្ងឺ ពួកគេមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការរកគ្រូពេទ្យ ឬទិញថ្នាំសម្រាប់ព្យាបាលទេ ជាហេតុធ្វើឲ្យពួកគេធ្លាក់ទឹកចិត្ត រហូតឈានទៅដល់មានជម្ងឺប្រចាំកាយទៀតផង។ ជាទូទៅកុមារគឺត្រូវការថែទាំ យកចិត្តទុកដាក់ ពីសំណាក់ឪពុកម្តាយ ប្រសិនបើឪពុកម្តាយលែងលះគ្នា កុមារពិតជាទទួលរងការប៉ះទង្គិចជាច្រើនមិនថា ផ្លូវចិត្ត ឬផ្លូវកាយ វាសុទ្ធតែធ្វើឲ្យប៉ះពាល់ដល់សុខភាពទាំងអស់ ដែលធ្វើឱ្យកុមារអាចគ្មានស្មារតីស្រស់ថ្លា បាត់បង់នូវចំណង់អាហារ គ្មានភាពរស់រវើក ដែលជាហេតុនាំឲ្យកុមារមានជម្ងឺ។

## ១.១.៣. ការសិក្សាអប់រំ

កុមារដែលមានមាតាបិតាលែងលះ និងបែកបាក់ទំនាក់ទំនង ច្រើនតែសម្តែងការបាក់ទឹកចិត្ត ក្នុងការសិក្សានិងសកម្មភាពផ្សេងទៀតជាច្រើន។ កុមារទាំងនោះមានចំណាត់ថ្នាក់មិនល្អដូចមិត្តរួមថ្នាក់របស់ពួកគេក្នុងការសិក្សាមុខវិជ្ជាផ្សេងៗ និងទំនាក់ទំនងសង្គមទេដោយសារពួកគេទទួលរងនូវភាពខ្វល់ខ្វាយ ភាពតានតឹង និងអោយតម្លៃខ្លួនឯងទាប។ ការសិក្សាមួយបានរកឃើញថា ក្នុងឆ្នាំ ២០១០ មានកុមារ ៧៨ភាគរយ រស់នៅក្នុងគ្រួសារដែលមានឪពុកម្តាយទាំងពីរបានបញ្ចប់ការសិក្សាពីសាលារៀនជាន់ខ្ពស់នៅអាយុ២០ឆ្នាំ។ ប៉ុន្តែអ្នកដែលរស់នៅមានបញ្ហាជាលក្ខណៈគ្រួសារដែលមានការលែងលះ ឬការស្លាប់ ឬការរៀបការម្តងទៀត បានបញ្ចប់ការសិក្សាមានតែ ៦០ ភាគរយប៉ុណ្ណោះ។ កុមារដែលមានអាយុកាន់តែតិច នឹងត្រូវទទួលរងផលប៉ះពាល់ពីការលែងលះកាន់តែខ្លាំង។[22] ក្នុងគ្រួសារមួយ នៅពេលមានបញ្ហា មានជម្លោះដែលឈានដល់ការលែងលះបានធ្វើឱ្យកូនមានការព្រួយបារម្ភ និង បញ្ហាផ្លូវចិត្តដែលនាំឱ្យពិបាកផ្តោតអារម្មណ៍ទៅលើ ការសិក្សារៀនសូត្ររបស់ពួកគាត់ដោយបាត់បង់អារម្មណ៍ក្នុងការសិក្សារៀនសូត្រ ហើយខ្លះទៀតអាចនឹងឈប់សិក្សាថែមទៀតផង។ ពួកគេបានឈប់សិក្សា រីឯមួយចំនួនទៀតចាប់ផ្តើមធ្វើការងារក្រៅម៉ោងសិក្សាដើម្បីជួយទ្រទ្រង់ជីវភាពគ្រួសារបន្ថែមទៀត។ មួយវិញទៀត ពួកគេតែងតែប្តូរសាលារៀនជាញឹកញាប់ទៀតផងដោយសារប្តូរទៅរស់នៅជាមួយម្តាយ ឬឪពុក ឬសាច់ញាតិរបស់ឪពុកម្តាយរបស់ពួកគេ ព្រមទាំងអាចប្តូរសាលាដោយសារមានការមើលងាយ និងរើសអើងពីមិត្តរួមថ្នាក់របស់ពួកគេ។

## ១.១.៤. កិត្តិយស

កូនៗដែលមានឪពុកម្តាយលែងលះគ្នា ពួកគេត្រូវបានមនុស្សជុំវិញខ្លួនមើលងាយថាមានពូជពង្សមិនល្អ ថែមទាំងហៅពួកគេថាជាកូនគ្មានម៉ែគ្មានឪជាដើម។ ពេលខ្លះពួកគេមានការពិបាកក្នុងការស្វែងរកការងារធ្វើក៏ដូចជាពិបាកក្នុងការរើសគូរស្រករទៀតផង ដោយសារតែមានការប្រកាន់ និងមិនគោរពឱ្យតម្លៃរបស់គ្រួសារម្ខាងទើតទៅលើពួកគេ។ យ៉ាងណាមិញ នៅក្នុងសង្គមខ្មែរបច្ចុប្បន្ននៅមិនទាន់ចោលនៅឡើយទេពាក្យស្លោកថា " ស្លឹកឈើជ្រុះមិនឆ្ងាយពីគល់" ដែលមានន័យថាប្រសិនបើឪពុកម្តាយរបស់ពួកគេជាមនុស្ស ប្រភេទណាកូនៗរបស់ពួកគាត់ ក៏ជាមនុស្សប្រភេទនោះដែរ។ នេះជាការគិតមួយដែលមិនល្អ ក៏ព្រោះតែពួកគេ មិនប្រាកដថាជាមនុស្សដែលមិនល្អនោះដែរ។ ការស្ថិតនៅក្នុងគ្រួសារដែលបែកបាក់គ្នាវាពុំមែនជាកំហុសរបស់ពួកគេនោះទេ ការដែលវាយតម្លៃពួកគេទៅលើស្ថានភាពគ្រួសារវាជាការគិតមួយដែលអគតិដែលវាធ្វើឲ្យប៉ះពាល់ដល់កិត្តិយស។

[22] យោងតាមគេហទំព័រ https://old.khmerload.com/news/48324

### ១.១.៥. ការរំលោភបំពានផ្លូវភេទ

នៅពេលមានការលែងលះគ្នា កូនៗតែងតែទៅរស់នៅខាងម្តាយឬឪពុករបស់ពួកគេណាម្នាក់ជាក់ជាមិនខាន។ ការរស់នៅជាមេម៉ាយ ឬពោះម៉ាយមិនយូរមិនឆាប់ពួកគេនឹងចង់បានដៃគូថ្មីមួយទៀត ដើម្បីរស់នៅជាមួយគ្នានឹងមើលថែគ្នា ហើយកូនៗក៏ត្រូវរស់នៅជាមួយដៃគូថ្មីរបស់ឪពុកម្តាយពួកគេ។ ក៏ប៉ុន្តែយើងគ្រប់គ្នាតែងតែបានលឺបានដឹងតាមសារព័ត៌មានផ្សេងៗ ជាពិសេសតាមបណ្តាញសង្គមទំនាក់ទំនងនានាតែម្តងទៅលើករណីរំលោភផ្លូវភេទជាច្រើន ដែលជនបង្កជាឪពុកចុងរបស់ក្មេងស្រីនោះជាអ្នករំលោភ។ករណីជាច្រើនតែងឃើញកើតមានឡើងជារឿយៗ ដែលឪពុកចុងធ្វើសកម្មភាព រំលោភទៅលើកូនចុង នៅពេលដែលម្តាយមិននៅព្រមទាំងបានគំរាមមិនឲ្យប្រាប់នរណា បើពុំដូចច្នោះគេនឹង វាយធ្វើបាប។ ករណីបែបនេះឃើញមានជាញឹកញាប់ដែលវាគឺជាអំពើដែលស្មោគគ្រោក និងមិនអាចទទួលយកបានដែលសង្គមមិនចង់ឲ្យកើតមាន។

## ១.២.ចំពោះប្តី-ប្រពន្ធ

### ១.២.១. ផ្លូវចិត្ត

ការលែងលះគឺជាការផ្លាស់ប្តូរជីវិតមួយរបស់មនុស្ស ដែលបង្កឱ្យប៉ះពាល់ដល់សុខុមាលភាពផ្លូវចិត្តរបស់ប្តី និងប្រពន្ធផងដែរ។ ពេលប្តីប្រពន្ធលែងលះគ្នា ពួកគេតានតឹងដែលអាចនឹងមានពេញមួយជីវិត។ មនុស្សមួយចំនួនមានអារម្មណ៍រំជើបរំជួលយ៉ាងខ្លាំង ចំពោះបទពិសោធន៍នេះ ដែលពួកគេបានឆ្លងកាត់ការផ្ទុះអារម្មណ៍ជាច្រើនដូចជា សោកសៅ ភាពច្របូកច្របល់ កំហុស កំហឹងជាដើម។ អារម្មណ៍ទាំងនេះអាចមានវត្តមានមិនត្រឹមតែនៅចុងបញ្ចប់នៃអាពាហ៍ពិពាហ៍របស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែក៏មាននៅពេលចាប់ផ្តើមនៃការលែងលះផងដែរ។ ការលែងលះអាចប៉ះពាល់ដល់សុខភាពផ្លូវចិត្តរបស់ប្តី និងប្រពន្ធ ដោយសារមានបញ្ហាផ្លូវចិត្តធ្ងន់ធ្ងរដោយមានអារម្មណ៍ថាខ្លួនមានកំហុស ជាញឹកញាប់ជាលទ្ធផលនៃការលែងលះ ជាពិសេសនៅពេលដែលដៃគូម្នាក់ចាប់ផ្តើមលែងលះ។ នេះក៏ជារយៈពេលដែលរំពឹងទុកសម្រាប់អារម្មណ៍សោកសៅ កំហឹង ការភ័យខ្លាច ការថប់បារម្ភ និងការធ្លាក់ទឹកចិត្តផងដែរ។ ប្រសិនបើអារម្មណ៍អវិជ្ជមានទាំងនេះត្រូវបានព្រងើយកន្តើយសម្រាប់រយៈពេលបន្ត ពួកគេអាចមានផលវិបាកអវិជ្ជមាន។

ផលប៉ះពាល់នៃការលែងលះលើសុខភាពផ្លូវចិត្តមានដូចជា៖

- **ការថប់បារម្ភ៖** ការថប់បារម្ភអាចបណ្តាលមកពីការលែងលះ ដែលអាចនាំឱ្យមានការព្រួយបារម្ភខ្លាំងអំពីអនាគត និងការភ័យខ្លាចចំពោះអ្វីដែលនឹងកើតឡើងបន្ទាប់ពីការលែងលះកើតឡើង។ ពួកគេអាចគិតពីការរ៉ាប់រងការចំណាយ ឬវិធីដែលពួកគេនឹងកែតម្រូវចំពោះការផ្លាស់ប្តូរ។ពួកគេក៏ប្រហែលជាគិតអំពីអ្វីទៅជាជីវិតក្រោយពីការលែងលះ។ ការថប់អារម្មណ៍អាចបង្ហាញជាទម្រង់នៃការញ័របេះដូង បែកញើស និងក្នុងករណីខ្លះមានកំហឹង។

- **ជំងឺធ្លាក់ទឹកចិត្ត៖** ជំងឺធ្លាក់ទឹកចិត្តគឺជាការបង្ហាញទូទៅក្នុងចំណោមមនុស្សដែលកំពុងបន្តការលែងលះ ឬនៅពេលដែលការលែងលះបានចាប់ផ្តើមកើតឡើង។ មានអារម្មណ៍សោកសៅ និងឯកោ ហើយពួកគេក៏មានអារម្មណ៍មិនគ្រប់គ្រាន់ដែរ។ វាក៏អាចមានអារម្មណ៍បាត់បង់ការគ្រប់គ្រង និងលើសលប់ផងដែរ។ ពួកគេក៏អាចខ្វះថាមពល ឬមានការផ្លាស់ប្តូរមួយចំនួននៅក្នុងទម្លាប់នៃការញ៉ាំ និងការគេងរបស់ពួកគេ។
- **កំហឹង៖** អារម្មណ៍ខឹងជូនកាលសាមញ្ញជាងការបាក់ទឹកចិត្ត ឬអស់សង្ឃឹម។ ពួកគេឆាប់ឆេវឆាវ មួម៉ៅចំពោះប្តី-ប្រពន្ធមុន ឬលើខ្លួនឯង ឬសូម្បីតែមិត្តភ័ក្តិ ឬសាច់ញាតិដែលពួកគេជឿថាមិនបានដូចការរំពឹងទុក អាចនឹងកើតឡើងបន្ទាប់ពីការលែងលះ។
- **កំហុស៖** ការលែងលះអាចបណ្តាលឱ្យមានអារម្មណ៍ខុស ជាពិសេសប្រសិនបើការបែកគ្នាកើតឡើងដោយការបោកប្រាស់ ឬបញ្ហាមូលដ្ឋានផ្សេងទៀត។ មនុស្សដែលពោរពេញដោយកំហុសអាចនឹងជួបប្រទះនឹងភាពនឿយហត់ផ្លូវចិត្ត ការនិយាយអវិជ្ជមានចំពោះខ្លួនឯង ឬគំនិតអន់ជាង។[23]

### ១.២.២. សុខភាព

នៅក្នុងដំណាក់កាលនៃការលែងលះគ្នា ភាគីសុទ្ធតែបានឆ្លងកាត់រួចមកហើយនូវការឈ្លោះប្រកែកគ្នា។ ការប៉ះទង្គិចទាំងអស់នេះសុទ្ធតែបានធ្វើឲ្យមានការឈឺចាប់ទាំងផ្លូវកាយ និងផ្លូវចិត្ត ហើយស្ត្រីគឺជាបុគ្គលដែលងាយរងគ្រោះព្រោះគាត់មានស្មារតីទន់ខ្សោយជាងបុរស។ ស្ត្រីគាត់អាចមានបញ្ហាផ្លូវចិត្តដោយសារមានអារម្មណ៍ថាខ្មាសគេព្រោះរងនូវសម្ពាធពីអ្នកនៅជុំវិញខ្លួន ពីសង្គម ដែលអាចបណ្តាលឲ្យគាត់មានបញ្ហាសុខភាពជាញឹកញាប់។ ការលែងលះនឹងធ្វើស្ត្រីមានការប្រេះស្រាំក្នុងចិត្ត ឈឺផ្សា រហូតឈានដល់មានជម្ងឺប្រចាំកាយដែលអាចបណ្តាលមកពីការគេងមិនគ្រប់គ្រាន់ និងបរិភោគមិនគ្រប់គ្រាន់ផងដែល។

ចំពោះប្តីវិញ ក៏មានការបាក់ទឹកចិត្តដែរនៅពេលមានការបែកបាក់គ្រួសារ។ បុរសភាគច្រើនតែងតែយកសុរាជាការបំបាត់ទុក្ខដោយផឹកស្រាច្រើនហួសហេតុដែលបណ្តាលឱ្យប៉ះពាល់ដល់សុខភាពផ្លូវកាយធ្ងន់ធ្ងរ។ ពេលខ្លះបុរសក៏កើតជម្ងឺគេងមិនលក់ និងគ្មានចំណង់អាហារ ដែលអាចបណ្តាលឱ្យបាត់បង់ស្មារតីរហូតឈានដល់សតិមិនល្អដោយសារជាតិស្រវឹងផងដែរ។

[23] យោងតាមគេហទំព័រ https://www.talktoangel.com/blog/how-does-divorce-impact-the-mental-health-of-couples

ចំពោះពាក្យថាលែងលះនិងការបែកបាក់មិនមែនជាបំណងប្រាថ្នារបស់មនុស្សគ្រប់គ្នានោះទេ។ ដូចនេះនៅពេលដែលមានការបែកបាក់ ភាគីទាំងសងខាងតែងតែមានផលលំបាករៀងៗខ្លួនមិនថាបុរសឬស្ត្រីនោះទេតែពេលខ្លះបុរសដែលជាប្តីមិនសូវបង្ហាញការលំបាកមកក្រៅទេដូចមនុស្សស្រីនោះទេ។

## ១.២.៣. ការងារ

នៅពេលដែលមានការលែងលះគ្នាតែងតែមានផលប៉ះពាល់ទៅលើប្តីប្រពន្ធទាំងពីរទាំងផ្លូវកាយ និងផ្លូវចិត្ត ព្រមទាំងស្មារតី និងផ្នែកផ្សេងៗទៀត។ ចំពោះប្តី ប្រសិនបើគាត់ជាអ្នកធ្វើជំនួញ នោះអាចនឹងបាត់បង់ដៃគូសហការ ព្រោះដៃគូសហការមានការភ័យខ្លាចបរាជ័យបណ្តាលមកពីការលែងលះ។ តែប្រសិនបើគាត់ជាបុគ្គលិកធ្វើការ នោះគាត់អាចនឹងត្រូវធ្លាក់ដំណែងដោយសារតែការបាក់ទឹកចិត្ត ស្រ្តេសដែលបណ្តាលមកពីការលែងលះធ្វើឱ្យគាត់បំពេញការងារមិនបានល្អ។ ក្នុងករណីខ្លះបុរសអាចនឹងបាត់បង់ការងារដោយសារការបែកបាក់គ្រួសារបានធ្វើឱ្យពួកគេមានបញ្ហាផ្លូវចិត្តធ្ងន់ធ្ងរ។

ចំពោះប្រពន្ធវិញ ប្រសិនបើស្ត្រីនោះមានកូននៅតូចហើយអំណាចមេបាបានមកលើស្ត្រីនោះនឹងធ្វើឲ្យនាងពិបាកទៅធ្វើការរបស់នាងព្រោះជាប់រវល់មើលកូននៅតូច។ មិនមែនពិបាកចំពោះតែការមើលថែរក្សាកូនប៉ុណ្ណោះទេ គាត់អាចនឹងពិបាករកការងារធ្វើថែមទៀតផងព្រោះស្ត្រីខ្លះកាលនៅមានចំណងអាពាហ៍ពិពាហ៍ ស្ត្រីអាចឈប់ធ្វើការដើម្បីនៅផ្ទះមើលថែរក្សាកូន ថែរក្សាផ្ទះសម្បែងសុខចិត្តលះបង់ការងារតែក្រោយពីលែងលះគ្នាស្ត្រីគឺបាត់អ្នករកប្រាក់ដូចនេះគាត់ត្រូវរកប្រាក់ដោយខ្លួនឯង។បើអ្នកមានចំណេះជំនាញគាត់អាចមានសមត្ថភាពរកការងារសមរម្យបាន តែចំពោះអ្នកដែលគ្មានចំណេះជំនាញគាត់អាចនឹងពិបាករកការងារធ្វើ។ ជាពិសេសនោះគឺស្ត្រីដែលមិនបានរៀនខ្ពង់ខ្ពស់ថែមទាំងមិនជំនាញ ឬមិនធ្លាប់ធ្វើការងារទៀតនោះ វាគឺមានការលំបាកខ្លាំង និងងាយរងហានិភ័យជាងស្ត្រីដទៃទៀត។

## ១.២.៤. សេដ្ឋកិច្ច

នាពេលបច្ចុប្បន្នយើងសង្កេតឃើញថាស្ត្រីមួយចំនួនធំហាក់នៅពឹងលើប្រាក់ចំណូលប្តីនៅឡើយ ប្រសិនបើមានការលែងលះនោះនឹងធ្វើប៉ះពាល់ការចាយវាយប្រចាំថ្ងៃរបស់នាងជាក់ជាមិនខាន។ ស្ត្រីភាគច្រើនមានវិបត្តិផ្នែកហិរញ្ញវត្ថុក្រោយពេលលែងលះដោយសារត្រូវទទួលរ៉ាប់រងការចំណាយទាំងអស់តែម្នាក់ឯងដូចជាថ្លៃចំណីអាហារ ថ្លៃការសិក្សារបស់កូន និងចំណាយផ្សេងៗជាដើម ហើយប្រសិនបើនាងមានកូនច្រើនទៀតនោះនឹងត្រូវទទួលបន្ទុកកាន់តែច្រើនថែមទៀត។ អ្នកខ្លះក្រោយពីលែងលះ បើគាត់មានចំណេះជំនាញគាត់អាចទៅស្វែងរកការងារធ្វើបាន ប៉ុន្តែសម្រាប់អ្នកដែលគាត់គ្មានចំណេះ ជំនាញទេ វាពិតជាពិបាកសម្រាប់គាត់ខ្លាំងក្នុងការរកការងារធ្វើ។ ឯអ្នកខ្លះគាត់ត្រូវបង្ខំចិត្តទៅធ្វើការងារណាដែលពុំត្រូវការជំនាញខ្ពស់ទេ តែវាគឺប្រឈម និង

ទទួលរងនូវការរិះគន់ ឬជិះជៀលពីអ្នកដទៃ។ រីឯអ្នកខ្លះគាត់ត្រូវទៅធ្វើការរោងចក្រ ខ្លះធ្វើការនៅក្នុងហាងនានា ខ្លះទៀតធ្វើចំណាកស្រុក ដើម្បីស្វែងរកការងារឆ្ងាយកូនចៅហើយទទួលប្រាក់ខែក៏មិនច្រើនក្នុងការផ្គត់ផ្គង់គ្រួសារថែមទៀតផងដែលវាជាការលំបាកដល់ពួកគាត់។ មួយវិញទៀតនៅពេលលែងលះគ្នា បុរសជាប្តីក៏មានកាតព្វកិច្ចជួយក្នុងការឧបត្ថម្ភកូនផងដែរ ប្រសិនបើអំណាចមេបាបានទៅលើខាងប្រពន្ធ ប៉ុន្តែបុរសមួយចំនួនតូចមិនបានជួយនោះទេដោយសារខ្លះគ្មានថវិការគ្រប់គ្រាន់ ខ្លះទៀតត្រូវចំណាយលើគ្រួសារថ្មីផងដែរ។

ចំណែកបុរសវិញដូចមិនសូវមានវិបត្តិផ្នែកសេដ្ឋកិច្ចប៉ុន្មាននោះទេ ព្រោះភាគច្រើនគាត់គឺជាអ្នករកលុយចិញ្ចឹមគ្រួសារស្រាប់ ក៏ប៉ុន្តែបុរសមួយចំនួនក៏មានផលប៉ះពាល់ដែរ នៅពេលការលែងលះប៉ះពាល់ដល់ការងាររបស់គាត់ នោះការរកប្រាក់ចំណូលក៏ធ្លាក់ទៅតាមនឹងដែរ។ ម្យ៉ាងវិញទៀតចំណូលរបស់គាត់នឹងត្រូវបែងចែកជាពីរដែលគាត់ក៏ត្រូវជួយឧបត្ថម្ភអាហារតព្វកិច្ចរបស់កូនៗដែលបណ្តាលឱ្យការចាយវាយផ្សេងៗមានការលំបាក។

### ១.២.៥. កិត្តិយស

នៅក្នុងសង្គមខ្មែរ តាំងតែពីអតីតកាលរហូតដល់បច្ចុប្បន្ននៅមិនទាន់បានលះបង់នៅឡើយទេពាក្យថាឈ្មោះជា "មេម៉ាយចំណាយមាត់អ្នកស្រុក" ដែលន័យនេះសំដៅលើស្ត្រីដែលត្រូវបានលែងលះជាមួយស្វាមីហើយ ត្រូវបានគេមាក់ងាយឬពេបជ្រាយថាជាស្ត្រីមិនល្អថែមទាំងមិនឲ្យតម្លៃនៅក្នុងសង្គមនោះទេ។ ជាពិសេសស្ត្រីដែលទើបតែលែងលះងាយរងការរិះគន់ជាងបុរស ហើយប្រសិនបើថ្ងៃណាមួយនាងចង់រៀបការថ្មីនោះនឹងមិនសូវមានអ្នកណាឱ្យតម្លៃ និងគោរពនោះទេដោយលើកឡើងថា នាងមានប្រវត្តិមិនល្អ។ ប្រាកដណាស់ការលែងលះជះផលអាក្រក់ដល់កិត្តិយសចំពោះស្ត្រីក្នុងសង្គមខ្មែរជាការពិតមែន តែអាចនឹងជះផលអាក្រក់ជាងនេះទៅទៀត បើការរស់នៅនោះជាការរស់នៅមួយមិនចុះសម្រុងនឹងគ្នា តើស្ត្រីនៅតែទ្រាំរស់នៅក្រោមសម្ពាធជាមួយស្វាមីបន្តទៀត រឺយ៉ាងណា? តើសុខចិត្តទ្រាំរស់នៅដើម្បីតែបន្តរក្សាកិត្តិយសរបស់ខ្លួនហើយសុខចិត្តឈឺចាប់ផ្លូវចិត្ត? សំណួរនេះមានតែស្ត្រីដែលធ្លាប់ឆ្លងកាត់ផ្ទាល់ទេដែលអាចឆ្លើយបាន។ មុននឹងសម្រេចចិត្តរៀបការតែងតែសង្ឃឹមថាមានសុភមង្គល តែគ្មាននរណាអាចមើលដឹងទេថាថ្ងៃស្អែកនឹងមានអ្វីកើតឡើង។ ជីវិតលែងលះគ្មានស្រីណាចង់ជួបនោះទេ។

ជាធម្មតាបុរសគ្រប់គ្នាសុទ្ធតែមានកិត្តិយសរបស់ខ្លួន និងសេចក្តីថ្លៃថ្នូរ ដូច្នេះកាលណាមានការបែកបាក់ឬមានការលែងលះតែងតែមានការអាប់ឱនដល់កិត្តិយសរបស់ខ្លួនហើយមានការរើសអើងក្នុងសង្គមដែរ។ ប៉ុន្តែជាក់ស្តែងក្នុងប្រទេសកម្ពុជា បុរសមិនសូវមានការរិះគន់ ឬប្រកាន់ដូចស្ត្រីនោះទេ។

## ១.២.៦. ទំនាក់ទំនងរវាងឪពុក-ម្តាយ និងកូន

### ១.២.៦.១. ទំនាក់ទំនងរវាងឪពុក និងកូន

ចំពោះទំនាក់ទំនងរវាងឪពុក និងកូនអាចនឹងឃ្លាតឆ្ងាយ បើអំណាចមេបាបានទៅលើខាងម្តាយ។ មួយវិញទៀត ប្រសិនបើម្តាយហាមឃាត់មិនឱ្យជួបកូន ឬឪពុកមិនដែលទៅលេងកូនថែមទៀតនោះមិនត្រឹមតែឃ្លាតឆ្ងាយតែកាយកូននោះទេ សូម្បីតែមនោសញ្ចេតនាក៏មិនសូវមានដូចកាលពីមុនដែរដូចពាក្យចាស់ពោលថា"ឆ្ងាយកាយណាយចិត្ត"។ ពេលឪពុកលែងលះគ្នា គាត់ចំណាយពេលវេលាតិចជាមួយកូនដោយពេលខ្លះគាត់ជួបកូនបានតែមួយសប្តាហ៍ត្រឹមមួយដងតែប៉ុណ្ណោះដោយសារគាត់មិនសូវយកចិត្តទុកដាក់លើកូនៗនោះទេ។ លើសពីនេះទៅទៀតនោះ កូនខ្លះធំឡើងសឹងមិនស្គាល់ថាឪពុកថែមទៀតផងព្រោះខានជួបគ្នាយូរនិងមិនបានប្រាស្រ័យទាក់ទងគ្នា។

### ១.២.៦.២. ទំនាក់ទំនងរវាងម្តាយ និងកូន

ការលែងលះនឹងធ្វើឱ្យទំនាក់ទំនងរវាងម្តាយនិងកូនឃ្លាតឆ្ងាយគ្នាបន្តិចម្តងៗប្រសិនបើឪពុកជាអ្នកមានអំណាចមេបា។ មិនថាកុមារ ឬវ័យជំទង់នោះទេតែងតែត្រូវការមើលថៃពីឪពុកម្តាយទាំងផ្នែកសម្ភារៈ និងស្មារតីតែកាលបើបែកពីឪពុក ឬម្តាយហើយនោះទំនាក់ទនងរបស់ពួកគេក៏ត្រូវផ្លាស់ប្តូរដែរ។ ម្យ៉ាងវិញទៀត ចំពោះម្តាយដែលគាត់មានអំណាចមេបាហើយ តែបែជាមានបញ្ហាខាងហិរញ្ញវត្ថុមិនអាចនៅមើលថៃកូនឱ្យបានដិតដល់នោះទេដោយត្រូវផ្ញើកូនទៅនឹងជីដូនជីតា ហើយចេញទៅធ្វើការ ឬរកស៊ីដើម្បីដោះស្រាយ បញ្ហាហិរញ្ញវត្ថុ។ កត្តានេះហើយដែលធ្វើឱ្យកូនមិនសូវមាន មនោសញ្ចេតនាជាមួយម្តាយ។ កូនខ្លះទៀតមិនស្គាល់មុខម្តាយថែមទៀតផងដោយសារតែម្តាយត្រូវធ្វើការនៅទីក្រុង ឬធ្វើចំណាកស្រុក។ ដូច្នេះហើយពេលមានបុណ្យទានទើបបានមកលេងកូនម្តង។

## ១.២.៧. ទំនាក់ទំនងចំពោះសាច់ញាតិពន្ធទាំងសងខាង

ក្រោយពីលែងលះ ឃើញថាទំនាក់ទំនងសាច់ញាតិសហាពន្ធទាំងសងខាងមានការរកាំរកូស មើលមុខគ្នាមិនចំ ជាពិសេសដន្លងនឹងដន្លងតែម្តង។ ចំពោះសាច់ញាតិផ្សេងទៀតក៏មានផលប៉ះពាល់ផងដែរ។ ទោះបីជាប្តី-ប្រពន្ធបានបញ្ចប់ទំនាក់ទំនងហើយក៏ដោយសាច់ញាតិគ្រួសារទាំងសងខ្លះនៅតែមានជម្លោះនឹងគ្នា។ ពេលខ្លះគ្រាន់តែទៅលេងកូនសោះក៏ឈ្លោះទាស់ទែងគ្នា ហាមមិនឱ្យជួបមុខកូន ឬដេរប្រទេចគ្នា។ ខ្លះទៀតទៅដណ្តើមយកកូនពីឪពុក ឬម្តាយដែលមានអំណាចមេបាតាមផ្លូវច្បាប់ថែមទៀតផង។

## ផ្នែកទី២ ផលប៉ះពាល់ក្នុងសង្គម

ពេលខ្លះ ការលែងលះអាចជួយសង្គ្រោះបុគ្គលម្នាក់ៗពីអាពាហ៍ពិពាហ៍មិនល្អ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយការស្រាវជ្រាវបង្ហាញថា ការលែងលះជាទូទៅធ្វើឱ្យសង្គមចុះខ្សោយយ៉ាងខ្លាំង។ នេះដោយសារតែអាពាហ៍ពិពាហ៍គឺជាអង្គភាពសង្គមមួយផ្អែកលើការបង្កើតគ្រួសារ និងផ្តល់ការគាំទ្រផ្នែកអប់រំ អារម្មណ៍ និងហិរញ្ញវត្ថុក្នុងការរីកចម្រើនក្នុងសង្គមជាបន្តបន្ទាប់។ នៅពេលដែលការលែងលះកើតឡើង គ្រួសារទាំងនេះកាន់តែមិនសូវមានផលិតភាពក្នុងសង្គមហើយសុខភាពផ្លូវចិត្តនិងផ្លូវកាយអាចរងទុក្ខក្រោយការលែងលះ។[24] នៅពេលដែលកើតមានការលែងលះជាញឹកញាប់ និងជាបន្តបន្ទាប់នោះវាមិនត្រឹមតែប៉ះពាល់ដល់បុគ្គល និងគ្រួសារតែប៉ុណ្ណោះទេគឺអាចប៉ះពាល់ដល់សង្គមថែមទៀតផង។

### ២.១. សង្គមពោរពេញទៅដោយក្មេងកំព្រា

នៅពេលក្រុមគ្រួសារមួយបានបែកបាក់បុគ្គលទាំងពីរបានចែកផ្លូវគ្នាដើររៀងៗខ្លួន វាមិនសូវជាពិបាកប្រសិនបើចំណងអាពាហ៍ពិពាហ៍របស់ពួកគេមិនមានកូន តែប្រសិនបើពួកគេមានកូនក្នុងចំណងអាពាហ៍ពិពាហ៍បន្ទាប់ពីលែងលះគ្នាថាតើកូនរបស់គេនឹងទៅជាយ៉ាងណា? ត្រូវទៅនៅជាមួយនរណា ខាងម្តាយ ឬខាងឪពុក? ក្នុករណីខ្លះពេលដែលម្តាយ ឪពុកមានចំណងអាពាហ៍ពិពាហ៍ថ្មីឬបង្កើតគ្រួសារថ្មីមួយទៀត ពេលនោះពួកគេអាចមានការធ្វេសប្រហែស ឬមិនបានយកចិត្តទុកដាក់ខ្លាំងលើកូនបែបនេះវាក៏ជាហេតុនាំឲ្យក្មេងមានអារម្មណ៍ថាខ្វះក្តីស្រលាញ់ហើយវាក៏ជាហេតុនាំឲ្យមានការប៉ះពាល់ដល់ផ្លូវចិត្តរបស់ក្មេងអាចឈានដល់ការមិនចង់រស់នៅក្នុងផ្ទះតទៅទៀតខ្លះរត់ចេញពីផ្ទះដែលនាំឱ្យពួកគេអាចក្លាយជាក្មេងកំព្រាឪពុកម្តាយ គ្មានទីពឹង ងាយប្រឈមទៅនឹងបញ្ហាជាច្រើនដូចជាខ្វះការអប់រំ កង្វះអាហារសម្រាប់បរិភោគ គ្មានកន្លែងស្នាក់នៅគ្មានសម្លៀកបំពាក់ ឬក្លាយក្មេងអានាថា។បញ្ហាក្មេងកំព្រានេះអាចជះឥទ្ធិពលដល់កុមារទាំងផ្នែករាងកាយបញ្ញាស្មារតី និងការវិវត្តផ្នែកអារម្មណ៍ក្នុងរយៈពេលវែង ហើយវាក៏ក្លាយជាបន្ទុកមួយសម្រាប់សង្គម។ យ៉ាងណាមិញក្រុមគ្រួសារខ្លះបានបញ្ជូនកូនរបស់ខ្លួនទៅកាន់មណ្ឌលកុមារកំព្រា។ បញ្ហាទាំងអស់នោះរួមមានការលែងលះ ជីវភាពក្រីក្រឪពុកម្តាយធ្វើចំណាកស្រុក ហើយនិងការយល់ឃើញថាមណ្ឌលកុមារកំព្រាជាកន្លែងមួយដែលអាចផ្តល់នូវការអប់រំ ថែទាំង និងជាកន្លែងមួយដ៏ល្អក្នុងការចិញ្ចឹមកូនៗរបស់ពួកគេ។ ការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រជាសកលបានបង្ហាញថា ការរស់នៅក្នុងមណ្ឌលកុមារកំព្រា អាចនឹងជះឥទ្ធិពលអវិជ្ជមានដល់កុមារទាំង ផ្នែករាង

[24] យោងតាមគេហទំព័រ: https://vwelfare.com/our_blogs/the-impact-of-divorce-on-society-parents-and-children/

កាយ បញ្ញាស្មារតី និងការវិវឌ្ឍផ្នែកអារម្មណ៍ ក្នុងរយៈពេលវែង នៅពេលដែលពួកគេធំពេញវ័យ។[25]

## ២.២. ស្ត្រីមេម៉ាយ និងបុរសពោះម៉ាយច្រើន

ក្រោយពេលលែងលះ អ្នកខ្លះអាចបង្កើតចំណងអាពាហ៍ពិពាហ៍ថ្មី រីឯអ្នកខ្លះទៀត ពួកគេសុខចិត្តរស់នៅម្នាក់ឯងជារៀងរហូតដោយមិនព្រមសាងគ្រួសារថ្មីទេ។ ហេតុផលទាំងនេះ វាក៏ជាកត្តាមួយដែលធ្វើឲ្យសង្គមយើងសម្បូរទៅដោយស្ត្រីមេម៉ាយ និងពោះម៉ាយច្រើន ហើយចំនួនប្រជាជនក៏ពុំសូវមានការកើនឡើងកាលណាដែលអត្រានៃការលែងលះកាន់តែមានកម្រិតខ្ពស់។ប្រសិនបើពុំមានការលែងលះក្រុមគ្រួសារមួយយ៉ាងតិចក៏មានកូនពីរនាក់ដែរមួយវិញទៀតបើការលែងលះបានសម្រេចក្រុមគ្រួសារខ្លះមានកូនមួយឬពីរនាក់ក្រោយការបញ្ចប់ចំណងអាពាហ៍ពិពាហ៍ពួកគេគ្មានបំណងរៀបអាពាហ៍ពិពាហ៍ថ្មី ដោយនៅជាស្ត្រីមេម៉ាយ ឬពោះម៉ាយបែបនេះឃើញថាកំណើតប្រជាជនក៏គ្មានការកើនឡើង ហើយវាក៏បានជះផលប៉ះពាល់ខ្លះដល់សង្គមផងដែរ។

## ២.៣. កង្វះធនធានមនុស្ស

បន្ទាប់ពីឪពុកម្តាយបានលែងលះគ្នាហើយ តែងតែមានការប៉ះពាល់ទៅលើកូនទាំងផ្លូវចិត្ត ផ្លូវកាយ ផ្នែកស្មារតី និងផ្នែកសម្ភារៈដែលវាបណ្តាលឱ្យកុមារបាត់បង់ ឬថយចុះសមត្ថភាពក្នុងការសិក្សានិងការទទួលបានការអប់រំ។ ការថយចុះសមត្ថភាពក្នុងការសិក្សានេះសំដៅទៅលើការពិបាកផ្តោតអារម្មណ៍ទៅលើការសិក្សារៀនសូត្រដោយសារតែរងការប៉ះពាល់ទៅលើបញ្ហាផ្លូវចិត្តពិបាកទទួលយក ឬពិបាកទទួលស្គាល់នៅពេលឪពុកម្តាយលែងលះគ្នា។ កាលដែលឪពុកម្តាយមិនទាន់លែងលះគ្នា កុមារទទួលបានការអប់រំដិតដល់ហើយថែមទាំងរៀនបានចំណាត់ថ្នាក់ល្អថែមទៀតផង។ ប៉ុន្តែក្រោយពេលដឹងថាឪពុកម្តាយរបស់ពួកគេលែងលះគ្នា ពួកគេមិនសូវយកចិត្តទិកដាក់ទៅលើការសិក្សានោះទេដែលធ្វើចំណាត់ថ្នាក់របស់ពួកគេធ្លាក់ចុះ។ លើសពីនេះទៅទៀតនោះ កុមារខ្លះបានក្លាយទៅជាក្មេងកំព្រា ក្មេងអនាថាមិនទទួលបានការអប់រំនោះទេ។ នេះបង្ហាញឱ្យឃើញថា សង្គមអាចនឹងបាត់បង់ធនធានមនុស្សបន្តិចម្តងៗដោយសារការលែងលះព្រោះថាកុមារ គឺជាទំពាំងស្នងឬស្សីហើយរួមចំណែកក្នុងការចូលរួមអភិវឌ្ឍសង្គមផងដែរ។

ម្យ៉ាងវិញទៀតជាធម្មតា មនុស្សម្នាក់ៗតែងប្រាថ្នាចង់ទទួលបានសុភមង្គល សេចក្តីសុខ និងសុវត្ថិភាពក្នុងជីវិត។ ជាពិសេសនោះគឺមុនពេលសម្រេចចិត្តរៀបការ ពួកគេតែងតែស្រមៃថាជីវិតអាពាហ៍ពិពាហ៍មានភាពឋិតថេរយូរអង្វែងរស់នៅយ៉ាងមានសេចក្តីសុខ តែក្រោយពេលរៀបការរួចបែរជារស់នៅមិនចុះសម្រុងនឹងគ្នាហើយត្រូវបែកបាក់គ្រួសារទៅវិញ។ កាលបើមានការលែងលះជាញឹកញាប់បែបនេះហើយបានធ្វើឱ្យអត្រានៃការ

[25] យោងតាមគេហទំព័រៈ https://www.rfi.fr/km/cambodia/homeless-children-increa-to-92percent-comparing-from-2014-to-2015-25-03-2016

រៀបការថយចុះ។ ជាពិសេសក្នុងសង្គមជាក់ស្តែង កាលបើឃើញថាប្តី-ប្រពន្ធរៀបកការរួចបែរជាលែងលះគ្នា ហើយបង្កឱ្យមានផលប៉ះពាល់ដល់បុគ្គល គ្រួសារ និងសង្គមថែមទៀតនោះបានធ្វើឱ្យក្មេងជំនាន់ក្រោយភ័យខ្លាចមិនចង់រៀបការព្រោះថាមិនត្រឹមតែមានទទួលរងនៅការប៉ះពាល់នៅថ្ងៃអនាគតនោះទេ ថែមទាំងត្រូវបានសង្គមរើសអើងទៀតផង។ កត្តានេះហើយក៏អាចបណ្តាយឱ្យសង្គមបាត់បង់នៅធនធានមនុស្សព្រោះថាគ្មានកំណើតប្រជាជនកើនឡើង ក៏អាចធ្វើឱ្យប្រទេសជាតិមិនមានការអភិវឌ្ឍបានដែរ។

## ២.៤. ការប្រើប្រាស់សារធាតុញៀន និងជួញដូរគ្រឿងញៀន

គ្រឿងញៀន គឺជាសារធាតុគីមីឬរុក្ខជាតិដែលមានឥទ្ធិពលធ្វើឱ្យមានរំញោចខ្លាំងទៅលើអ្នកដែលបាប្រើប្រាស់វាទាំងផ្នែកស្មារតីចិត្តអារម្មណ៍និងរូបរាងកាយហើយពិបាកនិងផ្តាច់ ឬបញ្ឈប់ការប្រើប្រាស់វាណាស់ ។ យោងតាមមាត្រា ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ បានចែងអំពីនិយមន័យនៃពាក្យ «គ្រឿងញៀន» ដែលសំដៅដល់រុក្ខជាតិញៀន សារធាតុញៀន និងសារធាតុគីមីផ្សំទាំងឡាយដែលបានកំណត់ក្នុងតារាងដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។ គ្រឿងញៀន តែងមានផលប៉ះពាល់ធ្ងន់ធ្ងរដល់សង្គមជាតិទាំងមូល ក្នុងនោះយុវជនគឺជាក្រុមដែលងាយរងគ្រោះជាងគេ។ យ៉ាងណាមិញការលែងលះក៏ជាកត្តាមួយដែលអាចធ្វើឱ្យបុគ្គលឈានដល់ការប្រើប្រាស់សារធាតុញៀនបានដែរ សូម្បីតែកូនៗរបស់ពួកគេក៏អាចធ្លាក់ខ្លួនក្នុងការប្រើប្រាស់សារធាតុញៀនផងដែរ ជាពិសេសនោះគឺកូនដែលស្ថិតនៅវ័យជំទង់ ឬជាយុវជនតែម្តង។ បញ្ហានេះកើតឡើងដោយសារតែពួកគេភាគច្រើនមានបញ្ហាផ្លូវចិត្តនិងមួយវិញទៀត ដោយសារតែបញ្ហាហិរញ្ញវត្ថុទើបធ្វើឱ្យពួកគេជួញដូរគ្រឿងញៀន ដើម្បីរកលុយចិញ្ចឹមជីវិត។បច្ចុប្បន្នការជួញដូរ ចែកចាយ និងប្រើប្រាស់គ្រឿងញៀននៅតែជាបញ្ហាគួរឲ្យព្រួយបារម្ភ និងកំពុងធ្វើឲ្យប៉ះពាល់ដល់សង្គម មិនថាទាំងនៅក្នុងរាជធានីភ្នំពេញ និងនៅតាមបណ្តាខេត្តនានាទូទាំងប្រទេស។ ឥទ្ធិពលនៃគ្រឿងញៀនកំពុងបំផ្លាញធនធានមនុស្សកាន់តែច្រើនឡើងៗគួរឲ្យកត់សម្គាល់ ។

ការប្រើប្រាស់គ្រឿងញៀនវាផ្តល់នូវផលប៉ះពាល់ដូចជា៖

- ផលប៉ះពាល់ចំពោះបុគ្គលអ្នកប្រើមានដូចជា ប៉ះពាល់ចំពោះសុខភាពផ្លូវកាយ ដែលនៅពេលបុគ្គលនោះប្រើប្រាស់គ្រឿងញៀន គឺវាបានជ្រាបចូលក្នុងសរីរាង្គរបស់មនុស្សមានថ្លើម បេះដូង តម្រងនោម និងសួតហើយបង្កឲ្យមានជម្ងឺដោយសារធាតុពុល និងជម្ងឺឆ្លងផ្សេងៗ រាងកាយស្គមស្គាំង ស្លេកស្លាំង មិនងងុយដេក មិនឃ្លានអាហារ និងកម្លាំងចុះថយ ។
- សម្រាប់ស្ត្រីមានផ្ទៃពោះ ប្រសិនបើប្រើប្រាស់គ្រឿងញៀន អាចមានឥទ្ធិពលផ្ទាល់ទៅលើទារកក្នុងផ្ទៃទាំងរាងកាយ និងខួរក្បាល។ សម្រាប់សុខភាពផ្លូវចិត្ត វាផ្តល់នូវផលប៉ះពាល់ដូចជា សតិស្មារតីមិន

ប្រក្រតី គ្មានភាពច្បាស់លាស់នូវការឃើញ ការស្តាប់ ការចងចាំថយចុះ ឬបាត់បង់តែម្តងនៅពេលដែលប្រើប្រាស់គ្រឿងញៀនលើសកម្រិត ។

- ផលប៉ះពាល់ចំពោះក្រុមគ្រួសារ មានដូចជា បាត់បង់កិត្តិយស បំផ្លាញទ្រព្យសម្បត្តិគ្រួសារ បង្កភាពភ័យខ្លាច អំពើហិង្សាក្នុងគ្រួសារ ខាតបង់ថវិកាជាដើម ។
- ផលប៉ះពាល់ចំពោះសង្គមជាតិមានដូចជាបង្កនូវអំពើអសីលធម៌ផ្សេងៗ អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងផ្លូវភេទ គ្រោះថ្នាក់ចរាចរណ៍ ការប្រព្រឹត្តអំពើឆក់ប្លន់ និងបទឧក្រិដ្ឋផ្សេងៗរួមទាំងបាត់បង់ធនធានមនុស្សជាដើម ។[26]

## ២.៥. ការអភិវឌ្ឍសេដ្ឋកិច្ច

ការអភិវឌ្ឍសេដ្ឋកិច្ចវិញ គឺសំដៅដល់ការរីកចម្រើននៃសង្គមទាំងមូលដែលមានទាំងកំណើនសេដ្ឋកិច្ចបូករួមទាំងប្រជាពលរដ្ឋអាចរស់នៅប្រកបដោយសុខុមាលភាព និងស្តង់ដារនៃការរស់នៅល្អប្រសើរជាងមុន។ ជាទូទៅ ដើម្បីពិនិត្យថា ប្រទេសមួយមានការអភិវឌ្ឍគេតែងពិនិត្យពី សន្ទស្សន៍ស្តីពីការអភិវឌ្ឍមនុស្សអត្រានៃការទទួលបានការអប់រំ អត្រានៃភាពក្រីក្រ ជាដើម។ធនធានមនុស្សគឺជាកម្លាំងចលករដ៏សំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចឱ្យរីកចម្រើន។ យ៉ាងណាមិញការលែងលះក៏មានផលប៉ះពាល់ទៅដល់ការអភិវឌ្ឍសេដ្ឋកិច្ចដោយសារតែការបាត់បង់នូវធនធានមនុស្ស។ ការបាត់បង់នូវធនធានមនុស្សនេះបណ្តាលមកពីបញ្ហាដែលបានលើកឡើងខាងលើដូចជាការថយចុះនៃការអប់រំរបស់កុមារ ភាពភ័យខ្លាចក្នុងការរៀបការ។ល។ ម្យ៉ាងវិញទៀត ការលែងលះគ្នាក៏ធ្វើឱ្យគ្រួសារមានវិបត្តិសេដ្ឋកិច្ចដោយសារតែបាត់បង់ប្រាក់ចំណូលគ្រួសារ គ្រួសារគ្មានការងារធ្វើដែលនាំឱ្យមានផលប៉ះពាល់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិផងដែរ។

## ២.៦. ការបង្កើនអត្រាចំណាយរបស់សង្គម

នៅពេលមានការលែងលះគ្នាកាន់តែច្រើននឹងធ្វើឲ្យសង្គមត្រូវប្រើកញ្ចប់ថវិកាជាតិជាច្រើនដើម្បីទប់ទល់ទៅនឹងបញ្ហានៃការលែងលះនេះមានដូចជាកញ្ចប់ថវិកាសម្រាប់ក្មេងដែលឪពុកម្តាយរបស់ពួកគេមានការបែកបាក់គ្នាពោលគឺជួយដល់ក្មេងៗកំព្រា និងក្មេងអនាថាក្នុងការទទួលបានការអប់រំ កន្លែងស្នាក់នៅ ចំណីអាហារ និងសម្លៀកបំពាក់ ព្រមទាំងកញ្ចប់ថវិកាសម្រាប់ស្ត្រីដែលត្រូវលែងលះគ្នា និងកញ្ចប់ថវិកាជាតិបម្រុងជាច្រើនទៀតទុកសម្រាប់ទ្រទ្រង់សង្គមជាតិ ដែលបណ្តាលមកពីករណីនៃការលែងលះនេះ។

[26] យោងតាមគេហទំព័រ: https://freshnewsasia.com/index.php/en/localnews/134790-2019-09-22-02-39-11.html

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ការសិក្សាអំពីការបែកបាក់គ្រួសារក្នុងសង្គមកម្ពុជាមានបំណងចម្បងគឺ កំណត់នូវបុព្វហេតុដែលឈានទៅដល់ការបែកបាក់គ្រួសារ និងបណ្តាលឱ្យមានផលប៉ះពាល់ក្នុងគ្រួសារ និងសង្គម។ ដោយឆ្លងតាមការសិក្សាស្រាវជ្រាវ រួចមករបស់យើងខ្ញុំទាំងពីរនាក់ យល់ឃើញថា មូលហេតុចម្បងដែលបណ្តាលឱ្យមានការបែកបាក់គ្រួសារ ឬការលែងលះកើតឡើងនៅក្នុងប្រទេសកម្ពុជាយើងនេះមានដូចជា ការប្រើប្រាស់អំពើហិង្សា ភាពក្រីក្រ កង្វះចំណេះដឹង ភាពមិនស្មោះត្រង់ ការប្រចណ្ឌ ការជ្រៀតជ្រែតពីញាតិពន្ធ និងកង្វះវិធីសាស្ត្រពិភាក្សាបញ្ហាគ្រួសារ។ ក្រៅពីមូលហេតុចម្បងៗទាំងនេះ ការសិក្សាក៏បង្ហាញនូវទិដ្ឋភាពផ្សេងៗដែលបង្ករទៅជាមូលហេតុទាំងនេះ ឬបានចូលរួមដោយផ្ទាល់ឬប្រយោលទៅក្នុងបញ្ហានៃការបែកបាក់គ្រួសារផងដែរ។ គ្រួសារខ្លះបែកបាក់គ្នាដោយសារមូលហេតុមួយឬច្រើន និងកត្តាផ្ទាល់ខ្លួនដូចជា កម្រិតការសិក្សា មុខរបរឬការងារ របៀបចាយវាយប្រាក់កាស ការសេពគប់មិត្តភិក្ក វាសុទ្ធតែមានចំណែកក្នុងបញ្ហានេះ។ សព្វថ្ងៃនេះការលែងលះនៅក្នុងសង្គមបច្ចុប្បន្នពួកយើងបានឃើញមានការលែងលះខ្លះនៅតុលាការ និងការលែងលះខ្លះទៀតនៅត្រឹមឃុំសង្កាត់តែប៉ុណ្ណោះ។ នៅក្នុងក្រមរដ្ឋប្បវេណី បណ្តឹងលែងលះនៅក្នុងប្រព័ន្ធតុលាការ បាននិយាយថាការដាក់ពាក្យបណ្តឹងលែងលះទៅកាត់តុលាការបានលុះត្រាប្តីប្រពន្ធមានសំបុត្រអាពាហ៍ពិពាហ៍ដែលធ្វើឡើងស្របទៅតាមច្បាប់កំណត់ នោះទើបតុលាការអាចទទួលពាក្យបណ្តឹងលែងលះនេះបាន។ ប្រសិនបើសហព័ន្ធមិនមានសំបុត្រអាពាហ៍ពិពាហ៍ស្រមទៅតាមច្បាប់កំណត់ទេនោះតុលាការមិនអាចទទួលយកពាក្យបណ្តឹងនោះបានទេ ពីព្រោះច្បាប់ចែងថាបុគ្គលដែលបានរៀបអាពាហ៍ពិពាហ៍ដោយមិនបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍មិនមែនជាប្តីប្រពន្ធស្របច្បាប់ទេហៅថា អនីតិសង្វាស។ ដូច្នេះការបែកបាក់គ្នាចំពោះអនីតិសង្វាសនេះដែល តុលាការមិនទទួលពាក្យបណ្តឹងលែងលះនេះទេ គេនិងឱ្យគូរភាគីដោះស្រាយដោយខ្លួនឯង។ ប្តីប្រពន្ធដែលមិនទៅចុះសំបុត្រអាពាហ៍ពិពាហ៍ ពេលដែលពួកគេចង់បែកបាក់គ្នាពួកគេទៅផ្ទះមេភូមិ ឬទៅក្រុមប្រឹក្សាឃុំសង្កាត់ដើម្បីស្នើសុំបែកបាក់គ្នា។ កាស្នើសុំរបស់គូរភាគីទៅកាន់មេភូមិ ឬឃុំសង្កាត់វាគ្រាន់តែជាការស្នើសុំឱ្យដឹងលឺ និងធ្វើជាសាក្សីឱ្យពួកគាត់ទាំងពីរតែប៉ុណ្ណោះថាពួកគាត់បានបែកបាក់គ្នារួចហើយ។ ប៉ុន្តែក្នុងករណីដែលអនីតិសង្វាសមានកូនអាចដាក់ពាក្យបណ្តឹងស្នើសុំធ្វើជាអំណាចមេបាទៅកាន់តុលាការបានដើម្បីឱ្យតុលាការធ្វើការដោះស្រាយបញ្ហាជូនគូភាគី។ហេតុនេះការបែកបាក់គ្រួសារនេះយើងឃើញថាវាបានផ្តល់ផលប៉ះពាល់ជាខ្លាំង ចំពោះកូន ចំពោះទំនាក់ទំងឪពុកម្តាយ និងកូន ចំពោះទំនាក់ទំនងសាច់ញាតិសហពន្ធ័ទាំងសងខាងហើយ ក៏ផ្តល់ផលប៉ះពាល់ក្នុងសង្គមផងដែរ។

យ៉ាងណាមិញការបែកបាក់គ្រួសារដែលអាចរក្សាផលប្រយោជន៍ឱ្យសហព័ន្ធទាំងសងខាងបានលុះត្រាតែ មុននិងរៀបអាពាហ៍ពិពាហ៍ ឬក្រោយរៀបអាពាហ៍ពិពាហ៍សហព័ន្ធទាំងពីរត្រូវតែទៅចុះសំបុត្រ

អាពាហ៍ពិពាហ៍ទៅតាមច្បាប់កំណត់ ពីព្រោះវាធ្វើឱ្យមានភាពងាយស្រួលក្នុងការដោះស្រាយបញ្ហានៅពេលដែលមានការស្នើសុំលែងលះគ្នា។

សរុបមកការសិក្សាស្រាវជ្រាវប្រធានបទនេះពិតជាឆ្លុះបញ្ចាំងពីទិដ្ឋភាពជាក់ស្តែងដែលកំពុងកើតមាននៅក្នុងសង្គមកម្ពុជា បើទោះបីមិនបានគ្រប់ជ្រុងជ្រោយក្តី ប៉ុន្តែលទ្ធផលចេញពីប្រធានបទនេះមានសារៈសំខាន់សម្រាប់អ្នកស្រាវជ្រាវ អ្នកធ្វើការងារទាក់ទងក្នុងសង្គម ដើម្បីពិចារណានិងស្វែងរកដំណោះស្រាយសម្រាប់បញ្ហាដែលកើតមាន ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានស្រាវជ្រាវ និងចងក្រងប្រធានបទ"ការលែងលះ និងផលប៉ះពាល់" រួចមក យើងខ្ញុំសង្កេតឃើញថា ប្រជាជនមិនសូវមានការយល់ដឹងអំពីរឿងអាពាហ៍ពិពាហ៍ស្របច្បាប់ អំពីការលែងលះ និងផលប៉ះពាល់បន្ទាប់ពីការលែងលះនៅឡើយនោះទេ ដោយសារពួកគាត់ពុំទទួលនូវការផ្សព្វផ្សាយអំពីឯកសារច្បាប់ និងព័ត៌មានដែលពាក់ព័ន្ធឱ្យបានទូលំទូលាយនិងស៊ីជម្រៅជាក់លាក់នៅឡើយ។ ជាពិសេស ប្រជាជនរស់នៅតំបន់ដាច់ស្រយាលភាគច្រើនពួកគាត់គ្រាន់តែរៀបចំប្រាព្ធធ្វើនូវពិធីតតាមទំនៀមទម្លាប់ប្រពៃណីតាំងពីដូនតាមកម្ល៉េះ ដើម្បីបង្ហាញថាកូនកំលោះកូនក្រមុំជាស្វាមី ភរិយាតែប៉ុណ្ណោះដោយមិនបានចុះសំបុត្រអាពាពិពាហ៍។ មួយវិញទៀត នៅពេលមានវិវាទក្នុងគ្រួសារកើតឡើងរហូតឈានដល់ការលែងលះ វាមិនត្រឹមតែផ្តល់ផលអវិជ្ជមានដល់ប្តី និងប្រពន្ធនោះទេពោល គឺជះឥទ្ធិពលដល់កូន និងសង្គមថែមទៀតផង។

ជាចុងក្រោយបំផុតក្នុងគោលបំណង និងឆន្ទៈដើម្បីធ្វើឲ្យស្នាដៃមួយនេះអាចយកទៅអនុវត្តបានយ៉ាងត្រឹមត្រូវសមស្របទៅនឹងស្ថានភាពនិងកាលៈទេសៈជាក់ស្តែង ក៏ដូចជាកាត់បន្ថយការលែងលះក្នុងសង្គម យើងខ្ញុំសូមការអនុញ្ញាតលើកឡើងនូវអនុសាសន៍មួយចំនួនដូចខាងក្រោមៈ

❖ **ចំពោះរដ្ឋ ឬរដ្ឋាភិបាល**

- សូមរាជរដ្ឋាភិបាលធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះឱ្យបានយល់ដឹងគ្រប់ៗគ្នា ជាពិសេសដាក់ទណ្ឌកម្មដល់អ្នករំលោភបំពានច្បាប់នេះ និងអ្នកប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារឲមានលក្ខណៈធ្ងន់ធ្ងរ
- សូមឱ្យមានការការពារផ្លូវច្បាប់ដោយតុលាការ នៅក្នុងករណីមានការលែងលះគ្នា
- សូមឱ្យស្ថាប័នដែលពាក់ព័ន្ធគួរតែបណ្តុះបណ្តាលដល់មន្ត្រីដែលធ្វើការផ្នែកអត្រានុកូលដ្ឋានតាមមូលដ្ឋានឲ្យយល់ដឹងបានទូលំទូលាយពីសេវាសាធារណៈនេះ ដើម្បីឱ្យពួកគាត់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញការងារជូនប្រជាពលរដ្ឋ។
- សូមរាជរដ្ឋាភិបាលមេត្តាទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងឱ្យមានប្រសិទ្ធភាព និងស្របតាមពេលវេលាជាក់ស្តែង។
- សូមរាជរដ្ឋាភិបាលជួយទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀននៅក្នុងសង្គមឱ្យមានប្រសិទ្ធភាពខ្ពស់។

❖ **ចំពោះមន្ត្រីអនុវត្តច្បាប់**

- សូមឲ្យមន្ត្រីនៅថ្នាក់មូលដ្ឋាន ដែលពាក់ព័ទ្ធទៅនឹងសំណុំរឿងនៃការលែងលះគួរតែជួយផ្សះផ្សាសហព័ទ្ធនោះឱ្យអស់លទ្ធភាពជាមុនសិន មុនពេលសម្រេចចិត្តឱ្យពួកគាត់លែងលះគ្នាតាមផ្លូវតុលាការ

- សូមឱ្យអាជ្ញាធរដែនដីធ្វើអន្តរាគមន៍ជាបន្ទាន់រាល់ពេលមានអំពើហិង្សាកើតឡើង ដើម្បីទប់ស្កាត់កុំឲ្យមានអំពើហិង្សាធ្ងន់ធ្ងររហូតឈានទៅដល់ការលែងលះគ្នា
- សូមឱ្យមន្ត្រីដែលពាក់ព័ន្ធមេត្តាផ្តល់នូវជំនួយផ្លូវច្បាប់ណាមួយដែលសមស្របតាមរយៈកាលៈទេសៈជាក់ស្តែង និងធានាសុវត្ថិភាពដល់គូភាគីនៅពេលមានបណ្តឹងលែងលះកើតឡើង
- សូមមន្ត្រីនៅថ្នាក់មូលដ្ឋាន ចុះបណ្តុះបណ្តាលជូនពលរដ្ឋរបស់ខ្លួនពីផលប៉ះពាល់នៃការលែងលះ ផលប៉ះពាល់នៃការប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារ និងផលប៉ះពាល់នៃការប្រើគ្រឿងញៀន។

❖ **ចំពោះប្តី-ប្រពន្ធ**

- សូមប្តីប្រពន្ធគិតឱ្យបានវែងឆ្ងាយមុនសម្រេចចិត្តលែងលះគ្នា ព្រោះផលប៉ះពាល់ដែលបណ្តាលមកពីការលែងលះគ្នានឹងធ្លាក់ទៅលើកូនៗរបស់យើងខ្លាំងជាងគេ។
- សូមប្តីប្រពន្ធទាំងឡាយ រៀនតាំងចិត្តថែរក្សាទំនាក់ទំនងឲ្យមានភាពរឹងមាំ ព្រោះគ្មានអ្វីដែលថា ធ្វើមិនបាននោះទេ ប្រសិនបើមានការតាំងចិត្ត។ ការតាំងចិត្តថែរក្សានូវទំនាក់ទំនងប្តីប្រពន្ធតម្រូវផងដែរឱ្យដៃគូទាំងសងខាងមានការតាំងចិត្តខ្ពស់ទើបអាចថែរក្សានូវទំនាក់ទំនងប្តីប្រពន្ធឱ្យមានភាពរឹងមាំ និងមិនអាចប្រះឆាគ្នាបាន ។
- សូមប្តីប្រពន្ធទាំងសងខាងរៀនគិតវិជ្ជមានអំពីគ្នាទៅវិញទៅមកព្រោះវាមិនត្រឹមតែធ្វើឱ្យយើងរស់នៅយ៉ាងមានក្តីសុខនោះទេ វាក៏ជារឿងមួយដែលមានប្រយោជន៍ជាខ្លាំងសម្រាប់ទំនាក់ទំនងប្តីប្រពន្ធព្រោះថានៅពេលដែលគិតអ្វីដែលល្អៗអំពីគ្នាវាក៏ជាវិធីសាស្ត្រមួយដែលធ្វើឲ្យមនុស្សពីរនាក់បង្កើននូវការទុកចិត្តគ្នា លើសពីនេះវាក៏ជួយឱ្យទំនាក់ទំនងរវាងប្តីប្រពន្ធរបស់មនុស្សពីរនាក់ជៀសផុតពីការឈ្លោះប្រកែកគ្នា។
- សូមប្តីប្រពន្ធចេះអធ្យាស្រ័យឱ្យគ្នាទៅវិញទៅមកនៅពេលដែលធ្វើខុស។ ពិតណាស់ក្នុងការរក្សាជីវិតគូឱ្យមានសុភមង្គល គឺតម្រូវឱ្យមនុស្សពីរនាក់ ចេះប្រើនូវពាក្យសុំទោសនៅពេលដែលធ្វើខុសលើសពីនេះរៀនធ្វើជាចាញ់និងមិនចង់ឈ្នះគ្នា នោះហើយដែលជាវិធីមួយដែលអាចជួយឲ្យបញ្ហារបស់ប្តីប្រពន្ធកាន់តែមានភាពធូរស្រាល ពីបញ្ហាដែលបានកើតឡើងនោះ។
- សូមប្តីប្រពន្ធចេះជួយកែតម្រូវគ្នាទៅវិញទៅមក ព្រោះមនុស្សយើងកើតមកមិនមាននរណាម្នាក់ថាមិនចេះធ្វើខុសនោះទេ ដូច្នេះហើយជីវិតជាប្តីប្រពន្ធក៏រមែងតែងមានការធ្វើខុស ចំពោះគ្នាដោយមិនដឹងខ្លួនអញ្ចឹងហើយវាក៏តម្រូវឱ្យមនុស្សពីរនាក់មានការកែតម្រូវឲ្យគ្នា ទៅវិញទៅមកនូវចំណុចណាមួយដែលខ្វះខាតលើសពីនេះការធ្វើបែបនេះវាក៏ធ្វើឱ្យទំនាក់ទំនងប្តីប្រពន្ធរបស់មនុស្សពីរនាក់កាន់តែមានភាពស្និទ្ធស្នាលនិងកាន់តែយល់ចិត្តគ្នា។

- សូមប្តីប្រពន្ធគ្រប់គូព្យាយាមមើលពីបញ្ហាគ្នាទៅវិញទៅមក ព្រោះគូស្នេហ៍ដែលរស់នៅជាមួយគ្នាយ៉ាងមានសុភមង្គលនោះ គឺពួកគេតែងតែព្យាយាមយល់នូវបញ្ហាដែលបានកើតឡើង ចំពោះជីវិតប្តីប្រពន្ធរបស់ពួកគេ។ ជាងនេះទៅទៀត ពួកគេមិនមែនខឹងគ្នា ឬបន្ទោសគ្នាទៅវិញទៅមកនោះទេគឺពួកគេតែងតែចំណាយពេលវេលា ដើម្បីពិភាក្សានិងរកដំណោះស្រាយជាមួយគ្នា ដូច្នេះហើយមិនថាបញ្ហាតូចឬធំខ្លាំងប៉ុណ្ណានោះទេ ក៏មិនអាចបំផ្លាញសុភមង្គលប្តីប្រពន្ធរបស់ពួកគេបាននោះទេ។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- ក្រមរដ្ឋប្បវេណីឆ្នាំ, លេខ នស រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧
- ក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦
- ច្បាប់ស្ដីពីឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៦
- ច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០
- ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងពាក់ព័ន្ធនឹងឋានៈបុគ្គល ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១០
- ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ១៩៨៩
- ច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៥
- ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២

## ២. ឯកសារយោងសៀវភៅតែងនិពន្ធ

- សៀវភៅសេចក្ដីពន្យល់មាត្រានីមួយៗ ក្រមរដ្ឋប្បវេណី(គន្ថីទី៧)
- សៀវភៅសេចក្ដីពន្យល់មាត្រានីមួយៗ ក្រមនីតិវិធីរដ្ឋប្បវេណី
- វចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត
- វចនានុក្រម Cambridge Dictionary

## ៣. ឯកសារយោងជាគេហទំព័រ

- គេហទំព័រ https://freshnewsasia.com/index.php/en/localnews/134790-2019-09-22-02-39-11.html
- គេហទំព័រ https://vwelfare.com/our_blogs/the-impact-of-divorce-on-society-parents-and-children/

# ឧបសម្ព័ន្ធ

## បញ្ជីឧបសម្ព័ន្ធ

- ឧបសម្ព័ន្ធទី១  ៖ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧
- ឧបសម្ព័ន្ធទី ២៖ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ ១៩៨៩
- ឧបសម្ព័ន្ធទី៣ ៖ ច្បាប់ស្តីពី ឯកពន្ធភាព ឆ្នាំ ២០០៦
- ឧបសម្ព័ន្ធទី៤ ៖ បញ្ជីអាពាហ៍ពិពាហ៍
- ឧបសម្ព័ន្ធទី ៥៖ ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍
- ឧបសម្ព័ន្ធទី ៦៖ សំបុត្រអាពាហ៍ពិពាហ៍
- ឧបសម្ព័ន្ធទី ៧៖ កិច្ចព្រមព្រៀងលែងលះ
- ឧបសម្ព័ន្ធទី ៨៖ ពាក្យស្នើសុំលែងលះតាមការព្រមព្រៀង
- ឧបសម្ព័ន្ធទី ៩៖ ពាក្យបណ្តឹងលែងលះ
- ឧបសម្ព័ន្ធទី ១០៖ សំណុំរឿងពាក់ព័ន្ធនឹងការលែងលះ

# ឧបសម្ព័ន្ធទី១៖
# ក្រមរដ្ឋប្បវេណី ឆ្នាំ
# ២០០៧

# ព្រះរាជក្រម

នស/រកម/១២០៧/០៧០

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមនីតិវិធីរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

## ផ្នែកទី ៣
## ប្រព័ន្ធទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ

### កថាភាគទី ១
### ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា

**មាត្រា ៩៦៩.–** កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ និង ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់

១-ប្តីប្រពន្ធ អាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិ នៅមុន ឬ ក្រោយអាពាហ៍ពិពាហ៍បាន ។ ប៉ុន្តែ កិច្ចសន្យានេះ មិនអាចធ្វើផ្ទុយនឹងបញ្ញត្តិស្តីពីសិទ្ធិទាមទារអាហារកាតព្វកិច្ច និង ភាគបម្រុងបានឡើយ ។

២-បើប្តីប្រពន្ធមិនបានធ្វើកិច្ចសន្យាពិសេសចំពោះទ្រព្យសម្បត្តិនោះទេ ទំនាក់ទំនងទ្រព្យសម្បត្តិនោះ ត្រូវអនុលោមតាមបញ្ញត្តិនៃកថាភាគទី ២ (ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់) ។

**មាត្រា ៩៧០.–** ភាពចាំបាច់នៃទម្រង់ជាលាយល័ក្ខណ៍អក្សរនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ និង ល័ក្ខខ័ណ្ឌតតាំង

១-កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ។

២-ក្នុងករណីដែលប្តីប្រពន្ធបានធ្វើកិច្ចសន្យា ផ្សេងពីប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ បើមិនបានចុះបញ្ជីទេ មិនអាចយកកិច្ចសន្យានោះមកតតាំងជាមួយនឹងតតិយជនបានឡើយ ។

### កថាភាគទី ២
### ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់

**មាត្រា ៩៧១.–** ចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍

ប្តីប្រពន្ធ ត្រូវមានចំណែកបន្ទុកលើសោហ៊ុយដែលកើតចេញពីអាពាហ៍ពិពាហ៍

ដោយពិចារណាទៅលើទ្រព្យសម្បត្តិ ប្រាក់ចំណូល និង ស្ថានភាពផ្សេងៗទៀត ។

**មាត្រា ៩៧២.-** ទ្រព្យសម្បត្តិដោយឡែក

ទ្រព្យសម្បត្តិដែលកំណត់ដូចខាងក្រោមនេះ គឺជាទ្រព្យសម្បត្តិដោយឡែក ដែលស្ថិតនៅក្រោមកម្មសិទ្ធិរបស់សហព័ទ្ធណាម្នាក់ :

ក-ទ្រព្យសម្បត្តិ ដែលសហព័ទ្ធមាន នៅមុនពេលរៀបអាពាហ៍ពិពាហ៍ ។

ខ-ទ្រព្យសម្បត្តិ ដែលសហព័ទ្ធទទួលបាន ដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ។

គ-ទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដែលបានកំណត់ក្នុងចំណុច ក និង ចំណុច ខ ខាងលើនេះ ។

**មាត្រា ៩៧៣.-** ទ្រព្យសម្បត្តិរួម

ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយ ដែលប្តីប្រពន្ធទាំងសងខាង ឬ តែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិដែលកំណត់ក្នុងចំណុច ខ និង ចំណុច គ នៃមាត្រា ៩៧២ (ទ្រព្យសម្បត្តិដោយឡែក) ខាងលើនេះ ។

**មាត្រា ៩៧៤.-** ការគ្រប់គ្រង និង ការប្រើប្រាស់ទ្រព្យសម្បត្តិ

១-ប្តីប្រពន្ធ មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ទទួលផលប្រយោជន៍ និង គ្រប់គ្រងទ្រព្យសម្បត្តិរួម ។ សហព័ទ្ធនីមួយៗ មានសិទ្ធិប្រើប្រាស់ ទទួលផលប្រយោជន៍ និង គ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនរៀងៗខ្លួនបាន ។

២-សហព័ទ្ធ មានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិរួម នៅក្នុងទំហំដែលចាំបាច់ ដោយផ្អែកលើការចាំបាច់នៅក្នុងជីវភាព ។

៣-សហព័ទ្ធត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរួម ដោយសហការគ្នា ។ សហព័ទ្ធម្ខាងអាចទាមទារចំពោះភាគីម្ខាងទៀត ឱ្យធ្វើចំណាត់ការដែលចាំបាច់ដើម្បីគ្រប់គ្រង និង រក្សាទុកនូវទ្រព្យសម្បត្តិរួមបាន ។

៤-បើការពិភាក្សាអំពីការគ្រប់គ្រង ឬ ប្រើប្រាស់ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ

មិនបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ ភាគីម្ខាងទៀតអាចទាមទារទៅតុលាការឱ្យធ្វើការចាត់ចែងចំពោះការគ្រប់គ្រង និង ប្រើប្រាស់ទ្រព្យសម្បត្តិរួមបាន ។

**មាត្រា ៩៧៥.–** ការទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះកាតព្វកិច្ច

ប្តីប្រពន្ធត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះកាតព្វកិច្ចដែលកំណត់ខាងក្រោមនេះ :

ក-សោហ៊ុយដើម្បីរក្សាជីវភាពរួមរបស់ប្តីប្រពន្ធ និង សោហ៊ុយដើម្បីការអប់រំ ឬ ការព្យាបាល ថែទាំកូន ជាអាទិ៍ ។

ខ-កាតព្វកិច្ច និង ករណីយកិច្ចផ្សេងៗទៀត ដែលប្តី ឬ ប្រពន្ធទាំងសងខាងបានព្រមព្រៀងតាមលិខិតជាលាយល័ក្ខណ៍អក្សរ ជាមួយម្ចាស់បំណុល នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬ កាតព្វកិច្ច និង ករណីយកិច្ចផ្សេងៗទៀត ដែលប្តី ឬ ប្រពន្ធណាម្ខាងបានទទួលបន្ទុក ដោយមានការយល់ព្រមតាមលិខិតជាលាយល័ក្ខណ៍អក្សរ ពីប្រពន្ធ ឬ ប្តីម្ខាងទៀត នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ។

គ-សោហ៊ុយដើម្បីគ្រប់គ្រង និង រក្សាទ្រព្យសម្បត្តិរួម ។

**មាត្រា ៩៧៦.–** ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ

១-បើគ្មានការយល់ព្រមពីប្តីប្រពន្ធទាំងសងខាងទេ ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធមិនអាចយកទៅលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀតបានឡើយ ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើក៏ដោយ បើមានស្ថានភាពមិនអាចជៀសវាងបាន សម្រាប់ការថែទាំជីវភាពរួមក្នុងអាពាហ៍ពិពាហ៍ និង ដើម្បីរក្សាជីវភាពរស់នៅ នោះប្តីប្រពន្ធណាម្ខាង អាចលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀត នូវទ្រព្យសម្បត្តិរួមបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

៣-ក្នុងករណីដែលប្តី ឬ ប្រពន្ធណាម្ខាង បានលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀតនូវទ្រព្យសម្បត្តិរួម ដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតផង និង គ្មានការអនុញ្ញាតពីតុលាការផង សហព័ទ្ធដែលមិនបានផ្តល់ការយល់ព្រម អាចទាមទារឱ្យលុបចោលនូវការចាត់ចែងនោះ ទៅតុលាការបាន នៅក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ គិតចាប់ពីពេលដែលបាន

ដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះ ជាអចលនវត្ថុ និង នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះ ជាទ្រព្យសម្បត្តិផ្សេង ។

**មាត្រា ៩៧៧.-** ការអាស្រ័យនៅទ្រព្យសម្បត្តិដោយឡែក

១-ប្តីប្រពន្ធម្ខាងអាចអាស្រ័យនៅអចលនវត្ថុដែលជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាងទៀត ហើយដែលត្រូវបានប្រើសម្រាប់ការអាស្រ័យនៅរបស់គ្រួសារបាន ។

២-ក្នុងករណីដែលប្តីប្រពន្ធម្ខាងអាស្រ័យនៅអចលនវត្ថុដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ទោះបីជាសហព័ទ្ធម្ខាងទៀតបានចាត់ចែងអចលនវត្ថុនោះក៏ដោយ ក៏អាចបន្តអាស្រ័យនៅអចលនវត្ថុនោះបានដែរ ។

## ផ្នែកទី ៤

## ការលែងលះគ្នា

### កថាភាគទី ១

### មូលហេតុនៃការលែងលះគ្នា

**មាត្រា ៩៧៨.-** មូលហេតុនៃការលែងលះគ្នា

១-ប្តី ឬ ប្រពន្ធ អាចដាក់ពាក្យបណ្តឹងលែងលះគ្នាបាន តែក្នុងករណីដែលកំណត់ខាងក្រោមនេះ :

ក-បើបានប្រព្រឹត្តអំពើផិត ទៅលើសហព័ទ្ធ ។

ខ-បើបានបោះបង់សហព័ទ្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវ ។

គ-បើមិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬ រស់ អស់រយៈពេលជាង ១ (មួយ) ឆ្នាំ ។

ឃ-បើសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ អស់រយៈពេលជាង ១ (មួយ) ឆ្នាំ ផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍ ។

ង-ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយ

គ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន ។

២-ទោះបីជាក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ប្រសិនបើយល់ឃើញថា ការលែងលះគ្នានោះនឹងបណ្តាលឱ្យការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធ ឬ កូន ក្រលំបាកយ៉ាងខ្លាំង ឬ មានការឈឺចាប់ដែលពុំអាចទ្រាំទ្របាន តុលាការអាចច្រានចោលការទាមទារលែងលះគ្នា ដោយពិចារណាទៅលើស្ថានភាពទាំងឡាយបាន ។

៣-ក្នុងករណីដែលមានមូលហេតុដូចបានកំណត់នៅក្នុងចំណុច ឃ ឬ ចំណុច ង នៃកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើយល់ឃើញថា ការទាមទារនោះផ្ទុយនឹងភាពសុចរិត ដោយជនដែលទាមទារឱ្យលែងលះគ្នានោះ ធ្វេសប្រហែសយ៉ាងខ្លាំង ក្នុងការសហប្រតិបត្តិ និង ជួយសង្គ្រោះចំពោះសហព័ទ្ធ តុលាការអាចច្រានចោលការទាមទារលែងលះគ្នានោះ ដោយឆន្ទានុសិទ្ធិបាន ។

**មាត្រា ៩៧៩.-** ការលែងលះដោយការព្រមព្រៀង

ភាគីនៃអាពាហ៍ពិពាហ៍ អាចដាក់ពាក្យបណ្តឹងលែងលះ ទៅតុលាការបាន ក្នុងករណីដែលភាគីសងខាងបានព្រមព្រៀងអំពីការលែងលះគ្នា ។ ប៉ុន្តែ តុលាការអាចឱ្យលែងលះគ្នាបាន ក្រោយពីបានយល់ឃើញថា ភាគីសងខាងមានបំណងពិតប្រាកដ ក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ ។

**មាត្រា ៩៨០.-** ការបែងចែកទ្រព្យសម្បត្តិ

១-ក្នុងករណីដែលប្តីប្រពន្ធលែងលះគ្នា ត្រូវបែងចែកទ្រព្យសម្បត្តិដោយយុត្តិធម៌ ផ្អែកតាមការពិភាក្សារបស់ភាគីទាំងសងខាង ។

២-ក្នុងករណីដែលមិនអាចពិភាក្សាគ្នារវាងប្តីប្រពន្ធបានទេ ត្រូវបែងចែកទ្រព្យសម្បត្តិ ដោយផ្អែកតាមចំណុចនីមួយៗ ដូចកំណត់ខាងក្រោមនេះ :

ក-សហព័ទ្ធនីមួយៗ ត្រូវទទួលបាននូវទ្រព្យសម្បត្តិដោយឡែកដែលបានកំណត់នៅក្នុងមាត្រា ៩៧២ (ទ្រព្យសម្បត្តិដោយឡែក) ។

ខ-បន្ថែមពីលើទ្រព្យសម្បត្តិដោយឡែក សហព័ទ្ធនីមួយៗ មានសិទ្ធិទទួលយក ១ ភាគ ២ (មួយភាគពីរ) នៃទ្រព្យសម្បត្តិរួម ។ ប៉ុន្តែ បើមានករណីពិសេស និង មានការ

ឃុំសង្កាត់ ត្រូវបញ្ជូនពាក្យបណ្ដឹងនោះ ទៅតុលាការជាបន្ទាន់ ។

**មាត្រា ៩៨៣.–** ការចាត់ចែងរក្សាការពារ

តុលាការដែលទទួលពាក្យបណ្ដឹងលែងលះគ្នា ក្នុងករណីចាំបាច់ អាចចេញដីកាសម្រេចបង្គាប់ឱ្យធ្វើការចាត់ចែងរក្សាការពារ ចំពោះការបំបែកលំនៅ ការគ្រប់គ្រងថែរក្សាកូន ការគ្រប់គ្រងរក្សាទ្រព្យសម្បត្តិ អាហារកាតព្វកិច្ចរបស់សហព័ទ្ធ បន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍ និង សោហ៊ុយចិញ្ចឹមបីបាច់កូន ជាអាទិ៍ តាមពាក្យសុំ ឬ ដោយភន្នានុសិទ្ធិបាន ។

**មាត្រា ៩៨៤.–** ការសាកល្បងផ្សះផ្សា ដោយតុលាការ

១-ទោះបីជាភាគីម្ខាងទាមទារយ៉ាងខ្លាំង ចំពោះការលែងលះគ្នាក៏ដោយ តុលាការអាចសាកល្បងធ្វើការផ្សះផ្សាបាន ។

២-បើការផ្សះផ្សាពុំអាចសម្រេចបានទេ តុលាការត្រូវយកបណ្ដឹងលែងលះគ្នា មកធ្វើការវិនិច្ឆ័យ ហើយធ្វើការប្រកាសសាលក្រម ។

# ជំពូកទី ៤

# ឪពុកម្ដាយ និង កូន

## ផ្នែកទី ១

## បុត្តភាព

### កថាភាគទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ៩៨៥.–** ករណីយកិច្ចនៃការសុំចុះកំណើត

១-ឪពុក ឬ ម្ដាយរបស់កូន ត្រូវសុំចុះកំណើតរបស់កូន នៅសាលាឃុំសង្កាត់នៃលំនៅឋានរបស់ឪពុក ឬ ម្ដាយ ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពី

ថ្ងៃដែលកូននោះកើត ។ ប្រសិនបើឪពុក ឬ ម្ដាយមិនអាចសុំចុះបានទេ ញាតិជានីតិជន ដែលរស់នៅជាមួយឪពុកម្ដាយនៃកូន ត្រូវសុំចុះកំណើតរបស់កូននោះ ឱ្យបានឆាប់រហ័ស ។

២-ក្នុងករណីដែលឪពុកម្ដាយបានធ្វេសប្រហែសនឹងករណីយកិច្ចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ដោយគ្មានមូលហេតុត្រឹមត្រូវ នឹងត្រូវពិន័យស៊ីវិលជាប្រាក់ មិនលើសពី ១០.០០០ (មួយម៉ឺន) រៀល ។

**មាត្រា ៨៨៦.-** វិធីគណនាអាយុ

១-អាយុត្រូវគណនាដោយគិតចាប់ពីថ្ងៃកំណើត ។

២-បញ្ញត្តិនៃមាត្រា ៣៣៥ (ការគណនារយៈពេលតាមប្រតិទិនសុរិយគតិ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការគណនាអាយុ ។

## **កថាភាគទី ២**

## **ការសម្រេចអំពីបុត្តភាព**

**មាត្រា ៨៨៧.-** មាតុភាព

ស្ត្រីដែលបានសម្រាលកូន គឺជាម្ដាយរបស់កូន ។

**មាត្រា ៨៨៨.-** ការសន្មតបិតុភាព

១-ទារកនៅក្នុងគភ៌ប្រពន្ធដែលមាននៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ត្រូវសន្មតថាជាកូនរបស់ប្ដី ។

២-កូនដែលបានកើតនៅក្រោយរយៈពេល ១៨០ (មួយរយប៉ែតសិប) ថ្ងៃ គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍ ត្រូវបានបង្កើត ឬ ក្នុងរយៈពេល ៣០០ (បីរយ) ថ្ងៃ គិតចាប់ពីថ្ងៃដែលបានរំលាយ ឬ លុបចោលអាពាហ៍ពិពាហ៍ ត្រូវសន្មតថា មានគភ៌ នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍នោះ ។

៣-ក្នុងករណីដែលស្ត្រីបានរៀបអាពាហ៍ពិពាហ៍ថ្មីទៀតផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៩៥០ (រយៈពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត) នៃក្រមនេះ បានបង្កើត

កូន ប្រសិនបើមិនអាចកំណត់ឪពុករបស់កូននោះ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះទេ ត្រូវសន្មតថា កូននោះជាកូនរបស់ប្ដីដែលបានរៀបអាពាហ៍-ពិពាហ៍ក្រោយ ។

**មាត្រា ៨៨៩.-** ការបដិសេធបិតុភាព

នៅក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ៨៨៨ (ការសន្មតបិតុភាព) ខាងលើនេះ ជនដែលត្រូវបានសន្មតថាជាឪពុក ឬ កូន អាចបដិសេធបិតុភាពបាន ។

**មាត្រា ៨៩០.-** បណ្ដឹងបដិសេធបិតុភាពពីជនដែលត្រូវបានសន្មតថាជាឪពុក

១-សិទ្ធិបដិសេធរបស់ជនដែលត្រូវបានសន្មតថាជាឪពុកដែលបានកំណត់នៅក្នុងមាត្រា ៨៨៩ (ការបដិសេធបិតុភាព) ខាងលើនេះ ត្រូវអនុវត្ត ដោយបណ្ដឹងចំពោះកូន ។

២-ជនដែលត្រូវបានសន្មតថាជាឪពុក ត្រូវដាក់ពាក្យបណ្ដឹងបដិសេធបិតុភាព ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីពេលដែលខ្លួនបានដឹងអំពីកំណើតរបស់កូន ។

៣-នៅពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បានកន្លងផុត បើជនដែលត្រូវបានសន្មតថាជាឪពុក ជាជនដែលនៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេលនោះត្រូវគណនា ដោយគិតចាប់ពីពេលដែលមានការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ ដែលបានកំណត់នៅក្នុងមាត្រា ២៧ (ការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

**មាត្រា ៨៩១.-** បណ្ដឹងបដិសេធបិតុភាព ពីកូន

១-សិទ្ធិបដិសេធរបស់កូន ដែលបានកំណត់នៅក្នុងមាត្រា ៨៨៩ (ការបដិសេធបិតុភាព) នៃក្រមនេះ ត្រូវអនុវត្តដោយបណ្ដឹងចំពោះជនដែលត្រូវបានសន្មតថាជាឪពុក ។

២-ក្នុងករណីដែលកូនដែលជាអនីតិជន ប្រើសិទ្ធិបដិសេធ បើកូននោះគ្មានម្ដាយដែលអនុវត្តអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនទេ តុលាការត្រូវជ្រើសតាំងអ្នកតំណាងពិសេស ។

៣-កូន មិនអាចអនុវត្តសិទ្ធិបដិសេធបានឡើយ ប្រសិនបើអំឡុងពេល ៦ (ប្រាំមួយ)

នៃ បានកន្លងផុត គិតចាប់ពីពេលដែលខ្លួនបានក្លាយជានីតិជន ។

៤-នៅពេលដែលរំឭងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ បានកន្លងផុត បើកូនជាជននៅក្រោមអាណាព្យាបាលទូទៅ រំឭងពេលនោះត្រូវគណនា ដោយគិតចាប់ពីពេលដែលមានការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ ដែលបានកំណត់នៅក្នុងមាត្រា ២៧ (ការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

**មាត្រា *៩៩២*.-** អានុភាពប្រតិសកម្មនៃបណ្ដឹងបដិសេធបិតុភាព

ការបដិសេធបិតុភាព ត្រូវបង្កើតអានុភាពប្រតិសកម្មតាំងពីពេលកំណើតរបស់កូន ។

## កថាភាគទី ៣
## ការទទួលស្គាល់

**មាត្រា *៩៩៣*.-** ការទទួលស្គាល់ដោយស្ម័គ្រចិត្ត

ឪពុករបស់កូន អាចទទួលស្គាល់កូនបាន ។ ប៉ុន្តែ ប្រសិនបើកូននោះមានឪពុកតាមផ្លូវច្បាប់រួចហើយ ពុំអាចទទួលស្គាល់បានឡើយ ។

**មាត្រា *៩៩៤*.-** សមត្ថភាពក្នុងការទទួលស្គាល់

ដើម្បីទទួលស្គាល់ ទោះបីជាឪពុកជាអនីតិជន ឬ ជាជននៅក្រោមអាណាព្យាបាលទូទៅក៏ដោយ ក៏ពុំចាំបាច់មានការយល់ព្រម ពីអ្នកតំណាងដែលច្បាប់បានកំណត់ឡើយ ។

**មាត្រា *៩៩៥*.-** ការទទួលស្គាល់របស់ឪពុក

១-ឪពុកអាចទទួលស្គាល់កូនដែលជាអនីតិជនបាន ។

២-ទោះជាទារកនៅក្នុងគភ៌ក៏ដោយ ក៏ឪពុកអាចទទួលស្គាល់កូននោះបាន ដោយទទួលការយល់ព្រមពីម្ដាយ ។

**មាត្រា *៩៩៦*.-** ការទទួលស្គាល់កូនជានីតិជន និង កូនដែលបានទទួលមរណភាព

១-ឪពុកដែលមានបំណងចង់ទទួលស្គាល់កូនដែលជានីតិជន មិនអាចទទួលស្គាល់

បានឡើយ បើគ្មានការយល់ព្រមពីកូននោះ ។

២-ឪពុកអាចទទួលស្គាល់កូនដែលបានទទួលមរណភាពបាន តែក្នុងករណីដែលកូននោះមានបច្ឆាញាតិផ្ទាល់ ។ ក្នុងករណីនេះ បើបច្ឆាញាតិផ្ទាល់នោះជាអនីតិជន ត្រូវទទួលការយល់ព្រមពីជននោះ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៩៩៧ (ទម្រង់នៃការទទួលស្គាល់) ខាងក្រោមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការយល់ព្រមដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ នៃមាត្រានេះ ។

**មាត្រា ៩៩៧.-** ទម្រង់នៃការទទួលស្គាល់

១-ការទទួលស្គាល់ នឹងត្រូវធ្វើឡើងដោយការជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាន ។ ការទទួលស្គាល់ ក៏អាចធ្វើតាមបតកសាសន៍ក៏បានដែរ ។

២-ការយល់ព្រមរបស់ម្ដាយ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៩៩៥ (ការទទួលស្គាល់របស់ឪពុក) ខាងលើនេះ អាចធ្វើបាន ដោយចុះហត្ថលេខាលើលិខិតទទួលស្គាល់នោះ ។

**មាត្រា ៩៩៨.-** អានុភាពនៃការចុះកំណើតនៅក្នុងសៀវភៅកំណើតនិងការទទួលស្គាល់

បើបុគ្គលណាម្នាក់បានសុំចុះកំណើតរបស់កូន បានចុះឈ្មោះខ្លួនជាឪពុក ហើយបានចុះហត្ថលេខា ឬ ផ្ដិតមេដៃ នៅក្នុងសៀវភៅកំណើត បុគ្គលនោះត្រូវចាត់ទុកថា បានទទួលស្គាល់កូននោះ នៅពេលដែលបានសុំចុះកំណើត ។

**មាត្រា ៩៩៩.-** អានុភាពប្រតិសកម្មនៃការទទួលស្គាល់

ការទទួលស្គាល់កូន ត្រូវមានអានុភាពប្រតិសកម្មតាំងពីពេលកំណើតរបស់កូននោះ ។ ប៉ុន្តែ ការទទួលស្គាល់ ពុំអាចបំពានសិទ្ធិដែលតតិយជនបានធ្វើលទ្ធកម្មរួចហើយឡើយ ។

**មាត្រា ១០០០.-** ការហាមឃាត់មិនឱ្យដកការទទួលស្គាល់ចេញ

ឪពុកដែលបានទទួលស្គាល់កូនហើយ ពុំអាចលុបចោលការទទួលស្គាល់នោះបាន

ឡើយ ។

**មាត្រា ១០០១.-** បណ្តឹងទាមទារឱ្យទទួលស្គាល់

១-កូន អាចដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់បាន ។ ប៉ុន្តែ កូនដែលមិនបានយល់ព្រម តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៩៩៦ (ការទទួលស្គាល់កូនជានីតិជន និង កូនដែលបានទទួលមរណភាព) នៃក្រមនេះ ពុំអាចទាមទារឱ្យទទួលស្គាល់បានឡើយ ។

២-ប្រសិនបើកូនបានទទួលមរណភាព បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់បាន ។

៣-កូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់បាន ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ដោយគិតចាប់ពីពេលដែលបានដឹងថាជាឪពុក ។

៤-ក្នុងករណីដែលកូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ ជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ នៅពេលដែលខ្លួនបានដឹងថាជាឪពុក អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវគណនា គិតចាប់ពីពេលដែលកូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ បានក្លាយជានីតិជន ឬ ពេលដែលមានការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ដែលបានកំណត់នៅក្នុងមាត្រា ២៧ (ការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

៥-កូន ឬ បច្ឆាញាតិផ្ទាល់របស់កូន អាចដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់បាន នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃមរណភាពរបស់ឪពុក ប្រសិនបើបានដឹងថាជាឪពុក នៅក្រោយមរណភាពរបស់ឪពុក ។

៦-បណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ អ្នកតំណាងដែលច្បាប់បានកំណត់របស់កូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់ ជំនួសជនទាំងនោះបាន ។

# ឧបសម្ព័ន្ធទី ២៖
# ច្បាប់ស្តីពីអាពាហ៍ពិពាហ៍
# និងគ្រួសារ ឆ្នាំ ១៩៨៩

# ច្បាប់

# ស្តីពី

# អាពាហ៍ពិពាហ៍ និងគ្រួសារ

**រដ្ឋកម្ពុជា**

ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

ក្រុមប្រឹក្សារដ្ឋ

លេខ : ៥៦ ក្រ.

## ក្រឹត្យ

## ក្រុមប្រឹក្សារដ្ឋ

## នៃ

## រដ្ឋកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំរដ្ឋសភា និងក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ក្រ. ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

**សំរេច**

ប្រកាសអោយប្រើច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារដែលរដ្ឋសភានៃរដ្ឋកម្ពុជា បានអនុម័តនៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៨៩ នាសម័យប្រជុំសាមញ្ញលើកទី ១៧ នីតិកាលទី ១ ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩

ជ.ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និង ត្រា : **ហេង សំរិន**

រដ្ឋកម្ពុជា

ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

រដ្ឋសភា

# ច្បាប់

## ស្តីពី

## អាពាហ៍ពិពាហ៍ និង គ្រួសារ

### ជំពូកទី ១

### បទបញ្ញត្តិទូទៅ

**មាត្រា ១.** ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ដោយផ្អែកលើមាត្រា ៧ និងមាត្រា ៨ នៃរដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា មានគោលដៅ ដាក់បទបញ្ជា និង ការរៀបអាពាហ៍ពិពាហ៍ និងគ្រួសារ ធានាសមភាពវាងសហព័ទ្ធ ក្នុងអាពាហ៍ពិពាហ៍ និង ក្នុងជីវភាពគ្រួសារ ពង្រឹងការទទួលខុសត្រូវរបស់ឪពុកម្តាយ ក្នុងការចិញ្ចឹមថែរក្សាកូន និង ជំរុញការបណ្តុះបណ្តាលសីលធម៌ និងការអប់រំ ដើម្បីឱ្យទៅជាពលរដ្ឋល្អ មានមនសិការស្នេហាជាតិ ស្រឡាញ់ការងារ មានសម្បជញ្ញៈទទួលខុសត្រូវចំពោះសង្គម ។

**មាត្រា ២.** ហាមឃាត់ដាច់ខាត នូវអាពាហ៍ពិពាហ៍ដែលគួស្រករនៅក្មេងពេក អាពាហ៍ពិពាហ៍ដោយបង្ខិតបង្ខំ អំពើដែលមានឧបសគ្គដល់សេរីភាពនៃអាពាហ៍ពិពាហ៍ ។

### ជំពូកទី ២

### អំពីអាពាហ៍ពិពាហ៍

### ផ្នែកទី ១

### អំពីលក្ខខណ្ឌដែលត្រូវមានដើម្បីរៀបអាពាហ៍ពិពាហ៍

**មាត្រា ៣.** អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឱឡារិកមួយ ធ្វើឡើងដោយបុរសម្នាក់ និង ស្ត្រីម្នាក់ដែលប្តេជ្ញាថា ខ្លួននិងរួម សមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្ត របស់ខ្លួន ។

អាពាហ៍ពិពាហ៍នឹងមានអានុភាពពេញលក្ខណៈច្បាប់បាន លុះត្រាតែអាពាហ៍ពិពាហ៍នោះធ្វើឡើងស្របតាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់នេះ ។

**មាត្រា ៤.** បុរស និង នារី ដែលមានអាយុពេញលក្ខណៈច្បាប់ មានសិទ្ធិពេញលេញក្នុងការសំរេចអាពាហ៍ពិពាហ៍ ។ ភាគីម្ខាងមិនអាចបង្ខំឆន្ទៈរបស់ភាគីម្ខាងទៀតបានឡើយ ។

គ្មាននរណាមួយអាចបង្ខំបុគ្គលម្នាក់ឱ្យរៀប ឬ រារាំងមិនឱ្យរៀបអាពាហ៍ពិពាហ៍បានឡើយ បើ អាពាហ៍ពិពាហ៍នោះរៀបតាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់នេះ ។

**មាត្រា ៥**~ អាចរៀបអាពាហ៍ពិពាហ៍បាន បុរសចាប់ពីអាយុ ២០ឆ្នាំឡើង នារីចាប់ពីអាយុ ១៨ ឆ្នាំឡើង ។

ក្នុងករណីពិសេស បុរសដែលមានអាយុមិនទាន់ដល់ ២០ ឆ្នាំ និង នារីដែលមានអាយុមិនទាន់ដល់ ១៨ ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍ស្របច្បាប់បាន ប្រសិនបើនារីមានផ្ទៃពោះ ហើយមានការអនុញ្ញាតពីឪពុកម្ដាយ ឬ អ្នកអាណាព្យាបាល ។

**មាត្រា ៦**~ មិនអាចរៀបអាពាហ៍ពិពាហ៍បាន :

-បុគ្គលមានភេទដូចគ្នា

- បុគ្គលគ្មានពលានុភាពនៃលិង្គ

- បុគ្គលមានជម្ងឺឃ្លង់ របេង មហារីក កាមរោគ ដែលមិនទាន់ព្យាបាលបានជាដាច់

- ជនវិកលចរិត ជនមិនដឹងខុសត្រូវ

- បុគ្គលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយ ។

**មាត្រា ៧**~ អាពាហ៍ពិពាហ៍ត្រូវហាមឃាត់ រវាងបុគ្គលដែលជាប់ចំណងញាតិលោហិត ឬ ញាតិពន្ធក្នុងខ្សែផ្ទាល់ គ្រប់ថ្នាក់ទោះចំណងនោះមានខាន់ស្លាក្ដី ឥតមានខាន់ស្លាក្ដី ឬ សាច់ចិញ្ចឹមក្ដី ។

**មាត្រា ៨**~ អាពាហ៍ពិពាហ៍ត្រូវហាមឃាត់ រវាងសាខាញាតិ ទោះសាខាញាតិនោះមានខាន់ស្លាក្ដី ឥតខាន់ស្លាក្ដី សាច់ចិញ្ចឹមក្ដី រួមម្ដាយក្ដី រួមឪពុកក្ដី ជាញាតិលោហិតក្ដី ឬ ជាញាតិពន្ធក្ដី រហូតដល់ថ្នាក់ទី ៣ រាប់ទាំងថ្នាក់ទី ៣ នេះផង ។

ក្នុងករណីពិសេស ប្រសិនបើសហព័ន្ធណាមួយស្លាប់ សហព័ន្ធដែលនៅរស់អាចរៀប អាពាហ៍ពិពាហ៍ ជាមួយ សាខាញាតិពន្ធ ថ្នាក់ទី ២ ឬ ថ្នាក់ទី ៣ បាន ។

**មាត្រា ៩**~ ក្រោយពីអាពាហ៍ពិពាហ៍រលាយដោយមូលហេតុ ប្ដីស្លាប់ មោឃភាពនៃអាពាហ៍ពិពាហ៍ ឬ លែងលះគ្នា នារីអាចរៀបអាពាហ៍ពិពាហ៍ថ្មីមួយទៀតបាន ប៉ុន្តែត្រូវស្ថិតនៅក្នុងវិធវភាព " ភាពមេម៉ាយ " ចំនួន ៣០០ថ្ងៃ គិតពីថ្ងៃដែលប្ដីស្លាប់ ឬ ពីថ្ងៃប្រកាសសាលក្រមដែលសំរេចពីមោឃភាព នៃអាពាហ៍ពិពាហ៍ ឬ ពីថ្ងៃប្រកាសសាលក្រមស្ថាពរនៃការលែងលះ ។ ក្នុងករណីដែលតុលាការប្រជាជនបានចេញដីកាសំរេច ឱ្យប្ដីប្រពន្ធនៅបែកគ្នា នោះសាលក្រមនៃការលែងលះត្រូវគិតវិធវភាពតាំងពីថ្ងៃដែលចេញដីកានេះ ។

ប៉ុន្តែ បើនារីរៀបអាពាហ៍ពិពាហ៍មុនផុត រយៈពេល ៣០០ ថ្ងៃ ប្ដីដែលរៀបអាពាហ៍ពិពាហ៍ថ្មីនេះ ត្រូវចាត់ទុកជា ឪពុករបស់កូនដែលកើតក្នុងអាពាហ៍ពិពាហ៍ថ្មីនេះ លើកលែងតែមានការជំទាស់ពីប្ដី មុន ដោយមានភស្តុតាងច្បាស់លាស់ ។

**មាត្រា ១០.** ក្នុងករណីដែលសហព័ន្ធណាមួយបាត់ខ្លួនកន្លងហួសពីមួយឆ្នាំ គិតពីថ្ងៃដែលបាត់ខ្លួននោះមក ដោយគ្មានដំណឹងអ្វីសោះ ហើយក៏គ្មាននរណាដឹងថា ជននោះស្លាប់ ឬ រស់ សហព័ន្ធម្នាក់ទៀត អាចនឹងរៀបអាពាហ៍ពិពាហ៍ទៀតបាន បើផុតរយៈពេល ១៥ ថ្ងៃ គិតពីថ្ងៃប្រកាសសាលក្រម ដែលបញ្ជាក់ថា ជននោះបានបាត់ខ្លួនពិតមែន ។

ជនណាក៏ដោយ មិនអាចប្ដឹងសុំបដិសេធអាពាហ៍ពិពាហ៍ថ្មីនេះបានឡើយ ទោះបីសហព័ន្ធ ដែល បាត់ខ្លួននោះត្រឡប់មកវិញក៏ដោយ ។

**មាត្រា ១១.** មុនពេលរៀបអាពាហ៍ពិពាហ៍ អនាគតប្ដី ប្រពន្ធ ត្រូវប្ដឹងដល់គណៈកម្មាធិការប្រជាជន ឃុំ ឬ សង្កាត់ខាងលំនៅរបស់នារី ដោយមានឪពុក ឬម្ដាយ ឬអ្នកអាណាព្យាបាលចូលរួមផងក៏ដោយ ។

**មាត្រា ១២.** ប្រធាន ឬ សមាជិកនៃគណៈកម្មាធិការប្រជាជន ឃុំ ឬ សង្កាត់ ក្នុងឋានៈជាមន្ត្រីអត្រានុកូលដ្ឋាន ត្រូវប្រកាសផ្សាយជាសាធារណៈ នូវអាពាហ៍ពិពាហ៍នោះដោយបិទប័ណ្ណប្រកាសនៅលំនៅរបស់នារី និង នៅទីស្នាក់ការឃុំ ឬ សង្កាត់របស់ខ្លួន ។

ប័ណ្ណប្រកាសពីរទៀត ត្រូវផ្ញើទៅជូនមន្ត្រីអត្រានុកូលដ្ឋាន ឃុំ ឬ សង្កាត់ខាងបុរស ដើម្បីយកទៅបិទនៅលំនៅរបស់បុរស និង នៅទីស្នាក់ការឃុំ ឬ សង្កាត់របស់ខ្លួន ។

ប័ណ្ណប្រកាសត្រូវចុះ :

១- ត្រកូល ឈ្មោះ អាយុ មុខរបរ និង លំនៅនៃអនាគតប្ដី និង ប្រពន្ធ ។

២- ប្រកូល ឈ្មោះ អាយុ មុខរបរ និង លំនៅរបស់ឪពុកម្ដាយនៃអនាគតប្ដីប្រពន្ធ " បើឪពុក ឬ ម្ដាយស្លាប់ ត្រូវដាក់ថា ស្លាប់ផង "។

៣- រយៈពេលប្ដឹងជំទាស់ ។

**មាត្រា ១៣.** ប័ណ្ណប្រកាសត្រូវបិទផ្សាយក្នុងរយៈពេល ១០ ថ្ងៃ ដើម្បីឱ្យជនដែលមានផលប្រយោជន៍ក្នុងរឿងនេះដឹងឮ ហើយអាចប្ដឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះបាន ប្រសិនបើមានការមិនយល់ស្របនឹងអាពាហ៍ពិពាហ៍នោះ ។ ផុតរយៈពេល ១០ ថ្ងៃនេះ ពិធីអាពាហ៍ពិពាហ៍អាចធ្វើទៅបាន បើគ្មានការប្ដឹងជំទាស់ ។

**មាត្រា ១៤.** អាពាហ៍ពិពាហ៍ និង ចាត់ទុកជាត្រឹមត្រូវតាមលក្ខណៈច្បាប់បាន លុះត្រាតែបុរស និងនារីដែលស្ម័គ្រចិត្តយកគ្នាជាប្ដីជាប្រពន្ធ ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានខាងលំនៅរបស់នារី ។

កិច្ចសន្យានេះត្រូវចុះក្នុងបញ្ជីអាពាហ៍ពិពាហ៍ ហើយត្រូវចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាន ប្ដីប្រពន្ធ និង សាក្សីគ្រប់អាយុការពីរនាក់ ។

## ផ្នែកទី ២

## អំពីបណ្តឹងទាស់ទារមិនឱ្យរៀបអាពាហ៍ពិពាហ៍

**មាត្រា ១៥**៚ ក្នុងរយៈពេល ១០ថ្ងៃ គិតពីថ្ងៃដែលបិទផ្សាយជាសាធារណៈ ញាតិក្តី ជនដែលមានប្រយោជន៍ក្នុងរឿងនេះក្តី អាចនឹងប្តឹងជំទាស់មិនឱ្យរៀបអាពាហ៍ពិពាហ៍បាន ។

**មាត្រា ១៦**៚ បណ្តឹងទាស់នេះ នឹងយកជាការបាន លុះណាតែអ្នកប្តឹងជំទាស់ចុះហត្ថលេខា លើពាក្យរបស់ខ្លួនដោយផ្ទាល់ដៃខ្លួនឯង ។

បណ្តឹងនេះ ត្រូវចង្អុលពីមូលហេតុនៃការប្តឹងទាស់ ។ មូលហេតុដែលអាចយកមក ប្តឹងជំទាស់បាន នោះ គឺអសមត្ថភាពរបស់បុរស ឬ នារី ឬ មានប្រកាសណាមួយ ដែលច្បាប់ហាមឃាត់ក្នុងមាត្រា ៥ វាក្យខ័ណ្ឌទី ១ មាត្រា ៦ មាត្រា ៧ មាត្រា ៨ នៃច្បាប់នេះ ។

**មាត្រា ១៧**៚ បណ្តឹងទាស់នោះ ត្រូវអ្នកប្តឹងជំទាស់ ឬ តំណាងរបស់ខ្លួនយកទៅជូនគណៈកម្មាធិការប្រជាជនឃុំ ឬ សង្កាត់ខាងលំនៅអនាគតប្រពន្ធ ។ គណៈកម្មាធិការនេះត្រូវសំរេចក្នុងរយៈពេល ៣ ថ្ងៃ គិតពីថ្ងៃទទួលបណ្តឹងទាស់ ។

បើអ្នកប្តឹងជំទាស់ ឬ អនាគតប្តីប្រពន្ធ មិនសុខចិត្តនឹងសេចក្តីសំរេចនេះ គណៈកម្មាធិការប្រជាជនឃុំ ឬ សង្កាត់ ត្រូវបញ្ជូនសំណុំរឿងទៅតុលាការប្រជាជនក្នុងរយៈពេល ៥ ថ្ងៃយ៉ាងយូរ គិតពីថ្ងៃទទួលបណ្តឹងទាស់ ដើម្បីសំរេច ។

**មាត្រា ១៨**៚ តុលាការប្រជាជន ត្រូវសំរេចសេចក្តីពីបណ្តឹងទាស់ក្នុងរយៈពេល ៧ ថ្ងៃយ៉ាងយូរ គិតពីថ្ងៃបានទទួលសំណុំរឿង ។

សាលក្រមរបស់តុលាការប្រជាជន មិនអាចប្តឹងតវ៉ាបានឡើយ ទោះបីសាលក្រមនោះជាសាលក្រមកំបាំងមុខក៏ ដោយ ។

**មាត្រា១៩**៚បើតុលាការប្រជាជនបដិសេធបណ្តឹងទាស់ចោលអនាគតប្តីប្រពន្ធអាចរៀបអាពាហ៍ពិពាហ៍ បាន។

បើតុលាការប្រជាជនចាត់ទុកបណ្តឹងទាស់នោះជាត្រឹមត្រូវមន្ត្រីអត្រានុកូលដ្ឋានត្រូវបញ្ឈប់មិនឱ្យរៀបអាពាហ៍ពិពាហ៍ ។

**មាត្រា ២០**៚ នៅពេលដែលដឹងថា បុរស ឬ នារីជាអសមត្ថជន ឬ មានប្រការណាមួយដែលច្បាប់ហាមឃាត់ដូចមានចែងក្នុងមាត្រា ១៦ មន្ត្រីអត្រានុកូលដ្ឋានមានសិទ្ធិជំទាស់មិនឱ្យរៀបអាពាហ៍ពិពាហ៍ដោយធ្វើរបាយការណ៍ពីបណ្តឹងទាស់នេះ ជូនទៅតុលាការ ប្រជាជនក្នុងរយៈពេល ២ ថ្ងៃយ៉ាងយូរ ដើម្បីសំរេច ។

តុលាការប្រជាជន ត្រូវសំរេចសេចក្តីតាមបទបញ្ញត្តិដែលមានចែងក្នុងមាត្រា ១៨ និង ១០ ខាងលើ ។

## ផ្នែកទី ៣

## អំពីមោឃភាពនៃអាពាហ៍ពិពាហ៍

**មាត្រា ២១.** អាពាហ៍ពិពាហ៍ត្រូវទុកជាមោឃៈ ប្រសិនបើអាពាហ៍ពិពាហ៍នោះ ចុះបញ្ជីនៅពេលដែលសហព័ន្ធណាម្នាក់ឆ្កួត ឬ មិនដឹងខុសត្រូវ ។ តែបើសហព័ន្ធនោះបានជាស្រួលឡើងវិញហើយ ហេតុដែលនាំឱ្យទុកជាមោឃៈនោះត្រូវរលាយទៅវិញដែរ ។

**មាត្រា ២២.** អាពាហ៍ពិពាហ៍រវាងបុរសអាយុតិចជាង ២០ ឆ្នាំ ឬ នារីអាយុតិចជាង ១៨ ឆ្នាំ ត្រូវទុកជាមោឃៈ ។

អាពាហ៍ពិពាហ៍ដែលទុកជាមោឃៈនោះនឹងលែងមោឃៈទៅវិញ កាលបើប្តី ឬ ប្រពន្ធ នោះចំរើនវ័យ ដល់អាយុតាម បញ្ញត្តិច្បាប់ ឬ ក្នុងករណីដែលមានចែងក្នុងមាត្រា ៥ វាក្យខ័ណ្ឌទី ២ ។

**មាត្រា ២៣.** អាពាហ៍ពិពាហ៍ត្រូវទុកជាមោឃៈ កាលបើសហព័ន្ធណាម្នាក់ប្តឹងថា ខ្លួនត្រូវគេចាប់បង្ខំឱ្យរៀបអាពាហ៍ពិពាហ៍

ការប្តឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍ត្រូវផុតអាជ្ញាយុកាល ប្រសិនបើការប្តឹងនោះ មិនធ្វើក្នុង រយៈ ៦ ខែ គិតពីថ្ងៃដែលគេលែងបង្ខំមក ។

**មាត្រា ២៤.** អាពាហ៍ពិពាហ៍ត្រូវទុកជាមោឃៈ បើចំណងអាពាហ៍ពិពាហ៍មុនរបស់សហព័ន្ធណាម្នាក់មិនទាន់រលាយ ។

ការប្តឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍ក្រោយ មិនអាចធ្វើបានឡើយ បើក្រោយពីថ្ងៃចុះអាពាហ៍ពិពាហ៍ក្រោយ នេះមក អាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ។

**មាត្រា ២៥.** អាពាហ៍ពិពាហ៍រវាងញាតិលោហិត ឬ ញាតិព័ន្ធក្នុងថ្នាក់ដែលច្បាប់ហាមឃាត់ ត្រូវទុកជាមោឃៈ លើកលែងតែករណីដែលមានចែងក្នុងមាត្រា ៨ វាក្យខ័ណ្ឌទី ២ ។

ការប្តឹងសុំមោឃភាព នៃអាពាហ៍ពិពាហ៍ខាងលើនេះ មិនអាចផុតអាជ្ញាយុកាលឡើយ ។

**មាត្រា ២៦.** មានតែសហព័ន្ធ រដ្ឋអាជ្ញា និង ជនដែលមានប្រយោជន៍ស្របច្បាប់ក្នុងការប្តឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍ទេ ទើបអាចដាក់ពាក្យប្តឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍ទៅតុលាការប្រជាជនបាន ។

បើជនដែលបានដាក់ពាក្យប្តឹងនោះស្លាប់ សិទ្ធិវន្តអាចប្តឹងជំនួសបាន ។

**មាត្រា ២៧.** កូនកើតអំពីអាពាហ៍ពិពាហ៍ដែលតុលាការបានប្រកាសជាមោឃៈ ត្រូវទុកជាកូនមានខាន់ស្លាទោះបីហេតុដែលនាំឱ្យមានមោឃភាពនោះ យ៉ាងណាក៏ដោយ ។

សិទ្ធិ និង កាតព្វកិច្ចរបស់ឪពុក ម្តាយ និង កូនត្រូវមានដូចគ្នាក្នុងករណីនៃឪពុក ម្តាយលែងលះគ្នា ។

ការចែកទ្រព្យសម្បត្តិរវាង ប្តី ប្រពន្ធ នៃអាពាហ៍ពិពាហ៍ដែលតុលាការប្រកាសជាមោឃៈ ក៏ត្រូវធ្វើដូចក្នុងករណីលែងលះគ្នាដែរ ។

**មាត្រា ២៨**- តុលាការប្រជាជន ត្រូវចាត់ចែងឱ្យចម្លងសេចក្តីវិនិច្ឆ័យ នៃសាលក្រមស្ថាពរដែលប្រកាសមោឃភាពអាពាហ៍ពិពាហ៍ ចុះនៅរឹមទំព័រ នៃសំបុត្រអាពាហ៍ពិពាហ៍ដែលត្រូវទុកជាមោឃៈ ។

## ផ្នែកទី ៤

## សិទ្ធិ និង ករណីយកិច្ចរបស់សហព័ន្ធ

**មាត្រា ២៩**- ក្នុងគ្រួសារ ប្តី ប្រពន្ធ ត្រូវមានភាពស្មើគ្នាលើគ្រប់ទស្សនៈ ។

**មាត្រា ៣០**- ប្តី ប្រពន្ធ មានករណីយកិច្ចស្រឡាញ់គ្នាទៅវិញទៅមក គោរពគ្នាទៅវិញទៅមក ថែរក្សាគ្នា និង ជួយគ្នាទៅវិញទៅមក ដើម្បីឈានទៅកាន់វឌ្ឍនភាពព្រមទាំងកសាងគ្រួសារមួយមានសាមគ្គីភាព និង ប្រកបដោយសុភមង្គល ។

**មាត្រា ៣១**- ប្រពន្ធ ប្តី មានសិទ្ធិជ្រើសដោយសេរីនូវវិជ្ជាជីវៈរបស់ខ្លួន មានសិទ្ធិចូលរួមប្រាស្រ័យដោយសេរីក្នុងសកម្មភាពនយោបាយ វប្បធម៌ និង សង្គម ។

**មាត្រា ៣២**- ប្រពន្ធនិងប្តី មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ការអាស្រ័យផល ការចាត់ចែងទ្រព្យសម្បត្តិរួម ។ សហព័ន្ធម្នាក់ៗ មានសិទ្ធិពេញលេញក្នុងការប្រើប្រាស់ អាស្រ័យផល និង ចាត់ចែងទ្រព្យផ្ទាល់របស់ខ្លួន ។

**មាត្រា ៣៣**- ទ្រព្យសម្បត្តិរួម គឺជាអ្វីៗ ទាំងអស់ដែលសហព័ន្ធទាំងពីរ រកបានជាមួយគ្នា ឬ សហព័ន្ធណាម្នាក់រកបានក្នុងរយៈពេលមានចំណងអាពាហ៍ពិពាហ៍ ។

**មាត្រា ៣៤**- ត្រូវចាត់ទុកជាទ្រព្យសម្បត្តិផ្ទាល់របស់សហព័ន្ធ :

១- ទ្រព្យសម្បត្តិដែលសហព័ន្ធមានមុនរៀបអាពាហ៍ពិពាហ៍ ។

២- ទ្រព្យសម្បត្តិដែលសហព័ន្ធបានទទួលជាអំណោយជាមតិក ឬ ជាបច្ច័យទានក្នុងរយៈពេលមានចំណងអាពាហ៍ពិពាហ៍ ។

**មាត្រា ៣៥**- ត្រូវធ្លាក់លើបន្ទុកទ្រព្យសម្បត្តិរួម :

១- ការផ្គត់ផ្គង់គ្រួសារ និង ចំណាយដើម្បីអប់រំ និង បណ្តុះបណ្តាលកូន ។

២- បំណុល និង កាតព្វកិច្ចទាំងឡាយ ដែលសហព័ន្ធទាំងពីបានព្រមព្រៀងគ្នាសំរេច ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ឬ ដែលសហព័ន្ធណាម្នាក់សំរេចក្នុងរយៈពេលមានចំណង អាពាហ៍ពិពាហ៍ដោយមានការយល់ព្រមពីសហព័ន្ធម្នាក់ទៀត ។

៣- ការថែទាំ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរួម ។

**មាត្រា ៣៦**- សហព័ន្ធម្នាក់ៗ អាចប្រើប្រាស់សម្ភារៈដែលជាទ្រព្យសម្បត្តិរួម តាមការតម្រូវនៃសម្ភារៈនោះ ។ សហព័ន្ធទាំងពីរនាក់ត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរួមជាមួយគ្នា ។ សហព័ន្ធម្នាក់អាចទាមទារឱ្យសហព័ន្ធម្នាក់ទៀតយល់ព្រមលើវិធានការចាំបាច់ដើម្បីថែទាំទ្រព្យសម្បត្តិរួម ឬ រក្សាទុកតម្លៃរបស់ទ្រព្យសម្បត្តិនោះ ។

**មាត្រា ៣៧**- ទ្រព្យសម្បត្តិរួមអាចលក់ដូរឬធ្វើអំណោយបាន លុះត្រាតែមានការព្រមព្រៀងពីសហព័ន្ធទាំងពីរ ។

## ជំពូកទី ៣
## អំពីការលែងលះគ្នា
### ផ្នែកទី ១
### អំពីមូលហេតុនៃការលែងលះគ្នា

**មាត្រា ៣៨.** ការលែងលះគ្នា គឺការផ្តាច់ចំណងអាពាហ៍ពិពាហ៍របស់ប្តីប្រពន្ធ ដែលបានរៀបការពេញច្បាប់ ក្នុងពេលរស់នៅទាំងពីរនាក់ ។

**មាត្រា ៣៩.** ប្តី ឬ ប្រពន្ធ អាចប្តឹងសុំលែងលះគ្នាបាន កាលបើមានមូលហេតុគ្រប់គ្រាន់ បញ្ជាក់ថា ខ្លួនពុំអាចរួមរស់ជាមួយគ្នាតទៅទៀតបាន ។

មូលហេតុជាអាទិមានដូចខាងក្រោមនេះ :

១- ការចុះចោលលំនៅសង្វាស ដោយឥតមូលហេតុត្រឹមត្រូវ ហើយឥតមានផ្គត់ផ្គង់ស្បៀងអាហារ និង ទំនុកបំរុងកូនសោះ ។

២- វាយដំឃោរឃៅ ធ្វើទុក្ខបុកម្នេញប្រមាថមើលងាយធ្ងន់ធ្ងរ ចំពោះសហព័ន្ធ ឬ ចំពោះបុព្ពញាតិរបស់សហព័ន្ធនេះ ។

៣- មានចរិយាផ្ទុយពីសីលធម៌ ឬ ប្រព្រឹត្តអនាចារ ។

៤- អពលានុភាពនៃលិង្គ ។

៥- បែកគ្នាអស់រយៈពេលជាង ១ ឆ្នាំ

**មាត្រា ៤០.** ប្តីប្រពន្ធ អាចលែងលះគ្នាដោយស្ម័គ្រចិត្តបាន ។

### ផ្នែកទី ២
### អំពីនីតិវិធី នៃ ការលែងលះគ្នា

**មាត្រា ៤១.** ការសំរេចអំពីការលែងលះគ្នា ជាសមត្ថកិច្ចរបស់តុលាការប្រជាជនខេត្ត-ក្រុង ខាងលំនៅរបស់ចុងចម្លើយ ។

**មាត្រា ៤២.** បណ្តឹងលែងលះគ្នា ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ចុះមូលហេតុនាំឱ្យលែងលះគ្នា ។

បណ្តឹងនោះត្រូវដើមចោទយកទៅជូនតុលាការប្រជាជនខេត្ត-ក្រុងផ្ទាល់ក៏បាន ឬជូនគណៈកម្មាធិការប្រជាជន ឃុំ ឬសង្កាត់ខាងលំនៅរបស់ចុងចម្លើយ ដោយខ្លួនឯងផ្ទាល់ក៏បាន ។

ក្នុងករណីខាងក្រោមនេះ គណៈកម្មាធិការប្រជាជនឃុំ ឬសង្កាត់ត្រូវធ្វើការផ្សះផ្សាក្នុងរយៈ១៥ថ្ងៃ ក្រោយពីបានទទួលពាក្យបណ្តឹង ។ បើផ្សះផ្សាពុំបានសម្រេច ត្រូវបញ្ជូនសំណុំរឿងជាបន្ទាន់ទៅតុលាការប្រជាជនខេត្ត-ក្រុង ។

**មាត្រា ៤៣.** តុលាការប្រជាជនខេត្ត-ក្រុង ត្រូវអញ្ជើញអ្នកប្ដឹងឱ្យចូលមក ហើយសំរួលយ៉ាណាតាមដែលខ្លួនយល់ឃើញ ដើម្បីបញ្ចូលចិត្តអ្នកនោះឱ្យឈប់ប្ដឹង លើកលែងតែតុលាការប្រជាជនខេត្ត-ក្រុងយល់ឃើញថា ពាក្យសុំលែងលះគ្នានេះមានអាចហេតុធ្ងន់ធ្ងរណាស់ ។

**មាត្រា ៤៤.** ក្រោយពីពេលបានទទួលបណ្ដឹងសុំលែងលះ បើយល់ឃើញថា ការចាំបាច់ តុលាការប្រជាជនខេត្ត-ក្រុងអាចចាត់វិធានការបណ្ដោះអាសន្នបាន ដូចជាការបំបែកលំនៅប្ដី ប្រពន្ធ ការឱ្យថែរក្សា ថែរក្សាទ្រព្យសម្បត្តិ ការផ្ដល់អាហារកិច្ច ។ ក្នុងករណីនេះ មេធាវីនៃគូភាគីអាចចូលរួមស្ដាប់បាន ។

**មាត្រា ៤៥.** ប្រសិនបើដើមចោទនៅតែទទូចសុំលែង តុលាការប្រជាជនខេត្ត-ក្រុង ត្រូវអញ្ជើញប្ដី ប្រពន្ធអោយមកកាន់តុលាការជាប្រញាប់ ដើម្បីធ្វើការផ្សះផ្សា ។ ក្នុងករណីនេះ មេធាវីមិនត្រូវចូលរួមស្ដាប់ទេ ។

**មាត្រា ៤៦.** ប្រសិនបើផ្សះផ្សាចំពោះមុខដើមចោទ និងចុងចម្លើយហើយនៅតែពុំបានសំរេច តុលាការប្រជាជនខេត្ត-ក្រុង អាចធ្វើការផ្សះផ្សាជាលើកទី ២ បាន ។

**មាត្រា ៤៧.** ប្រសិនបើនៅពេលផ្សះផ្សាលើកទី ១ ដើមចោទ ឬ ចុងចម្លើយ ដែលបានទទួលដីកាអញ្ជើញដោយត្រឹមត្រូវ ហើយមិនមកបង្ហាញខ្លួនតាមការអញ្ជើញនោះ តុលាការប្រជាជនខេត្ត-ក្រុងត្រូវអញ្ជើញភាគីទាំងពីរនោះជាលើកទី ២ ដើម្បីធ្វើការផ្សះផ្សា ។

**មាត្រា ៤៨.** ប្រសិនបើដើមចោទ ដែលបានទទួលដីកាអញ្ជើញដោយត្រឹមត្រូវ ហើយមិនបានមកកាន់តុលាការ ប្រជាជនខេត្ត-ក្រុង ទាំងលើកទី ១ ទាំងលើកទី ២ ដោយគ្មានមូលហេតុនោះត្រូវចាត់ទុកថា សុខចិត្តឈប់ប្ដឹង ។

**មាត្រា ៤៩.** ប្រសិនបើចុងចម្លើយ បានទទួលដីកាអញ្ជើញត្រឹមត្រូវ ហើយនៅតែមិនព្រមចូលមកកាន់តុលាការប្រជាជនខេត្ត-ក្រុង ទាំងលើកទី ១ ទាំងលើកទី ២ ដោយគ្មានមូលហេតុ នោះត្រូវចាត់ទុកថា មិនព្រមសះជានឹងគ្នា ។

**មាត្រា ៥០.** ប្រសិនបើអ្នកមិនបានមកតាមដីកាអញ្ជើញលើកទី ១ មិនមែនជាអ្នកមិនបានមកលើកទី ២ទេ តុលាការប្រជាជនខេត្ត-ក្រុង ត្រូវអញ្ជើញភាគីនោះមកផ្សះផ្សាយជាលើកទី ៣ ។

**មាត្រា ៥១.** ការផ្សះផ្សាម្ដងៗ ត្រូវឱ្យឃ្លាតពីគ្នា ១ ខែ យ៉ាងឆាប់ និង ២ ខែយ៉ាងយូរ ។

**មាត្រា ៥២.** ក្នុងការផ្សះផ្សាម្ដងៗ ទោះបីបានលទ្ធផលយ៉ាងណាក្ដី ត្រូវចុះក្នុងកំណត់ហេតុបញ្ជាក់អំពីការផ្សះផ្សាបានសំរេច មិនបានសំរេច ឬ ភាគីមិនបានចូល ហើយចៅក្រមទទួលបន្ទុកការផ្សះផ្សាត្រូវ ចុះហត្ថលេខា លើកំណត់ហេតុនោះជាមួយភាគីវត្តមាន និង លេខាធិការក្រឡាបញ្ជី ។

**មាត្រា ៥៣.** បើការផ្សះផ្សាមិនបានសំរេច តុលារការប្រជាជនខេត្ត-ក្រុង ត្រូវអញ្ជើញប្តី ប្រពន្ធឱ្យចូលមកកាន់តុលាការប្រជាជន ដើម្បីជំនុំជំរះ ។

**មាត្រា ៥៤.** ប្រសិនបើដើមចោទ ត្រូវបានតុលាការប្រជាជនអញ្ជើញដោយត្រឹមត្រូវ ហើយមិនបានមកបង្ហាញខ្លួន ចំពោះតុលាការប្រជាជន និងមិនបានជូនសេចក្តីដោះសា ឬ មិនបានសុំឱ្យបង្អង់កាត់សេចក្តីទៅថ្ងៃក្រោយទេនោះ ត្រូវចាត់ទុកថា សុខចិត្តឈប់ប្តឹងវិញហើយ ។

ក្នុងករណីនេះ ត្រូវចេញសាលក្រមចំណាយរឿងក្តីនោះចោល ។

**មាត្រា ៥៥.** ប្រសិនបើចុងចម្លើយ មិនបានចូលមកកាន់តុលាការប្រជាជន ក្នុងល័ក្ខខ័ណ្ឌដូចខាងលើនេះដែរ ហើយបើយល់ឃើញថាហេតុដែលដើមចោទប្តឹងនោះមានភស្តុតាងពិតប្រាកដហើយ តុលាការប្រជាជនអាចសំរេចសេចក្តីឱ្យលែងលះគ្នាបាន។ បើបណ្តឹងនោះមិនទាន់មានភស្តុតាងគ្រប់គ្រាន់ ទេ តុលាការប្រជាជនត្រូវធ្វើការអង្កេតស៊ើបសួរអំពីរឿងនោះ ។

**មាត្រា ៥៦.** បើចុងចម្លើយប្រកែកថា សេចក្តីដែលប្តឹងពីខ្លួននោះមិនពិតទេ តុលាការប្រជាជនត្រូវបញ្ជាឱ្យធ្វើការអង្កេតស៊ើបសួរ ។

**មាត្រា ៥៧.** ក្នុងរឿងលែងលះគ្នា បើមានការត្រូវអង្កេតស៊ើបសួរ តុលាការប្រជាជនត្រូវធ្វើការអង្កេតស៊ើបសួរជាបន្ទាន់ ត្រូវបង្គាប់ឱ្យគូភាគី ជូនភស្តុតាងចាំបាច់នានាអញ្ជើញសាក្សីដែលមានប្រយោជន៍ក្នុងរឿងនេះ និង ចាត់វិធានការទូទៅ បើយល់ឃើញថា គួរចាត់ ។

**មាត្រា ៥៨.** ក្នុងករណីសុំលែងលះដោយព្រមព្រៀងគ្នា បើក្រោយពីការអង្កេតស៊ើបសួរឃើញថា ការសុំលែងលះគ្នានោះធ្វើដោយគ្មានការបង្ខិតបង្ខំ និង ដោយស្ម័គ្រចិត្តពិតប្រាកដ តុលាការប្រជាជនត្រូវសំរេចអោយលែងលះគ្នា ។

**មាត្រា ៥៩.** ក្នុងករណីសុំលែងលះដោយឯកតោភាគី បើក្រោយពីការអង្កេតស៊ើបសួរឃើញថា ស្ថានភាពរវាងប្តី ប្រពន្ធ មានភាពធ្ងន់ធ្ងរ ការរួមរស់ជាមួយគ្នាមិនអាចពន្យាយូរបាន គោលបំណងអាពាហ៍ពិពាហ៍លែងបានសំរេច តុលាការប្រជាជនត្រូវសំរេចឱ្យលែងលះគ្នា ។

**មាត្រា ៦០.** តុលាការប្រជាជនអាចធ្វើការស៊ើបសួរ និង ធ្វើការជំនុំជំរះដោយសម្ងាត់បាន ។

**មាត្រា ៦១.** ការវិនិច្ឆ័យដល់អង្គសេចក្តី ត្រូវតែធ្វើក្នុងរយៈ ១៥ ថ្ងៃ គិតពីថ្ងៃអង្កេតស៊ើបសួររួចមក ។

**មាត្រា ៦២.** តាមគោលការណ៍ សាលក្រមលែងលះគ្នាត្រូវសំរេចចំពោះមុខគូក្តី ។ ប្រសិនបើសាលក្រមនោះជាសាលក្រមកំបាំងមុខ គូក្តីអាចប្តឹងទាស់បាន ក្នុងរយៈ ១៥ ថ្ងៃ ។ រយៈពេលនេះគិតពីថ្ងៃដែលឱ្យដំណឹងពីសាលក្រមកំបាំងមុខដល់គូក្តីផ្ទាល់ ឬ ដល់លំនៅរបស់គូក្តី ។

**មាត្រា ៦៣.** បណ្តឹងទាស់និងសាលក្រមកំបាំងមុខ ត្រូវធ្វើដោយសាមីខ្លួន ជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់នៅតុលាការប្រជាជនខេត្ត ក្រុង ។ បណ្តឹងទាស់នាំឱ្យផ្អាកការអនុវត្តន៍សាលក្រម ។

**មាត្រា ៦៤.** ប្រសិនបើផុតរយៈពេលប្ដឹងទាស់ សាលក្រមកំបាំងមុខនឹងទៅជាសាលក្រមស្ថាពរ ។

**មាត្រា ៦៥.** ប្រសិនបើអ្នកប្ដឹងទាស់ បានប្ដឹងក្នុងរយៈពេលកំណត់ ប៉ុន្តែមិនបានចូលខ្លួនមកក្នុងពេលជំនុំជំរះ ដោយគ្មានមូលហេតុ នោះសាលក្រមកំបាំងមុខត្រូវតំកល់ជាបានការ និង ទៅជាសាលក្រមស្ថាពរ ។

**មាត្រា ៦៦.** ប្រសិនបើបណ្ដឹងជំទាស់ត្រឹមត្រូវតាមទម្រង់ច្បាប់តុលាការប្រជាជនខេត្ត-ក្រុង ត្រូវពិនិត្យ និង ជំនុំជំរះសាជាថ្មីលើអង្គសេចក្ដី ។

តុលាការប្រជាជនអាចតំកល់ កែប្រែ ឬ បដិសេធសាលក្រមកំបាំងមុខ ដែលបានសំរេចសេចក្ដី លើកមុនបាន កុំឱ្យតែបំពានលើច្បាប់ ឬ គោលការណ៍នៃច្បាប់ ។

**មាត្រា ៦៧.** កាលបើសាលក្រមលែងលះជាសាលក្រមស្ថាពរ តុលាការប្រជាជនខេត្ត-ក្រុង ត្រូវចាត់ចែងឱ្យចម្លងសេចក្ដីនៃសាលក្រមស្ថាពរនោះ ចុះទៅរឹមទំព័រនៃសំបុត្រអាពាហ៍ពិពាហ៍ដែលត្រូវរលាយ ។

**មាត្រា ៦៨.** ប្រសិនបើប្រពន្ធមានផ្ទៃពោះ ប្ដីអាចនឹងសុំលែងលះបាន លុះត្រាតែប្រពន្ធនោះសំរាលកូនរួចបាន ១ឆ្នាំសិន ។

ការបន្ថយសិទ្ធិខាងលើមិនត្រូវអនុវត្តលើនារីទេ ។ នារីអាចសុំលែងលះបាននៅពេលមានផ្ទៃពោះ ។

## ផ្នែកទី ៣
## អំពីអនុភាពនៃការលែងលះគ្នា

**មាត្រា ៦៩.** ការលែងលះគ្នារំសាយអនុភាពអាពាហ៍ពិពាហ៍ ចាប់តាំងពីថ្ងៃដែលការលែងលះគ្នានោះ ទៅជាស្ថាពរ ។

**មាត្រា ៧០.** ក្នុងករណីនៃការលែងលះគ្នា ទ្រព្យសម្បត្តិត្រូវបែងចែកទៅតាមការព្រមព្រៀងនៃភាគីទាំងសងខាង ។ បើគ្មានការព្រមព្រៀង សហព័ន្ធម្នាក់ៗត្រូវយកតែទ្រព្យសម្បត្តិផ្ទាល់ខ្លួនដែលមានមុនរៀបអាពាហ៍ពិពាហ៍ និង ទ្រព្យសម្បត្តិដែលខ្លួនបានទទួលជាមត៌កក្ដី ជាអំណោយក្ដី ជាអច្ច័យទានក្ដី ក្នុងរយៈមានចំណងអាពាហ៍ពិពាហ៍ប៉ុណ្ណោះ ។

ក្រៅពីនេះ សហព័ន្ធម្នាក់ៗ មានសិទ្ធិត្រូវបានទ្រព្យសម្បត្តិរួមពាក់កណ្ដាលម្នាក់ ។

ប៉ុន្តែក្នុងករណីពិសេស និង តាមសំណើរបស់សហព័ន្ធណាមួយ តុលាការប្រជាជនអាចសំរេចសេចក្ដីចែកទ្រព្យសម្បត្តិរួម ផ្សេងពីគោលការណ៍ខាងលើបាន ដោយគិតទៅដល់ផលប្រយោជន៍របស់កូន និង ផលិតកម្ម ។

ការងារនៃគេហកិច្ច ត្រូវចាត់ទុកជាមានតម្លៃស្មើនឹងការងារផលិតកម្ម ។

**មាត្រា ៧១៉** ប្រសិនបើទ្រព្យសម្បត្តិផ្ទាល់របស់សហព័ន្ធម្នាក់ត្រូវសហព័ន្ធម្នាក់ទៀតបំផ្លាញ សហព័ន្ធនេះត្រូវតែសងតម្លៃ ទ្រព្យនោះវិញ ។

**មាត្រា ៧២៉** សាលក្រមដែលកាត់ឱ្យប្ដីប្រពន្ធលែងលះគ្នានោះ ត្រូវសំរេចអំពីអំណាចមេបា ដែលត្រូវប្រគល់ឱ្យទៅឪពុក ឬ ទៅម្ដាយ ហើយនិងត្រូវសំរេចអំពីការប្រាស្រ័យទាក់ទងរវាងឪពុក ម្ដាយ និង កូននោះផង ។

**មាត្រា ៧៣៉** ដើម្បីផលប្រយោជន៍របស់កូន ការឱ្យភាគីណាមួយរក្សាកូន ត្រូវសំរេចតាមការយល់ព្រមនៃប្ដីប្រពន្ធដែលលែងលះគ្នានោះ ។ តាមគោលការណ៍កូនដែលនៅបៅដោះត្រូវឱ្យទៅម្ដាយរក្សា ។

ក្នុងករណីដែលគូភាគីទាំងសងខាង មិនឯកភាពគ្នាលើការរក្សាកូន តុលាការប្រជាជនត្រូវសំរេច ។

**មាត្រា ៧៤៉** ឪពុក ឬ ម្ដាយដែលលែងលះគ្នា ត្រូវជួយផ្គត់ផ្គង់ ជួយបីបាច់រក្សា ជួយផ្ដល់សោហ៊ុយ អប់រំ និងរៀនសូត្រដល់កូន តាមលទ្ធភាពរបស់ខ្លួន ។

កម្រិតអាហារកិច្ចដែលត្រូវឱ្យទៅកូន ត្រូវសំរេចតាមការព្រមព្រៀងនៃសហព័ន្ធដែលលែងលះគ្នា ។

ក្នុងករណីដែលគូភាគីទាំងសងខាង មិនឯកភាពគ្នា តុលាការប្រជាជនត្រូវសំរេច ដោយផ្អែកទៅតាមលទ្ធភាពរបស់សហព័ន្ធម្នាក់ៗ ។

អាហារកិច្ចត្រូវផ្ដល់ឱ្យកូនរហូត ដល់កូនមាននីតិភាព ។

**មាត្រា ៧៥៉** ភាគីដែលមិនបានរក្សាកូន មានសិទ្ធិទៅសួរសុខទុក្ខកូន ។ ភាគីដែលទទួលសិទ្ធិរក្សាកូនត្រូវបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់ភាគីម្ខាងទៀត ។

ភាគីដែលមិនបានរក្សាកូន មានសិទ្ធិប្ដឹងទៅតុលាការប្រជាជនគ្រប់ពេលវេលា ឱ្យដកសិទ្ធិរក្សាកូនពីភាគីម្ខាងនោះបាន បើមានការប៉ះពាល់ដល់ផលប្រយោជន៍របស់កូន ។

**មាត្រា ៧៦៉** ក្នុងករណីលែងលះគ្នា ភាគីដែលគ្មានកំហុសហើយខ្វះខាត អាចស្នើសុំអាហារកិច្ចពីភាគីម្ខាងទៀតបាន ។ ភាគីខាងក្រោយនេះ ត្រូវតែជួយឧត្ថម្ភទៅតាមលទ្ធភាពរបស់ខ្លួន ។

កំរិតអាហារកិច្ចត្រូវសំរេចតាមការយល់ព្រមរបស់គូភាគីទាំងសងខាង ។

ក្នុងករណីដែលគូភាគីទាំងសងខាង មិនឯកភាពគ្នា តុលាការប្រជាជនត្រូវសំរេចសេចក្ដី ។

បើជនដែលទទួលអាហារកិច្ចរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ជននោះឈប់មានសិទ្ធិទទួលអាហារកិច្ចទៀតហើយ ។

**មាត្រា ៧៧.** តុលាការប្រជាជនខេត្ត-ក្រុង អាចកែប្រែដោយបង្កើន ឬ បន្ថយកំរិតអាហារកិច្ចបាន បើមានសំណូមពររបស់ភាគីម្ខាង ។ ការបង្កើន ឬ បន្ថយកកម្រិតអាហារកិច្ចនោះ ត្រូវធ្វើឡើងតាមលទ្ធភាពនៃភាគីដែលផ្តល់អាហារកិច្ច និង តាមសេចក្តីត្រូវការនៃភាគីដែលទទួលអាហារកិច្ច ។

អាហារកិច្ចអាចផ្តល់ឱ្យជាទឹកប្រាក់ ឬ ជារបស់ ។

**មាត្រា ៧៨.** ការមិនព្រមបង់អាហារកិច្ចដូចបានចែងខាងលើនេះ ចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ ដែលនឹងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន បើកាលណាមានភស្តុតាង បញ្ជាក់ថា ជនដែលត្រូវផ្តល់អាហារកិច្ចនោះ មិនស្មោះត្រង់ ។

# តារាងនៃថ្នាក់ញាតិភាព
# (TABLEAU DES DEGRÉS DE LA PARENTÉ)



ចំពោះខ្សែផ្ទាល់ ក៏ដូចជាសាខាញាតិ សុទ្ធតែមានញាតិលោហិត និង ញាតិពន្ធ ។

ញាតិលោហិត : ញាតិដែលមានឈាមជាមួយគ្នា ។

ញាតិពន្ធ : សាច់ថ្លៃ (បងថ្លៃ ប្អូនថ្លៃ ឪពុក-ម្តាយក្មេក និង កូនប្រសា ជីតា ជីដូនក្មេក និង ចៅប្រសា) ។

សាខាញាតិ : ញាតិដែលចែកចេញជា មែកធាងពីអ្នកបង្កើតរួមដូចជាមីងមា ក្មួយ បងប្អូនបង្កើត បងប្អូនជីដូនមួយ ។

បងប្អូនបង្កើត : កូនដែលកើតពីឪពុក-ម្តាយជាមួយគ្នា គឺរួមឪពុក-ម្តាយ ឬ រួមតែឪពុក គឺឪពុកជាមួយគ្នា ម្តាយទីទៃ ឬ ក៏រួមតែម្តាយ គឺម្តាយជាមួយគ្នា ឪពុកទីទៃ ។

## ជំពូកទី ៤

## អំពីអាពាហ៍ពិពាហ៍នៅបរទេស និង
## អាពាហ៍ពិពាហ៍ជាមួយបរទេស

### ផ្នែកទី ១

### អំពីអាពាហ៍ពិពាហ៍

**មាត្រា ៧៩.** អាពាហ៍ពិពាហ៍រវាងពលរដ្ឋកម្ពុជា និង ពលរដ្ឋកម្ពុជា ឬ រវាងពលរដ្ឋកម្ពុជា និង ជនបរទេស ដែលរស់នៅឯបរទេស ត្រូវប្រព្រឹត្តទៅនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នៃស្ថានទូត ឬ ស្ថានកុងស៊ុល នៃរដ្ឋកម្ពុជាប្រចាំនៅប្រទេសដែលគូភាគីមានទីលំនៅ ។

ក្នុងករណីដែលអាពាហ៍ពិពាហ៍ រវាងពលរដ្ឋកម្ពុជា និង ពលរដ្ឋកម្ពុជា និង អាពាហ៍ពិពាហ៍ រវាងពលរដ្ឋកម្ពុជា និង ជនបរទេស បានប្រព្រឹត្តទៅត្រឹមត្រូវតាមទំរង់នៃអាពាហ៍ពិពាហ៍ ដែលមានចែងក្នុងច្បាប់ នៃកន្លែងរៀបអាពាហ៍ពិពាហ៍នោះ ត្រូវបានទទួលស្គាល់យកជាការបាននៅរដ្ឋកម្ពុជា ប្រសិនបើអាពាហ៍ពិពាហ៍នោះមិនផ្ទុយនឹងបទបញ្ញត្តិច្បាប់នៃរដ្ឋកម្ពុជា ។

លិខិតបញ្ជាក់អាពាហ៍ពិពាហ៍ ឬ សេចក្តីចម្លងលិខិតអាពាហ៍ពិពាហ៍នេះ ត្រូវយកមកចុះក្នុងបញ្ជីអាពាហ៍ពិពាហ៍នៃស្ថានទូត ឬស្ថានកុងស៊ុលនៃរដ្ឋកម្ពុជា ឬគូស្វាមីភរិយាមកតាំងទីលំនៅ១រដ្ឋកម្ពុជា ត្រូវយកមកចុះក្នុងបញ្ជីអាពាហ៍ពិពាហ៍នៅឃុំ ឬ សង្កាត់ ដែលមកតាំងទីលំនៅនោះ ។

**មាត្រា ៨០.** អាពាហ៍ពិពាហ៍រវាងពលរដ្ឋកម្ពុជា និង ជនបរទេសនៅរដ្ឋកម្ពុជា ត្រូវប្រព្រឹត្តទៅតាមច្បាប់នៃរដ្ឋកម្ពុជា ។

## ផ្នែកទី ២

## អំពីការរំលាយអាពាហ៍ពិពាហ៍

**មាត្រា ៨១.** ការរំលាយអាពាហ៍ពិពាហ៍ ដែលធ្វើនៅឯបរទេសរវាងពលរដ្ឋកម្ពុជា និង ពលរដ្ឋកម្ពុជា ឬ រវាងពលរដ្ឋកម្ពុជា និង ជនបរទេស ដែលរស់នៅឯបរទេស ត្រូវបានទទួលស្គាល់យកជាការបាននៅរដ្ឋកម្ពុជា ។

- ការរំលាយអាពាហ៍ពិពាហ៍រវាងពលរដ្ឋកម្ពុជា និងជនបរទេស ឬ ការរំលាយអាពាហ៍ពិពាហ៍រវាងជនបរទេស និងជនបរទេសនៅរដ្ឋកម្ពុជាត្រូវធ្វើតាមច្បាប់នៃរដ្ឋកម្ពុជា ។
- តុលាការប្រជាជននៃរដ្ឋកម្ពុជា មានសមត្ថកិច្ចសំរេចលើបណ្តឹងសុំរំលាយអាពាហ៍ពិពាហ៍ របស់សហព័ន្ធណាមួយដែលចូលមកតាំងទីលំនៅៗរដ្ឋកម្ពុជា ។

## ជំពូកទី ៥

## អំពីគ្រួសារ

## ផ្នែកទី ១

## អំពីកូនមានខាន់ស្លា

**មាត្រា ៨២.** កូន នឹងទុកជាកូនមានខាន់ស្លា លុះត្រាតែកូននោះកើតមកពីឪពុកម្តាយ ដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា និង លុះត្រាតែម្តាយនៃកូននោះមានគភ៌ក្នុងរយៈពេល ដែលឪពុកម្តាយនៅជាប់ចំណងអាពាហ៍ពិពាហ៍នឹងគ្នា បានន័យថា កូនដែលកើត ១៨០ ថ្ងៃយ៉ាងតិចក្រោយថ្ងៃរៀបអាពាហ៍ពិពាហ៍ ឬ ក្នុងរយៈពេល ៣០០ ថ្ងៃ គិតពីថ្ងៃដាច់ចំណងអាពាហ៍ពិពាហ៍ ។

**មាត្រា ៨៣.** កូនដែលកើតក្នុងរយៈវេលាតិចជាង ១៨០ ថ្ងៃ គិតពីថ្ងៃរៀបអាពាហ៍ពិពាហ៍ និងទុកថា កូនរបស់ប្តីនៃម្តាយបាន កាលបើមានភស្តុតាងច្បាស់ថា ប្តីនេះបានដឹងថា ប្រពន្ធរបស់ខ្លួនមានផ្ទៃពោះតាំងពីមុនរៀបអាពាហ៍ពិពាហ៍មកម៉្លេះ ឬ ក៏ព្រមទទួលស្គាល់ថា ខ្លួនជាឪពុករបស់កូននោះ ។ បើមិនដូច្នេះទេ ប្តីរបស់ម្តាយនៃកូននោះអាចបដិសេធថា ខ្លួនមិនមែនជាឪពុករបស់កូននោះបាន ដោយមិនចាំបាច់បង្ហាញភស្តុតាងថាខ្លួនមិនមែនជាឪពុក ។

**មាត្រា ៨៤.** កូនដែលកើតក្នុងល័ក្ខខ័ណ្ឌ នៃពេលដែលមានចែងក្នុងមាត្រា៨២ ជាភស្តុតាងយ៉ាងមាំ តម្រូវឱ្យសន្មត់ថា ប្តីនៃម្តាយគឺពិតជាឪពុករបស់កូននោះ ។ ប្តីនៃម្តាយអាចមិនទទួលស្គាល់ថា កូននោះជាកូនរបស់ខ្លួនបាន លុះណាតែប្តីនោះប្តឹងបដិសេធបិតុភាព ។

**មាត្រា ៨៥.** ការប្តឹងប្រកែកមិនទទួលស្គាល់បិតុភាព ត្រូវប្តីប្តឹងពីម្តាយ និង ពីកូន ចំពោះមុខតុលាការប្រជាជនខាងលំនៅនៃម្តាយក្នុងរយៈពេល ២ ខែ គិតពីថ្ងៃដែលខ្លួនបានដឹងពីកំណើតនៃកូននោះ ។

## ផ្នែកទី ២

## អំពីការរំលាយអាពាហ៍ពិពាហ៍

**មាត្រា ៨១.** ការរំលាយអាពាហ៍ពិពាហ៍ ដែលធ្វើនៅឯបរទេសរវាងពលរដ្ឋកម្ពុជា និង ពលរដ្ឋកម្ពុជា ឬ រវាងពលរដ្ឋកម្ពុជា និង ជនបរទេស ដែលរស់នៅឯបរទេស ត្រូវបានទទួលស្គាល់យកជាការបាននៅរដ្ឋកម្ពុជា ។

- ការរំលាយអាពាហ៍ពិពាហ៍រវាងពលរដ្ឋកម្ពុជា និងជនបរទេស ឬ ការរំលាយអាពាហ៍ពិពាហ៍រវាងជនបរទេស និងជនបរទេសនៅរដ្ឋកម្ពុជាត្រូវធ្វើតាមច្បាប់នៃរដ្ឋកម្ពុជា ។

- តុលាការប្រជាជននៃរដ្ឋកម្ពុជា មានសមត្ថកិច្ចសំរេចលើបណ្តឹងសុំរំលាយអាពាហ៍ពិពាហ៍ របស់សហព័ន្ធណាមួយដែលចូលមកតាំងទីលំនៅៗរដ្ឋកម្ពុជា ។

## ជំពូកទី ៥

## អំពីគ្រួសារ

## ផ្នែកទី ១

## អំពីកូនមានខាន់ស្លា

**មាត្រា ៨២.** កូន នឹងទុកជាកូនមានខាន់ស្លា លុះត្រាតែកូននោះកើតមកពីឪពុកម្តាយ ដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា និង លុះត្រាតែម្តាយនៃកូននោះមានគភ៌ក្នុងរយៈពេល ដែលឪពុកម្តាយនៅជាប់ចំណងអាពាហ៍ពិពាហ៍នឹងគ្នា បានន័យថា កូនដែលកើត ១៨០ ថ្ងៃយ៉ាងតិចក្រោយថ្ងៃរៀបអាពាហ៍ពិពាហ៍ ឬ ក្នុងរយៈពេល ៣០០ ថ្ងៃ គិតពីថ្ងៃដាច់ចំណងអាពាហ៍ពិពាហ៍ ។

**មាត្រា ៨៣.** កូនដែលកើតក្នុងរយៈវេលាតិចជាង ១៨០ ថ្ងៃ គិតពីថ្ងៃរៀបអាពាហ៍ពិពាហ៍ និងទុកថា កូនរបស់ប្តីនៃម្តាយបាន កាលបើមានភស្តុតាងច្បាស់ថា ប្តីនេះបានដឹងថា ប្រពន្ធរបស់ខ្លួនមានផ្ទៃពោះតាំងពីមុនរៀបអាពាហ៍ពិពាហ៍មកម្ល៉េះ ឬ ក៏ព្រមទទួលស្គាល់ថា ខ្លួនជាឪពុករបស់កូននោះ ។ បើមិនដូច្នេះទេ ប្តីរបស់ម្តាយនៃកូននោះអាចបដិសេធថា ខ្លួនមិនមែនជាឪពុករបស់កូននោះបាន ដោយមិនចាំបាច់បង្ហាញភស្តុតាងថាខ្លួនមិនមែនជាឪពុក ។

**មាត្រា ៨៤.** កូនដែលកើតក្នុងល័ក្ខខ័ណ្ឌ នៃពេលដែលមានចែងក្នុងមាត្រា៨២ ជាភស្តុតាងយ៉ាងមាំ តម្រូវឱ្យសន្មត់ថា ប្តីនៃម្តាយគឺពិតជាឪពុករបស់កូននោះ ។ ប្តីនៃម្តាយអាចមិនទទួលស្គាល់ថា កូននោះជាកូនរបស់ខ្លួនបាន លុះណាតែប្តីនោះប្តឹងបដិសេធបិតុភាព ។

**មាត្រា ៨៥.** ការប្តឹងប្រកែកមិនទទួលស្គាល់បិតុភាព ត្រូវប្តីប្តឹងពីម្តាយ និង ពីកូន ចំពោះមុខតុលាការប្រជាជនខាងលំនៅនៃម្តាយក្នុងរយៈពេល ២ ខែ គិតពីថ្ងៃដែលខ្លួនបានដឹងពីកំណើតនៃកូននោះ ។

**មាត្រា ៨៦.** ប្ដីត្រូវជូនភស្តុតាងថា កាលប្រពន្ធខ្លួនមានគភ៌ ក្នុងរយៈពេលដែលច្បាប់បានកំណត់នោះ ខ្លួនមានវិបត្តិខាងរូបកាយ មិនអាចរួមដំណេកជាមួយម្ដាយនៃកូននោះបានទេ ។ វិបត្តិខាងរូបកាយដែលពុំអាចឱ្យរួមដំណេកបាននោះ អាចកើតមកពីហេតុ ២ យ៉ាង :

១- ប្ដីប្រពន្ធរស់នៅដាច់ឆ្ងាយពីគ្នា

២- ប្ដីគ្មានពលានុភាពបណ្ដាលមកពីកាយវិកលកម្ម ដែលមិនអាចឱ្យបន្តពូជបាន ។

**មាត្រា ៨៧.** ទាយាទខាងប្ដី អាចនឹងប្ដឹងបដិសេធកូននោះជួសបាន ក្នុងរយៈពេលដែលមានចែងក្នុងមាត្រា ៨៥ ប្រសិនបើប្ដីនោះមិនអាចប្ដឹងបាន ដោយប្ដីនោះស្លាប់បាត់ខ្លួន ឬ ក៏វង្វេងស្មារតី ។

ទាយាទខាងប្ដីអាចនឹងបន្តការប្ដឹងបដិសេធកូននោះបាន ប្រសិនបើក្នុងរយៈពេល ដែលមានចែងក្នុងមាត្រា ៨៥ ក្ដីនោះបានប្ដឹងបដិសេធរួចហើយ ហើយស្លាប់បាត់ខ្លួន ឬ ក៏វង្វេងស្មារតី ។

**មាត្រា ៨៨.** សាលក្រមដែលសំរេចទទួលបណ្ដឹងបដិសេធនោះ ទុកជាត្រឹមត្រូវ ត្រូវបង្គាប់អោយលុបឈ្មោះប្ដីនោះ ចេញពីបញ្ជីសំបុត្រកំណើតរបស់កូន ហើយឱ្យដកត្រកូលឪពុកចេញពីកូន ដោយយកត្រកូលម្ដាយដាក់ជំនួសវិញ ។

**មាត្រា ៨៩.** ត្រូវបញ្ជូនសេចក្ដីសំរេចនៃសាលក្រមទៅឱ្យមន្ត្រីអត្រានុកូលដ្ឋានដែលបានធ្វើសំបុត្រកំណើតរបស់ កូននោះ ដើម្បីឱ្យចម្លងដាក់ក្នុង បញ្ជីសំបុត្រកំណើតហើយចុះនិទ្ទេសនៅរឹមទំព័រ នៃសំបុត្រ កំណើតដែលត្រូវកែនោះ ។

## ផ្នែកទី ២

## អំពីកូនឥតខាន់ស្លា

**មាត្រា ៩០.** ដែលហៅថា កូនឥតខាន់ស្លា គឺកូនដែលកើតពីឪពុកម្ដាយគ្មានចំណងដៃអាពាហ៍ពិពាហ៍ ។

**មាត្រា ៩១.** នៅពេលធ្វើសំបុត្រកំណើត បើឪពុកម្ដាយ ដែលគ្មានចំណងដៃអាពាហ៍ពិពាហ៍ បានឆ្លើយទទួលស្គាល់ដោយជាក់លាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានថា កូនដែលកើតមកនោះជាកូនរបស់ខ្លួន នោះត្រូវចាត់ទុកឪពុកម្ដាយនេះថា ឪពុកម្ដាយរបស់កូននោះ ។

**មាត្រា ៩២.** បើមានតែឪពុក ឬ មានតែម្ដាយ ឆ្លើយទទួលស្គាល់ម្នាក់ឯងទេ កូននោះត្រូវចាត់ទុកជាកូនរបស់អ្នកដែលបានឆ្លើយទទួលស្គាល់តែម្នាក់ប៉ុណ្ណោះ ។

**មាត្រា ៩៣.** ក្រោយពេលដែលឪពុក ឬ ម្ដាយបានប្ដឹងចុះកំណើតកូន ឪពុក ឬ ម្ដាយណាដែលមិនទាន់ទទួលស្គាល់ឪពុក ឬម្ដាយនោះ អាចប្ដឹងសុំទទួលស្គាល់កូនជាក្រោយបាន ។

**មាត្រា ៩៤.** កូនឥតខាន់ស្លាដែលឪពុកម្ដាយបានទទួលស្គាល់នឹងទៅជាកូនមានខាន់ស្លាបាន បើក្រោយពីកំណើតរបស់កូននោះ ឪពុកម្ដាយរបស់កូននោះ បានចុះអាពាហ៍ពិពាហ៍ជាមួយគ្នា ។

ការទទួលស្គាល់កូនអាចធ្វើនៅមុនពេលចុះអាពាហ៍ពិពាហ៍ ធ្វើដំណាលគ្នានឹងពេលចុះអាពាហ៍ពិពាហ៍ ឬ ក្រោយពេលចុះអាពាហ៍ពិពាហ៍ក៏បាន ។

## ផ្នែកទី ៣

## អំពីការស្វែងរកបិតុភាព ឬ មាតុភាព

## នៃកូនឥតខាន់ស្លា

**មាត្រា ៩៥.** បើគ្មានលិខិតធ្វើទទួលស្គាល់ ដោយស្ម័គ្រចិត្តនូវកូនឥតខាន់ស្លាទេ នោះតុលាការប្រជាជនអាចតម្រូវឱ្យឪពុក ឬ ម្ដាយទទួលស្គាល់កូននោះបាន ។

**មាត្រា ៩៦.** កូនឥតខាន់ស្លាដែលឪពុក ឬ ម្ដាយមិនបានទទួលស្គាល់ មានសិទ្ធិប្ដឹងសុំឱ្យតុលាការប្រជាជនរកឪពុក ឬ រកម្ដាយឱ្យខ្លួនបាន ។

**មាត្រា ៩៧.** បណ្ដឹងសុំឱ្យតុលាការប្រជាជន តម្រូវឱ្យឪពុក ឬ ម្ដាយទទួលស្គាល់នោះ អាចធ្វើឡើងក្នុងរយៈពេល ២ ឆ្នាំ គិតពីថ្ងៃដែលកូននោះមាននីតិភាព ។

នីតិភាពត្រូវកំណត់ចាប់ពីអាយុ ១៨ ឆ្នាំឡើងទៅ ។

ក្នុងពេលដែលកូនឥតខាន់ស្លា នៅក្នុងអនីតិភាពនៅឡើយ អ្នកអាណាព្យាបាលរបស់កូននោះមានសិទ្ធិប្ដឹងជួស សុំឱ្យតុលាការប្រជាជន រកមាតុភាពឱ្យកូននោះ ។

**មាត្រា ៩៨.** តុលាការប្រជាជន អាចតម្រូវឱ្យនារីជាម្ដាយទទួលស្គាល់កូនឥតខាន់ស្លាបាន បើមានភស្ដុតាងបញ្ជាក់ថា :

ក- នារីនោះបានបង្កើតកូនប្រាកដមែន

ខ- អត្តសញ្ញាណរបស់កូនដែលនារីនោះបានបង្កើត និង អត្តសញ្ញាណរបស់កូន ដែលប្ដឹងទាមទាររកមាតុភាព នោះមិនខុសប្លែកពីគ្នា ។

ភស្ដុតាងអាចបង្ហាញបានតាមគ្រប់មធ្យោបាយ ។

**មាត្រា ៩៩.** តុលាការប្រជាជន អាចតម្រូវឱ្យបុរសជាឪពុកទទួលស្គាល់កូនឥតខាន់ស្លាបាន :

១-បើបុរសនោះបាននាំពង្រត់ ឬ បានចាប់រំលោភសេពសន្ថវៈនារីជាម្ដាយដោយរំលោភ ហើយបើសម័យនាំពង្រត់ ឬ ចាប់រំលោភសេពសន្ថវៈនោះ ត្រូវគ្នានឹងសម័យដែលនារីនោះមានគភ៌ ។

២-បើបុរសនោះបានខ្លួននារី ដោយឧបាយកលបោកបញ្ឆោតដោយការរំលោភអំណាច ឬ ដោយការសន្យាថា នឹងរៀបអាពាហ៍ពិពាហ៍ជាមួយនារីនោះ ។

៣-បើមានភស្តុតាងជាលាយលក្ខណ៍អក្សរពីបុរសនោះ បង្ហាញឱ្យឃើញច្បាស់ថា បុរសនោះពិតជាឪពុករបស់កូននោះ ។

៤- បើបុរស នឹង នារីជាឪពុកម្តាយ និង ជាម្តាយរបស់កូននោះ បានរួមរស់ និងគ្នាជាអនីតិសង្វាសជាក់ស្តែងក្នុងសម័យនីត្យានុកូលដែលនារីនោះមានគភ៌ ។

៥- បើបុរសនោះបានផ្គត់ផ្គង់ ឬ បានចូលរួមក្នុងការបីបាច់រក្សា និង ការអប់រំកូននោះក្នុងឋានៈខ្លួនជាឪពុក ។

**មាត្រា ១០០**~ ពាក្យដែលប្តឹងរកបិតុភាពមិនអាចនឹងទទួលបាន :

១- បើមានភស្តុតាងថា នារីជាម្តាយមានទំនាក់ទំនងកាមគុណនឹងប្រុសដទៃទៀត ក្នុងសម័យនីត្យានុកូលដែលនារីនោះមានគភ៌ ។

២- បើក្នុងសម័យនីត្យានុកូលដែលនារី មានគភ៌បុរសដែលត្រូវប្រកាន់ថា ជាឪពុករបស់កូននោះ គ្មានលទ្ធភាពរួមដំណេកជាមួយនារីជាម្តាយនោះ ដោយរស់នៅឆ្ងាយពីគ្នា ឬ ដោយមកពីមានគ្រោះថ្នាក់ ដូចមានចែងក្នុងមាត្រា ៨៦ ។

**មាត្រា ១០១**~ ក្នុងពេលដែលកូនឥតខាន់ស្លា នៅក្នុងអនីតិភាពនៅឡើយ ម្តាយ ឬ អ្នកអាណាព្យាបាលនៃកូននោះអាចប្តឹងសុំឱ្យរកបិតុភាពបាន ។

ភស្តុតាងអាចបង្ហាញបានតាមគ្រប់មធ្យោបាយ ។

**មាត្រា ១០២**~ សាលក្រមដែលកាត់សេចក្តីឱ្យទទួលស្គាល់កូនឥតខាន់ស្លា មានអនុភាពដូចគ្នានឹងលិខិតដែលទទួលស្គាល់កូនដោយស្ម័គ្រចិត្តដែរ ។

**មាត្រា ១០៣**~ កូនឥតខាន់ស្លា ត្រូវយកត្រកូលរបស់ឪពុក ឬ ម្តាយដែលទទួលស្គាល់ខ្លួន ។ ប្រសិនបើឪពុក និង ម្តាយទាំងពីរនាក់ទទួលកូននោះ ត្រូវយកត្រកូលរបស់ឪពុក ។

ប្រសិនបើតុលាការប្រជាជន តម្រូវឱ្យឪពុក ឬ ម្តាយទទួលស្គាល់កូននោះ ត្រូវយកត្រកូលរបស់អ្នក ដែលតុលាការតម្រូវឱ្យទទួលស្គាល់ ។

ប្រសិនបើតុលាការប្រជាជនតម្រូវឱ្យឪពុក និង ម្តាយទាំងពីរនាក់ទទួលស្គាល់ កូននោះត្រូវយកត្រកូលរបស់ឪពុក ។

**មាត្រា ១០៤**~ កូនឥតខាន់ស្លា ដែលត្រូវបានទទួលស្គាល់មានករណីយកិច្ច និង មានសិទ្ធិដូចគ្នានឹងកូនមានខាន់ស្លាដែរ ។

# ឧបសម្ព័ន្ធទី៣៖
# ច្បាប់ស្តីពី ឯកពន្ធភាព ឆ្នាំ
# ២០០៦

# ច្បាប់

# ស្តីពី

# ឯកពន្ធភាព

# ព្រះរាជក្រម

នស/រកម/១០០៦/០២៦

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្សាខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ឯកពន្ធភាព ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៥ នីតិកាលទី ៣ និងដែលព្រឹទ្ធសភា បានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងការពារសេចក្តីថ្លៃថ្នូរ និងពង្រឹងសុខដុមរមនា សុភមង្គលក្នុងគ្រួសារ និងការគោរពសិទ្ធិគ្នាទៅវិញទៅមករវាងប្តីនិងប្រពន្ធ ស្របតាមមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដោយបំពេញបន្ថែមលើបទដ្ឋានគតិយុត្តជាធរមាន ។

**មាត្រា ២.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានចំណងអាពាហ៍ពិពាហ៍ ត្រូវគោរពគោលការណ៍ឯកពន្ធភាពដោយស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយ ដោយមានចុះបញ្ជីអាពាហ៍ពិពាហ៍ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ។

## ជំពូកទី ២
## និយមន័យ ពិរុទ្ធភាព និងនីតិវិធី

**មាត្រា ៣.-**

ឯកពន្ធភាពជាចំណងអាពាហ៍ពិពាហ៍ ដែលបុរសមានប្រពន្ធតែមួយ ឯស្ត្រីមានប្តីតែមួយ ។ ដែលហៅថាចំណងអាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឧឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ ដែលប្តេជ្ញាថារួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន ។

ចំណងអាពាហ៍ពិពាហ៍ត្រូវរលាយក្នុងករណីណាមួយដូចខាងក្រោម :

-សហព័ទ្ធណាមួយស្លាប់ ។

-មានសេចក្តីសម្រេចរំលាយចំណងអាពាហ៍ពិពាហ៍ជាស្ថាពររបស់តុលាការ ។

-សហព័ទ្ធណាម្នាក់បាត់ខ្លួនហួសពីមួយឆ្នាំដោយគ្មានដំណឹងអ្វីសោះ មិនដឹងថាស្លាប់ ឬរស់ ។

**មាត្រា ៤.-**

ទ្វេពន្ធភាពជាចំណងអាពាហ៍ពិពាហ៍ដែលបុរសមានប្រពន្ធពីរ ឬស្ត្រីមានប្តីពីរ ។

ត្រូវចាត់ទុកថាមានពិរុទ្ធក្នុងបទទ្វេពន្ធភាព បុរស ឬ ស្ត្រីណាដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយនៅឡើយ ហើយទៅចុះបញ្ជីអាពាហ៍ពិពាហ៍ថ្មីមួយទៀត ។

អ្នកសមគំនិតត្រូវមានទោសដូចគ្នា ។

**មាត្រា ៥.-**

ត្រូវចាត់ទុកថាសូន់ បុរស និងស្ត្រីណាដែលជាប់ចំណងជាញាតិលោហិត ឬ ញាតិពន្ធនឹងគ្នា ហើយរួមសេវនកិច្ចជាមួយគ្នា ។

**មាត្រា ៦.-**

ត្រូវចាត់ទុកថាមានពិរុទ្ធក្នុងបទសូន់ :

-បុរស និងស្ត្រីដែលជាប់ចំណងជាញាតិលោហិត ឬ ញាតិពន្ធក្នុងខ្សែផ្ទាល់គ្រប់ថ្នាក់ ទោះចំណងនោះមានខាន់ស្លាក្តី ឥតខាន់ស្លាក្តី ឬ ជាសាច់ចិញ្ចឹមក្តី បានរួមសេវនកិច្ចជាមួយគ្នា ។

-បុរស និងស្ត្រីដែលជាប់ចំណងសាខាញាតិនឹងគ្នា ទោះសាខាញាតិនោះមានខាន់ស្លាក្តី ឥតខាន់ស្លាក្តី ចិញ្ចឹមក្តី រួមម្តាយក្តី រួមឪពុកក្តី រួមម្តាយឪពុកក្តី ជាញាតិលោហិតក្តី ឬ ជាញាតិពន្ធក្តី រហូតដល់ថ្នាក់ទី ៣ រាប់ទាំងថ្នាក់នេះ ផងបានរួមសេវនកិច្ចជាមួយគ្នា ។

មិនចាត់ទុកថាមានពិរុទ្ធពីបទសូន់ទេ ប្រសិនបើសហព័ទ្ធណាម្នាក់ស្លាប់ ហើយសហព័ទ្ធដែលនៅរស់រួមសេវនកិច្ចជាមួយសាខាញាតិពន្ធថ្នាក់ទី ២ ឬ ថ្នាក់ទី ៣ ។

**មាត្រា ៧.-**

ត្រូវចាត់ទុកថាផិត គឺការរួមសេវនកិច្ចរវាងបុរសដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយជាមួយស្ត្រីដទៃក្រៅពីប្រពន្ធរបស់ខ្លួន ឬ ការរួមសេវនកិច្ចរវាងស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍មិនទាន់រលាយជាមួយបុរសដទៃក្រៅពីប្តីរបស់ខ្លួន ។

ត្រូវចាត់ទុកថាមានពិរុទ្ធក្នុងបទផិត :

-បុរសណា ដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយ ហើយទៅរួមសេវនកិច្ចជាមួយស្ត្រីផ្សេងទៀត ។

-ស្ត្រីណា ដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយ ហើយទៅរួមសេវនកិច្ចជាមួយបុរសដទៃទៀត ។

**មាត្រា ៨.–**

ក្នុងករណីដែលមានចែងក្នុងមាត្រា ៧ ខាងលើ ព្រះរាជអាជ្ញាអាចសំរេចមិនធ្វើបណ្តឹងអាជ្ញាបាន ប្រសិនបើមានបណ្តឹងរបស់សហព័ទ្ធណាមួយស្នើសុំកុំឱ្យចោទប្រកាន់ ។

## ជំពូកទី ៣
## ទោសប្បញ្ញត្តិ

**មាត្រា ៩.–**

ជនណាប្រព្រឹត្តល្មើសនឹងមាត្រា ៤ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ)ខែ ដល់ ១ (មួយ)ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ២០០.០០០ (ពីររយពាន់) រៀល ដល់ ១.០០០.០០០ (មួយលាន) រៀល ឬ ផ្តន្ទាទោសណាមួយនៃទោសទាំងពីរ ។

**មាត្រា ១០.–**

ជនណាប្រព្រឹត្តល្មើសនឹងមាត្រា ៦ និងមាត្រា ៧ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ខែ ដល់ ១ (មួយ)ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ២០០.០០០ (ពីររយពាន់) រៀល ដល់ ១.០០០.០០០ (មួយលាន) រៀល ឬ ផ្តន្ទាទោសណាមួយនៃទោសទាំងពីរ ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ១១.-**

ច្បាប់នេះ ពុំមានអានុភាពប្រតិសកម្មឡើយ ។

**មាត្រា ១២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៦

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៣រល.០៦១០.៤៥២ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ : ៤០១ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ២០០៦

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ឧបសម្ព័ន្ធទី៤៖ បញ្ជីអាពាហ៍ពិពាហ៍



បញ្ជីអាពាហ៍ពិពាហ៍

# ឧបសម្ព័ន្ធទី ៥៖ ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង រាជធានី ---- ភ្នំពេញ -------
ស្រុក ខណ្ឌ ---- ឫស្សីកែវ ------
ឃុំ សង្កាត់ ---- បាក់ខែង ------
លេខ ---- ០៥ ឃ.ខ -----

## ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍

| អំពីសាមីខ្លួន | ខាងប្រុស | ខាងស្រី |
|---|---|---|
| នាមត្រកូល និង នាមខ្លួន | សាយ សំអាន | អ៊ុ នួនស្រី |
| ជាអក្សរឡាតាំង | SAY SAM ANN | OU NUON SREY |
| សញ្ជាតិ | ខ្មែរ | ខ្មែរ |
| ថ្ងៃ ខែ ឆ្នាំកំណើត | ថ្ងៃពុធ ទី២៥ ខែសីហា ឆ្នាំ១៩៧៣ | ថ្ងៃច័ន្ទ ទី១៧ ខែមករា ឆ្នាំ១៩៧៥ |
| ទីកន្លែងកំណើត | ភូមិពញាឮ ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្ដាល ប្រទេសកម្ពុជា | ភូមិក្ដីចាស់ ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្ដាល ប្រទេសកម្ពុជា |
| មុខរបរបច្ចុប្បន្ន | សាស្ត្រាចារ្យ | គ្រូពេទ្យ |
| ទីលំនៅបច្ចុប្បន្ន | ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា | ភូមិក្ដីចាស់ សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| រយៈពេលប្ដឹងជំទាស់ | ១០ថ្ងៃ គិតពីថ្ងៃបិទផ្សាយ | |
| នាមត្រកូល និងនាមខ្លួនឪពុក | សាយ សំអឿន | អ៊ុ សែម |
| ថ្ងៃ ខែ ឆ្នាំកំណើត | ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៤៦ | ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥៥ |
| មុខរបរបច្ចុប្បន្ន | កសិករ | ជាងសំណង់ |
| ទីលំនៅបច្ចុប្បន្ន | ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា | ភូមិក្ដីចាស់ សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| នាមត្រកូល និងនាមខ្លួនម្ដាយ | សែម បុប្ផា | នួន ផល្លា |
| ថ្ងៃ ខែ ឆ្នាំកំណើត | ថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៤៨ | ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៦០ |
| មុខរបរបច្ចុប្បន្ន | ជាងកាត់ដេរ | លក់ដូរ |
| ទីលំនៅបច្ចុប្បន្ន | ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា | ភូមិក្ដីចាស់ សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍នេះ ត្រូវបិទផ្សាយជាសាធារណៈ នៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ។

ធ្វើនៅ... បាក់ខែង ....ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២

មន្ត្រីអត្រានុកូលដ្ឋាន

មេឃុំ

ផៃ សុទី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត/ក្រុង រាជធានី --- ភ្នំពេញ ---
ស្រុក/ខណ្ឌ --- ឫស្សីកែវ ---
ឃុំ/សង្កាត់ --- បាក់ខែង ---
លេខ --- ០៥ ប.ខ ---

# ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍

| អំពីសាមីខ្លួន | ខាងប្រុស | ខាងស្រី |
|---|---|---|
| នាមត្រកូល និង នាមខ្លួន | សាយ សំអាន | អ៊ូ នួនស្រី |
| ជាអក្សរឡាតាំង | SAY SAM ANN | OU NUON SREY |
| សញ្ជាតិ | ខ្មែរ | ខ្មែរ |
| ថ្ងៃ ខែ ឆ្នាំកំណើត | ថ្ងៃពុធ ទី២៥ ខែសីហា ឆ្នាំ១៩៨៣ | ថ្ងៃចន្ទ ទី១៧ ខែមករា ឆ្នាំ១៩៨៩ |
| ទីកន្លែងកំណើត | ភូមិពញាឮ ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្ដាល ប្រទេសកម្ពុជា | ភូមិក្ដីចាស់ ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្ដាល ប្រទេសកម្ពុជា |
| មុខរបរបច្ចុប្បន្ន | សាស្ត្រាចារ្យ | គ្រូពេទ្យ |
| ទីលំនៅបច្ចុប្បន្ន | ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា | ភូមិក្ដីចាស់ សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| រយៈពេលប្ដឹងជំទាស់ | ១០ថ្ងៃ គិតពីថ្ងៃបិទផ្សាយ | |
| នាមត្រកូល និងនាមខ្លួនឪពុក | សាយ សំភឿន | អ៊ូ សែម |
| ថ្ងៃ ខែ ឆ្នាំកំណើត | ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៥៦ | ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥៨ |
| មុខរបរបច្ចុប្បន្ន | កសិករ | ជាងសំណង់ |
| ទីលំនៅបច្ចុប្បន្ន | ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា | ភូមិក្ដីចាស់ សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| នាមត្រកូល និងនាមខ្លួនម្ដាយ | សែម បុប្ផា | នួន ផល្លា |
| ថ្ងៃ ខែ ឆ្នាំកំណើត | ថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៥៨ | ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៦០ |
| មុខរបរបច្ចុប្បន្ន | ជាងកាត់ដេរ | លក់ដូរ |
| ទីលំនៅបច្ចុប្បន្ន | ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា | ភូមិក្ដីចាស់ សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍នេះ ត្រូវបិទផ្សាយជាសាធារណៈ នៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ។

ធ្វើនៅ... បាក់ខែង ...ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២

មន្ត្រីអត្រានុកូលដ្ឋាន
មេឃុំ
ថៃ សុទ្ធិ

# ឧបសម្ព័ន្ធទី ៦៖ សំបុត្រអាពាហ៍ពិពាហ៍

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង រាជធានី(១) ---- ភ្នំពេញ ----

ស្រុក ខណ្ឌ (២) ---- ឫស្សីកែវ ----

ឃុំ សង្កាត់ (៣) ---- ចាក់ទែង ----

លេខ (៤)------០៩------------------------

សៀវភៅអាពាហ៍ពិពាហ៍លេខ (៥)-០១/២០១២

ឆ្នាំ (៦)------- ២០១២ --------------------

## សំបុត្រអាពាហ៍ពិពាហ៍

| អំពីប្តី ប្រពន្ធ | | ប្តី | ប្រពន្ធ |
|---|---|---|---|
| នាមត្រកូល (៧) | | សាយ | អ៊ូ |
| នាមខ្លួន (៨) | | សំអាន | នួនស្រី |
| ជាអក្សរឡាតាំង (៩) | នាមត្រកូល | SAY | OU |
| | នាមខ្លួន | SAM ANN | NUON SREY |
| សញ្ជាតិ (១០) | | ខ្មែរ | ខ្មែរ |
| ថ្ងៃ ខែ ឆ្នាំកំណើត (១១) | | ថ្ងៃពុធ ទី[illegible] ខែសីហា ឆ្នាំ១៩[illegible] | ថ្ងៃទី[illegible] ទី[illegible] ខែមករា ឆ្នាំ១៩[illegible] |
| ទីកន្លែងកំណើត (១២) ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្ត ក្រុង ប្រទេស | | ភូមិ[illegible] ឃុំ[illegible] ស្រុក[illegible] ខេត្តកណ្តាល ប្រទេសកម្ពុជា | ភូមិ[illegible] ឃុំចាក់ទែង ស្រុកមុខកំពូល ខេត្តកណ្តាល ប្រទេសកម្ពុជា |
| មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៣) | | [illegible] | [illegible] |
| ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៤) | | ភូមិចាក់ទែង សង្កាត់[illegible] ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា | ភូមិ[illegible] សង្កាត់ចាក់ទែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ (១៥) | | ថ្ងៃ សុក្រ ទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២ | |
| ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ (១៦) | | សង្កាត់ចាក់ទែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | |
| អំពីឪពុក ម្តាយ | | ខាងប្តី | ខាងប្រពន្ធ |
| នាមត្រកូល និង នាមខ្លួនឪពុក (១៧) | | សាយ សំអឿន | អ៊ូ សែម |
| ជាអក្សរឡាតាំង (១៨) | | SAY SAM OEUN | OU SEM |
| សញ្ជាតិ (១៩) | | ខ្មែរ | ខ្មែរ |
| ថ្ងៃ ខែ ឆ្នាំកំណើត (២០) | | ថ្ងៃទី[illegible] ខែកញ្ញា ឆ្នាំ១៩[illegible] | ថ្ងៃទី[illegible] ខែកុម្ភៈ ឆ្នាំ១៩[illegible] |
| នាមត្រកូល និង នាមខ្លួនម្តាយ (២១) | | សែម បុប្ផា | នួន ផល្លា |
| ជាអក្សរឡាតាំង (២២) | | SEM BOPHA | NUON PHALLA |
| សញ្ជាតិ (២៣) | | ខ្មែរ | ខ្មែរ |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៤) | | ថ្ងៃទី[illegible] ខែមករា ឆ្នាំ១៩[illegible] | ថ្ងៃទី[illegible] ខែមេសា ឆ្នាំ១៩[illegible] |

(២៥) ធ្វើនៅ.... ចាក់ទែង .... ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២

(២៦) មន្ត្រីអត្រានុកូលដ្ឋាន

មេឃុំ

(២៧) ហត្ថលេខា និងត្រា

កែវ សុខី

# ឧបសម្ព័ន្ធទី ៧៖ កិច្ចព្រមព្រៀងលែងលះ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កិច្ចព្រមព្រៀងលែងលះ**

កិច្ចព្រមព្រៀងនេះធ្វើឡើងនៅថ្ងៃទី ....... ខែ ...... ឆ្នាំ.........រវាង៖

ឈ្មោះ ................. ភេទ ប្រុស ថ្ងៃខែឆ្នាំកំណើត:....................... មានទីលំនៅផ្ទះលេខ: ........... ផ្លូវ............... សង្កាត់ ............... ខណ្ឌ ............... រាជធានីភ្នំពេញ ភាគីប្តីតទៅនេះហៅកាត់ថា **ភាគី "ក"**។

**និង**

ឈ្មោះ .................. ភេទ ស្រី ថ្ងៃខែឆ្នាំកំណើត: .................... មានទីលំនៅផ្ទះលេខ: ............. ផ្លូវ ............... សង្កាត់................. ខណ្ឌ ............... រាជធានីភ្នំពេញ ។

**មុនកថា**

**ដោយហេតុថា**: **ភាគី "ក"** និង **ភាគី "ខ"** បានរៀបការជាមួយគ្នានៅឆ្នាំ ........... និងបានចុះសំបុត្ររាពាហ៍ពិពាហ៍នៅថ្ងៃទី......... ខែ ......... ឆ្នាំ ......... នៅសាលាខណ្ឌ ........... រាជធានីភ្នំពេញ ហើយបង្កើតបានកូនចំនួន .......... នាក់ ភេទ ប្រុស ថ្ងៃខែឆ្នាំកំណើត: ២១.០១.២០០១។ ការរស់នៅជាមួយគ្នាជាប្តីប្រពន្ធនេះតែងតែមានភាពរកាំរកូស ពុំមានសេចក្តីសុខក្នុងគ្រួសារ មិនអាចរស់នៅជាមួយគ្នាតទៅទៀតបាន ហើយយើងខ្ញុំក៏អស់មនោសញ្ចេតនាក្នុងការរួមរស់ជាប្តីប្រពន្ធជាមួយគ្នា និង ព្រមព្រៀងលែងលះឈប់រស់នៅជាមួយគ្នាជាប្តីប្រពន្ធចាប់ពីពេលនេះតទៅ ។

**ក្រោយពីបានពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមកភាគីទាំងពីរបានឯកភាពគ្នាដូចខាងក្រោយ**:

**ប្រការ១**: **ភាគី "ក"** និង **ភាគី "ខ"** ឯកភាពយល់ព្រមលែងលះឈប់រស់នៅជាមួយគ្នាជាប្តីប្រពន្ធដោយស្ម័គ្រចិត្តពីថ្ងៃចុះហត្ថលេខា និងផ្តិតមេដៃនេះតទៅ ។

ទ្រព្យសម្បត្តិរួមមាន៖

មានកូនឈ្មោះ .............. ភេទ ប្រុស ថ្ងៃខែឆ្នាំកំណើត: .......................................................។

១-ដីទំហំ ..... ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: .....................ចុះថ្ងៃទី................ ចេញដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសុរិយោដី .........................។

២-ដីទំហំ ........... ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ................. ចុះថ្ងៃទី............ ចេញដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសុរិយោដី ..........................។

៣-ដីទំហំ ......... ម៉ែត្រការ៉េ ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ:................... ចុះថ្ងៃទី .................... ចេញដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម និង សុរិយោដី ................។

**ប្រការ២**: **ភាគី "ខ"** យល់ព្រមប្រគល់សិទ្ធិគ្រប់គ្រង និងជាអ្នកមានអំណាចមេបាលើកូនឈ្មោះ .............. .............. ភេទ ប្រុស ថ្ងៃខែឆ្នាំកំណើត: ............................អោយ**ភាគី "ក"** ។**ភាគី "ក"** ឯកភាពតាម**ភាគី "ខ"** ។

**ប្រការ៣**: **ភាគី "ក"** មិនទាមទារអោយ **ភាគី "ខ"** បង់អាហារកិច្ចចិញ្ចឹមបីបាច់កូនទេ ។ **ភាគី "ខ"** គ្មានសិទ្ធិគ្រប់គ្រង និងគ្មានអំណាចមេបាលើកូន តែមានសិទ្ធិជួបសួរសុខទុក្ខកូនតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារហើយ **ភាគី "ក"** ដែលមានសិទ្ធិគ្រប់គ្រង និងជាអ្នកមានអំណាចមេបាត្រូវបង្កលក្ខណៈងាយស្រួលដល់ **ភាគី "ខ"** ក្នុងការមកជួបកូន ។

<u>**ប្រការ៤**</u>: **ភាគី "ក"** និង **ភាគី "ខ"** យល់ព្រមបែងចែកទ្រព្យសម្បត្តិរួមដូចតទៅ :

-ដីទំហំ ........ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសម្គាល់អចលនវត្ថុលេខ: ........... ចុះថ្ងៃទី ......... ........... ចេញដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសុរិយោដី ...................................។

(មានសិទ្ធិចាត់ចែង គ្រប់គ្រង និងរកាស្រ័យផល ។

**ភាគី "ខ"** ទទួលបាន:

-ដីទំហំ ........ ម៉ែត្រការ៉េ ដែលមានសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ: ................. ចុះថ្ងៃទី........ ...................... ចេញដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម និង សុរិយោដី .....................។

(មានសិទ្ធិចាត់ចែង គ្រប់គ្រង និងរកាស្រ័យផល នៅពេលមានអាយុ ៣០ ឆ្នាំ )

ក្នុងកំឡុងពេលបច្ចុប្បន្នរហូតដល់អាយុក្រោម ៣០ ឆ្នាំ **ភាគី "ក"** ជាអ្នកថែរក្សា និងជាអ្នកមើលខុសត្រូវជូស ។

ធ្វើនៅថ្ងៃទី ...... ខែ..... ឆ្នាំ.......

| | | |
|---|---|---|
| **បានឃើញ និងបញ្ជាក់ថា** | **ស្នាមមេដៃស្តាំ** | **ស្នាមមេដៃស្តាំ** |
| គូភាគីពិតជាបានផ្តិតមេដៃស្តាំចំពោះ | **ភាគី "ក"** | **ភាគី "ខ"** |
| មុខមេធាវីពិតប្រាកដ ។ | | |
| **ហត្ថលេខា និងត្រា** | | |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀងលែងលះគ្នា

*កិច្ចព្រមព្រៀងនេះធ្វើឡើង និង មានសុពលភាពគិតចាប់ពីថ្ងៃទី ........ខែ........ ឆ្នាំ............. នេះតទៅ ដោយមានភាគី:*

*ឈ្មោះ......................................... ភេទ........... អាយុ.......... ឆ្នាំ............. សញ្ជាតិ................. កាន់អត្តសញ្ញាណប័ណ្ណលេខ............................................ ចុះថ្ងៃទី........... ខែ.......... ឆ្នាំ................. ហៅកាត់ថាភាគី "ក" ។*

**និង**

*ឈ្មោះ...................................................... ភេទ............. អាយុ........... ឆ្នាំ សញ្ជាតិ............... កាន់អត្តសញ្ញាណប័ណ្ណលេខ............................................... ចុះថ្ងៃទី........... ខែ.......... ឆ្នាំ............ ហៅកាត់ថាភាគី "ខ" ។*

**មុព្វកថា**

*ដោយហេតុថា ភាគី "ក" និង ភាគី "ខ" បានព្រមព្រៀងលែងលះគ្នាតាមគោលការណ៍ ស្ម័គ្រចិត្តទាំងសងខាងដោយគ្មានការបង្ខិតបង្ខំពីភាគីណាមួយនោះឡើយ ។*

*ដូចច្នេះ ដោយគិតពិចារណានៃការស្រុះស្រួលរកភាពគ្នា គូភាគីបានកំណត់ខចែង និង លក្ខខណ្ឌដូចខាងក្រោម:*

*ប្រការ១: អំពីការលែងលះ*

*១.១: ភាគី "ក" និងភាគី "ខ" បានសម្រេចចិត្តលែងលះគ្នាចាប់ពីថ្ងៃដែលផ្តិតមេដៃ នេះតទៅ និងមានជីវិតរៀងៗខ្លួនដោយមិនពាក់ព័ន្ធគ្នានៅថ្ងៃក្រោយ ។*

*១.២: ការលែងលះគ្នានេះធ្វើឡើងតាមការស្នើសុំរបស់ភាគី "..........." ។*


Shared By : Chim Vanntha Laws Page

១.៣: ភាគី "..........." បានយល់ព្រមលែងលះគ្នាតាមការស្នើសុំរបស់ភាគី "........."។

ប្រការ២: អំពីកូន

២.១: ភាគី " ........ " ជាអ្នកទទួលខុសត្រូវក្នុងការថែរក្សាកូនក្នុងផ្ទៃ (ករណីកូនក្នុងផ្ទៃ) ហូតដល់ កូននោះ សម្រាល និងចិញ្ចឹមបីបាច់ និងថែរក្សា អប់រំណែនាំ រួមទាំងទំនុកបម្រុងផ្សេងៗ ដល់កូននោះរហូតតទៅ ។

២.២: ភាគី "......" ស្ម័គ្រចិត្តបង់អាហារកាតព្វកិច្ចចំពោះកូនក្នុង ០១ខែ ........................... ចំពោះកូននៅក្នុងផ្ទៃ ប៉ុន្តែនៅពេលដែលកូននេះសម្រាល ភាគី "........." ស្ម័គ្រចិត្តបង់អាហារកាតព្វកិច្ច ចំពោះកូនទៅតាមតម្រូវការជាក់ស្តែងរបស់កូនក្នុងការសិក្សា ឬករណីមានជំងឺផ្សេងៗ ឬតាមលទ្ធភាពដែលខ្លួនអាចផ្តល់ឱ្យ ឬតាមការព្រមព្រៀងរបស់ភាគីទាំងសងខាង ។

ប្រការ៣: អំពីបំណុល

៣.១: ភាគី "........" ជាអ្នកស្ម័គ្រចិត្តសងនូវបំណុលដែលបានជំពាក់រួមគ្នាមុន និងក្រោយពេលរៀបអាពាហ៍ពិពាហ៍ក្នុងនោះមានបំណុលចំនួន ........................................ ។

៣.២: ភាគី "........" ស្ម័គ្រចិត្តសងបំណុលផ្សេងទៀតដែលនៅសេសសល់ក្រៅពីបំណុលចំណុច ៣.១ ខាងលើនេះ ។

ប្រការ៤: អំពីទ្រព្យរួម

៤.១: ភាគី " ..... " ជាអ្នកទទួលបាននូវដីមួយកន្លែងដែលគូភាគីបានទិញរួមគ្នាដែលមានប្រវែងបណ្តោយ .............. ម៉ែត្រ គុណ និងទទឹង .............. ម៉ែត្រ ដែលមានវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ................................................. ចុះថ្ងៃទី......... ខែ........ ឆ្នាំ........... និងមានទីតាំងស្ថិតនៅតាមផ្លូវលេខ............ ភូមិ.................... ឃុំ/សង្កាត់................. ស្រុក/ខណ្ឌ.................. រាជធានី/ខេត្ត............................... ។

៤.២: ភាគី " ......" ជាអ្នកទទួលបាននូវផ្ទះ និងដីដែលគូភាគីបានទិញរួមគ្នាដែលមានប្រវែងបណ្តោយ................. ម៉ែត្រ គុណ និងទទឹង........................... ម៉ែត្រ


Shared By : Chim Vanntha Laws Page

ដែលមានវិញ្ញាបនបត្រសម្គាល់អចលវត្ថុលេខ.......................................................
ចុះថ្ងៃទី.......... ខែ........ ឆ្នាំ........... និងមានទីតាំងស្ថិតនៅតាមផ្លូវលេខ............
ភូមិ......................ឃុំ/សង្កាត់................................. ស្រុក/ខណ្ឌ................................
រាជធានី/ខេត្ត............................................ ។

៤.៣: ភាគី ".....” ជាអ្នកទទួលបាននូវរថយន្ត០១ (មួយ) គ្រឿង ម៉ាក ...................................
សេរីឆ្នាំ............ ព៌ណ.................. ពាក់ស្លាកលេខ............................................... ។

៤.២: ភាគី ".....” ជាអ្នកទទួលបាននូវរថយន្ត០១ (មួយ) គ្រឿង ម៉ាក ...................................
សេរីឆ្នាំ............ ព៌ណ.................. ពាក់ស្លាកលេខ...............................................
និងម៉ូតូ០១ (មួយ) គ្រឿង ម៉ាក ...............................សេរីឆ្នាំ............ ព៌ណ................
ពាក់ស្លាកលេខ............................................ ។

ប្រការ៥: អំពីទ្រព្យដោយឡែក

៥.១: ទ្រព្យសម្បត្តិដែលភាគី "ក" និងភាគី "ខ" ដែលមានមុនពេល ឬក្រោយពេលរៀបអាពាហ៍ពិពាហ៍តាមរយៈអំណោយ ឬប្រទានកម្មផ្សេងៗទៀតដែលច្បាប់ចាត់ទុកថាជាទ្រព្យដោយឡែកគឺជាទ្រព្យរបស់ភាគីនោះ។

៥.២: លើកលែងតែទ្រព្យសម្បត្តិរួមដែលមានចែងក្នុងចំណុចប្រការ៤ ខាងលើនេះត្រូវមានការព្រមព្រៀងគ្នាក្នុងការបែកចែកទ្រព្យនោះ ។

ប្រការ៦: អំពីសិទ្ធិគូភាគី

៦.១: គូភាគីទាំងសងខាងមានសិទ្ធិរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបាន ក្រោយពីថ្ងៃផ្តិតមេដៃទទួលស្គាល់នូវកិច្ចព្រមព្រៀងនេះនៅចំពោះមុខចៅសង្កាត់ ។

៦.២: ក្នុងករណីដែលមានភាគីណាមួយរៀបអាពាហ៍ពិពាហ៍ថ្មីមួយទៀត ភាគីម្ខាងទៀតមិនអាចមានសិទ្ធិអះអាងថាជា សហព័ទ្ធ (ប្តី ឬប្រពន្ធ) របស់ខ្លួនបាននោះទេ (លើកលែងក្នុងករណីអះអាងថាជា អតីតសហព័ទ្ធ) ។



Shared By : Chim Vanntha Laws Page

៦.៣: ភាគី "........" មានសិទ្ធិក្នុងការចូលជួបកូន ឬអាចនាំកូនដើរលេងក្នុងករណីណាមួយ និងអប់រំប្រៀនប្រដៅចំពោះកូនបាន ។

ប្រការ៧: អំពីសិទ្ធិរបស់កូន

៧.១: កូនមានសិទ្ធិទៅលេង ឬចូលជួប ឬក៏អាចដើរលេង និងអាចទៅរស់នៅជាមួយភាគី "........" បានប្រសិនបើកូននោះចង់ទៅដោយគ្មានការបង្ខិតបង្ខំណាមួយពីភាគី "........" ឡើយ ។

៧.២: កូនអាចមានសិទ្ធិទទួលបានទ្រព្យសម្បត្តិដែលជាកេរ្តិ៍មរតករបស់ភាគី "........" បាននៅក្នុងពេលណាមួយតាមចំណែកដែលអាចទទួលបាន ។

ប្រការ៨: អន្តរបញ្ញត្តិ

៨.១: កិច្ចព្រមព្រៀងលែងលះគ្នានេះធ្វើឡើងជាឯកសារ ។

៨.២: ធ្វើឡើងជាភាសាខ្មែរមានចំនួន ០៣ ច្បាប់ ។

៨.៣: កិច្ចព្រមព្រៀងនេះរក្សាទុកនៅមេឃុំ ឬចៅសង្កាត់ចំនួន ០១ ច្បាប់ ប្រគល់ជូនភាគី "ក" ០១ ច្បាប់ និងប្រគល់ជូនភាគី "ខ" ០១ ច្បាប់ ។

**ហត្ថលេខា និងត្រា**

**មេឃុំ ឬចៅសង្កាត់**

ស្នាមមេដៃស្តាំ ភាគី "ក" សាក្សី សាក្សី ស្នាមមេដៃស្តាំ ភាគី "ខ"



Shared By : Chim Vanntha Laws Page

# ឧបសម្ព័ន្ធទី ៨៖ ពាក្យស្នើសុំលែងលះតាមការព្រមព្រៀង

គំរូ
ពាក្យសុំលែងលះ
ដោយព្រមព្រៀង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យស្នើសុំលែងលះតាមការព្រមព្រៀង

**ដើមចោទ** ៖ ឈ្មោះ.................... ភេទ......... អាយុ....... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ............... មានទីលំនៅបច្ចុប្បន្ន..........................................................។

**ចុងចម្លើយ** ៖ ឈ្មោះ.................... ភេទ......... អាយុ....... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ............... មានទីលំនៅបច្ចុប្បន្ន..........................................................។

**សូមគោរពជូនមក**

**ឯកឧត្តមប្រធានសាលាដំបូង**.........................

**កម្មវត្ថុ** ៖ សុំឲ្យតុលាការចេញដីកាសម្រេច មានខ្លឹមសារដូចខាងក្រោម ៖

១- ឲ្យ ដើមចោទ និងចុងចម្លើយ ផ្តាច់សមគ្គសង្វាស់ តាមផ្លូវច្បាប់ ។

២-សម្រេចឲ្យ (ដើមចោទ/ចុងចម្លើយ) ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ..........

៣-សម្រេចឲ្យ (ដើមចោទ/ចុងចម្លើយ) បង់អាហារកាតព្វកិច្ច និងអាចចូលសួរសុខទុក្ខកូនតាមច្បាប់កំណត់ ។

៤-សម្រេចឲ្យ ដើមចោទ មានសិទ្ធិលើទ្រព្យសម្បត្តិដូចខាងក្រោម៖

.......................................................................................................

.......................................................................................................

៥-សម្រេចឲ្យ ចុងចម្លើយ មានសិទ្ធិលើទ្រព្យសម្បត្តិដូចខាងក្រោម៖

.......................................................................................................

.......................................................................................................

៦-សម្រេចឲ្យ ដើមចោទ សងបំណុលដូចខាងក្រោម៖

(បើមានសូមសរសេរ)............................................................................

.......................................................................................................

៧-សម្រេចឲ្យ ចុងចម្លើយ សងបំណុលដូចខាងក្រោម៖

(បើមានសូមសរសេរ)............................................................................

.......................................................................................................

**យោង** ៖ -សំបុត្រអាពាហ៍ពិពាហ៍លេខ.......ចុះថ្ងៃទី...................... របស់.......................។

- ..........................................................................................................

តបតាមកម្មវត្ថុខាងលើ យើងខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា ៖ យើងខ្ញុំបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅសាលាសង្កាត់........................... តាមលិខិតលេខ............ ចុះថ្ងៃទី.................... ។ នៅពេលនេះ យើងខ្ញុំបានអស់មនោសញ្ចេតនាក្នុងការរស់នៅជាប្តីប្រពន្ធនឹងគ្នាទៀតហើយ ។ យើងខ្ញុំបានព្រមព្រៀងលែងលះគ្នាដោយស្ម័គ្រចិត្ត ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនិងសម្រេចតាមការស្នើសុំខាងលើដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ធ្វើនៅ................ ថ្ងៃទី........ ខែ........ ឆ្នាំ២០១......

ស្នាមមេដៃស្តាំចុងចម្លើយ
(ស្នាមមេដៃស្តាំ)

..................

ស្នាមមេដៃស្តាំដើមចោទ
(ស្នាមមេដៃស្តាំ)

....................

## ឧបសម្ព័ន្ធទី ៩៖ ពាក្យបណ្តឹងលែងលះ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គំរូ
ពាក្យសុំលែងលះ
ក្នុងការព្រមព្រៀង

**ពាក្យបណ្តឹងលែងលះ**

**ដើមចោទ** ៖ ឈ្មោះ.................... ភេទ.......... អាយុ....... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ............... មានទីលំនៅបច្ចុប្បន្ន..................................................................។

**ចុងចម្លើយ** ៖ ឈ្មោះ..................... ភេទ.......... អាយុ....... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ............... មានទីលំនៅបច្ចុប្បន្ន..................................................................។

**សូមគោរពចូលមក**
**ឯកឧត្តមប្រធានសាលាដំបូង**..........................

**កម្មវត្ថុ** ៖ សុំឲ្យតុលាការចេញដីកាសម្រេច មានខ្លឹមសារដូចខាងក្រោម ៖
១- ឲ្យ ដើមចោទ និងចុងចម្លើយ ផ្តាច់សបត្ថសង្វាស់ តាមផ្លូវច្បាប់ ។
២-សម្រេចឲ្យ (ដើមចោទ/ចុងចម្លើយ) ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ..........
៣-សម្រេចឲ្យ (ដើមចោទ/ចុងចម្លើយ) បង់អាហារកាតព្វកិច្ច និងអាចចូលសួរសុខទុក្ខកូនតាមច្បាប់កំណត់ ។
៤-សម្រេចឲ្យ ដើមចោទ មានសិទ្ធិលើទ្រព្យសម្បត្តិដូចខាងក្រោម៖
.........................................................................................................
៥-សម្រេចឲ្យ ចុងចម្លើយ មានសិទ្ធិលើទ្រព្យសម្បត្តិដូចខាងក្រោម៖
.........................................................................................................
៦-សម្រេចឲ្យ ដើមចោទ សងបំណុលដូចខាងក្រោម៖
(បើមានសូមសរសេរ)..........................................................................
៧-សម្រេចឲ្យ ចុងចម្លើយ សងបំណុលដូចខាងក្រោម៖
(បើមានសូមសរសេរ)..........................................................................

**យោង** ៖ -សំបុត្រអាពាហ៍ពិពាហ៍លេខ.......ចុះថ្ងៃទី...................... របស់.......................។
- ..........................................................................................

កាលពីថ្ងៃទី.....ខែ....ឆ្នាំ..... នាងខ្ញុំ/ខ្ញុំបាទ បាចចអាពាហ៍ពិពាហ៍ ជាឈ្មោះ......................... ។ ប៉ុន្តែក្នុងកំឡុងពេលអាពាហ៍ពិពាហ៍ ឈ្មោះនេះ (សរសេរពីមូលហេតុដែលនាំឲ្យមានការទាមទារ) .........................................................................................................................................។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធាន** មេត្តាទទួល និងសម្រេចតាមការប្តឹងសុំខាងលើដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ធ្វើនៅ................. ថ្ងៃទី......... ខែ......... ឆ្នាំ២០១.....

ស្នាមមេដៃស្តាំចុងចម្លើយ
(ស្នាមមេដៃស្តាំ)

ស្នាមមេដៃស្តាំដើមចោទ
(ស្នាមមេដៃស្តាំ)

# ឧបសម្ព័ន្ធទី ១០៖ សំណុំរឿងពាក់ព័ន្ធនឹងការលែងលះ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពង់ឆ្នាំង**

សំណុំរឿងរដ្ឋប្បវេណី

លេខៈ២១៤ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២

**សាលក្រមលេខៈ ១២ (ក)**

ថ្ងៃពុធ ១២រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក

ព.ស២៥៦៧ ត្រូវនឹងថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងខេត្តកំពង់ឆ្នាំង**

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣

**ចៅក្រមជំនុំជម្រះ**

-ឯកឧត្តម គីម តៃណារិន ប្រធានសាលាដំបូងខេត្តកំពង់ឆ្នាំង

**ក្រឡាបញ្ជីសវនាការ**

-លោក ឡុច សាមិធី ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ឆ្នាំង

-ដើមចោទឈ្មោះ **នូវ សុភារី** ភេទស្រី កើតថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៩០ ជាតិខ្មែរ របររកស៊ីមេផ្ទះ អាសយដ្ឋានភូមិព្រៃមាន់ ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ អ៊ុម សាវ៉ាន (ស្លាប់) ម្តាយឈ្មោះ នូវ ធាវ៉ា(រស់) ប្តីឈ្មោះ សាន់ ម៉ាឡៃ(រស់) មានកូន០២នាក់ ។

ដើមចោទមានមេធាវីតំណាងដោយអាណត្តិឈ្មោះ **ម៉ែន សុមុនី** ភេទស្រី អត្តលេខៈ៥៨៦ ក្រុមមេធាវីអ៊ឹម អេសអិន អាសយដ្ឋានផ្ទះលេខៈ៣៦E₀ ផ្លូវលេខៈ៩៩ ក្រុម៦ សង្កាត់បឹងត្របែក ខណ្ឌចំការមន ។

-ចុងចម្លើយឈ្មោះ **សាន់ ម៉ាឡៃ** ភេទប្រុស កើតថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៨៩ ជាតិខ្មែរ របររកស៊ីប៉ូលីស អាសយដ្ឋានផ្ទះលេខ ២២ ផ្លូវបេតុង ភូមិ៦ សង្កាត់ច្រាំងចំរេះទី២ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ អោម សី (រស់) ម្តាយឈ្មោះ ឡុង វណ្ណី (រស់) ប្រពន្ធឈ្មោះ នូវ សុភារី (រស់) មានកូន០២នាក់ ។

ចុងចម្លើយមានមេធាវីតំណាងដោយអាណត្តិឈ្មោះ **ទូច ចាន់ថេន** ភេទប្រុស អត្តលេខៈ ១១៨៦ ក្រុមហ៊ុនមេធាវីឈ្មោះសុភាចារស្មាក្តីអង្គរ មានអាសយដ្ឋានស្ថិតនៅបុរីភ្នំពេញថ្មីផាកផ្ទះលេខៈF៦៣៧ វិថីឧកញ៉ាខ្លូវតឹមបាក់ ភូមិខ្វរ សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ។

**អង្គហេតុ និងចំណុចវិវាទ**

**១-ការទាមទារ:** ដើមចោទសុំលែងលះប្តី ។

**២-ការពន្យល់ព្រួសៗអំពីរឿងក្តី**

ដើមចោទឈ្មោះ នូវ សុភារី បានរៀបការជាមួយចុងចម្លើយឈ្មោះ សាន់ ម៉ាឡៃ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១១ ក្នុងការរួមរស់នៅជាមួយគ្នា គូភាគីមានកូន មានទ្រព្យសម្បត្តិរួម និងមានបំណុលជំពាក់ធនាគារ គូភាគីបានស្ម័គ្រចិត្តលែងលះគ្នា ដោយសាររស់នៅមិនចុះសម្រុងនឹងគ្នា ភាគីដើមចោទក៏បានដាក់ពាក្យសុំលែងលះ បែងចែកទ្រព្យសម្បត្តិរួម បែងចែកបំណុល និងសុំគ្រប់គ្រងកូនទាំងពីរ ។ នៅក្នុងពេលផ្សះផ្សារនៃនីតិវិធីត្រៀមទាញហេតុផល គូភាគីបានធ្វើការព្រមព្រៀងគ្នាបែងចែកកូន ទ្រព្យសម្បត្តិរួម និងសល់ពីការព្រមព្រៀងគ្នា ភាគីដើមចោទសុំគ្រប់គ្រង រីឯភាគីចុងចម្លើយសុំគ្រប់គ្រងពាក់កណ្តាលម្នាក់ បំណុលសុំលក់ទ្រព្យសម្បត្តិសងទៅធនាគារ ។

**៣-ចំណុចវិវាទ:** ដើមចោទសុំគ្រប់គ្រងក្រុមហ៊ុនសាលាបើកបរដៃចំណាប់មានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មសាលាបង្រៀនបើកបរយានយន្តលេខៈ ៧១៩ ដជក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២ និងចុងចម្លើយសុំសិទ្ធិគ្រប់គ្រងក្រុមហ៊ុននេះពាក់កណ្តាល ។

**៤-ការអះអាងរបស់ភាគី :**

- ដើមចោទបានថ្លែងថា ខ្លួនរៀបអាពាហ៍ពិពាហ៍កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១០ និង បានចុះសំបុត្រអាពាហ៍ពិពាហ៍ កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១០ ដោយក្នុងចំណងអាពាហ៍ពិពាហ៍ ខ្លួនមានកូនចំនួនពីរនាក់ កូនទីមួយឈ្មោះ សាន់ ហេងច័ន្ទសេរីវត្ន ភេទស្រី កើតថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១ និង កូនទីពីរឈ្មោះ សាន់ អង្គារិទ្ធបញ្ញារើន ភេទប្រុស កើតថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៥ ដោយមិនទាមទារសោហ៊ុយសម្រាប់ចិញ្ចឹមកូនឡើយ និង មានទ្រព្យសម្បត្តិរួមៈ

១-ផ្ទះថ្មលេខ: R២២ មួយល្វែងពីរជាន់កន្លះមានទំហំទទឹង ៤.០១ម៉ែត្រ គុណនឹងបណ្តោយ១៦ម៉ែត្រ មានទីតាំងស្ថិតនៅផ្លូវលំ ភូមិ៩១ សង្កាត់ច្រាំងចំរេះ២ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ: ភព ៣៣៧៤៤ ចុះថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០១៦ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និង សុរិយោដីលោក សារិន វណ្ណា ។

២-ដីទំហំ ២៧៨៩ម៉ែត្រការ៉េ មានក្បាលដីលេខ:១០៣ មានទីតាំងស្ថិតនៅភូមិព្រៃមាន់ ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ:០៤០៦១១០៩-០១០៣ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី លោក លី សុភា ។

៣-ដីឡូត៍ទំហំទទឹង១៤.៥ម៉ែត្រ និងបណ្តោយ២០ម៉ែត្រ មានទីតាំងស្ថិតនៅភូមិទី៤ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។

៤-ដីទំហំ ១៨៤ម៉ែត្រការ៉េ មានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ:១៧៨/១៦ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ចេញដោយមេឃុំសំបូរមាស មានទីតាំងស្ថិតនៅភូមិអន្លង់ស្វែង ឃុំសំបូរមាស ស្រុកមុខកំពូល ខេត្តកណ្តាល ។

៥-ដីទំហំ ២(ពីរ)ហិចតា នៅខាងកើតវត្តព្រះឃ្លាំង មានទីតាំងស្ថិតនៅភូមិសិលា ឃុំស្វាយជ្រុំ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង (ឯកសារដីនៅចុងចម្លើយ) ។

៦-ក្រុមហ៊ុនសាលាបើកបរដៃចំណាប់ មានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម សាលាបង្រៀនបើកបរយានយន្តលេខ: ៧១៩ ជដក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២ ចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន ។

៧- រថយន្តកាម៉ារី ពណ៌ទឹកប្រាក់ សេរីឆ្នាំ២០០៧ ពាក់ស្លាកលេខ:ភ្នំពេញ 2BA ៨០៥២ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ ។

៨- រថយន្តម៉ាកហាយឡិនឌ័រ ពណ៌ទឹកប្រាក់ សេរីឆ្នាំ២០០៣ ពាក់ស្លាកលេខ: ភ្នំពេញ ២AO ៥៦៥៨ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ ។

៩-រថយន្តកាម៉ារី ចាឡែន ពណ៌ទឹកប្រាក់ សេរីឆ្នាំ២០០២ ពាក់ស្លាកលេខ ភ្នំពេញ ២AC ២៥០៦ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ។

១០-រថយន្តកាម៉ារីឆ្លាម ពណ៌ទឹកមាស សេរីឆ្នាំ១៩៩៧ ពាក់ស្លាកលេខ: ២I ០៨៣១ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ ។

១១- រថយន្តកាម៉ារី ពណ៌បៃតងចាស់ ពាក់ស្លាកលេខ: ភ្នំពេញ ២G ៣៦៥៧ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្ត ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០២ ។

១២- រថយន្តកាម៉ារី ស៊ិត ពណ៌ខ្មៅ ពាក់ស្លាកលេខ: ឆ០៣៥៩ ភព២ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តនៅចុងចម្លើយ ។

១៣- រថយន្តលុចស៊ុស ៣៣០ ពណ៌ទឹកមាស សេរីឆ្នាំ២០០៥ ពាក់ស្លាកលេខ:ភ្នំពេញ ២BL ២៦៨៣ ចំនួនមួយគ្រឿង មានប័ណ្ណសំគាល់យានយន្តនៅចុងចម្លើយ ។

និងមានបំណុលជំពាក់ធនាគារអេស៊ីលីដា ។

-ចុងចម្លើយបានថ្លែងថាខ្លួនក៏សុខចិត្តលែងប្រពន្ធផងដែរ តែចំពោះខ្លួនសុំគ្រប់គ្រងកូនប្រុសឈ្មោះ សាន់ អង្គារិទ្ធបញ្ញារើន ភេទប្រុស កើតថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៥ រីឯកូនស្រីឈ្មោះ សាន់ ហេងច័ន្ទសេរីវ័ត្ត កើតថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១ សុំប្រគល់ទៅឱ្យប្រពន្ធជាអ្នកមានអំណាចមេបា ដោយមិនទាមទារសោហ៊ុយសម្រាប់ចិញ្ចឹមកូនឡើយ។ ដោយឡែកទ្រព្យសម្បត្តិរួម ខ្លួនទទួលស្គាល់ថាមានចំនួនដូចខាងលើ ។

-ដើមចោទ និងចុងចម្លើយបានថ្លែងថា ខ្លួនទាំងពីរនាក់ ក៏បានព្រមព្រៀងគ្នាផងដែរ គឺរថយន្តដែលត្រូវឱ្យប្រពន្ធមាន:

-រថយន្តម៉ាកហាយឡិនឌ័រ ពណ៌ទឹកប្រាក់ សេរីឆ្នាំ២០០៣ ពាក់ស្លាកលេខ: ភ្នំពេញ ២AO ៥៦៥៨ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ ។

-រថយន្តកាម៉ារី បាឡែន ពណ៌ទឹកប្រាក់ សេរីឆ្នាំ២០០២ ពាក់ស្លាកលេខ: ភ្នំពេញ ២AC ២៥០៦ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ។

-រថយន្តកាម៉ារី ពណ៌បៃតងចាស់ពាក់ស្លាកលេខ: ភ្នំពេញ ២G ៣៦៥៧ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០២ ។

និងរថយន្តដែលត្រូវបានខ្លួនជាប្ដីមាន:

- រថយន្តកាម៉ារី ពណ៌ទឹកប្រាក់ សេរីឆ្នាំ២០០៧ ពាក់ស្លាកលេខ: ភ្នំពេញ 2BA ៨០៥២ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ ។

-រថយន្តកាម៉ារីឆ្មាម ពណ៌ទឹកមាស សេរីឆ្នាំ១៩៩៧ ពាក់ស្លាកលេខ: ២I ០៨៣១ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ ។

ទ្រព្យសម្បត្តិរួមសល់ពីររថយន្តបែងចែកគ្នាដូចខាងលើត្រូវលក់សងធនាគារ លើកលែងតែដីទំហំ២៧៨៩ម៉ែត្រការ៉េ មានក្បាលដីលេខ:១០៣ មានទីតាំងស្ថិតនៅភូមិព្រៃមាន់ ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ០៤០៦១១០៩-០១០៣ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និង សុរិយោដី លោក លី សុភា ទុកសម្រាប់កូនទាំងពីរនាក់មានកូនស្រីឈ្មោះ សាន់ ហេងច័ន្ទសេរីវត្ត និងកូនប្រុសឈ្មោះ សាន់ អង្គារិទ្ធបញ្ញារើន ភេទប្រុស កើតថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៥។ និងសូមបញ្ជាក់ថាដីទំហំ២(ពីរ)ហិចតា នៅខាងកើតវត្តព្រះឃ្លាំង មានទីតាំងស្ថិតនៅភូមិសិលា ឃុំស្វាយជ្រុំ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង និងរថយន្តកាម៉ារីស៊ុត ពណ៌ខ្មៅ ពាក់ស្លាកលេខ: ឆ០៣៥៩ ភ៧២ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តនៅចុងចម្លើយ និងរថយន្តលុចស៊ុស ៣៣០ ពណ៌ទឹកមាស សេរីឆ្នាំ២០០៥ ពាក់ស្លាកលេខ: ភ្នំពេញ ២BL ២៦៨៣ ចំនួនមួយគ្រឿង មានប័ណ្ណសំគាល់យានយន្តនៅចុងចម្លើយ ត្រូវបានខ្លួនជាចុងចម្លើយបានលក់ហើយ ហើយទ្រព្យដែលនៅសល់ពីការលក់នេះ ខ្លួនទាំងពីរនាក់ ព្រមព្រៀងគ្នាលក់សងបំណុលធនាគារអេស៊ីលីដា សល់ពីការសងធនាគារបែងចែកជាពីរចំណែកស្មើគ្នា ។

-ដើមចោទបានថ្លែងថា ខ្លួនសុំគ្រប់គ្រង ក្រុមហ៊ុនសាលាបើកបរដៃចំណាប់ មានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម សាលាបង្រៀនបើកបរយានយន្តលេខ:៧១៥ ដជត ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២ ចេញដោយក្រសួងសាធារណការ និង ដឹកជញ្ជូន ដោយសារក្រុមហ៊ុននេះ មានឈ្មោះខ្លួនជាម្ចាស់ក្រុមហ៊ុន ។

-ចុងចម្លើយបានថ្លែងថា ខ្លួនសុំសិទ្ធិក្រុមហ៊ុនពាក់កណ្ដាល ដល់កូនមានអាយុ១៨ឆ្នាំ សុំប្រគល់ទៅឱ្យកូនទាំងពីរនាក់ ដែលមានឈ្មោះ សាន់ ហេងច័ន្ទសេរីរ័ត្ន ភេទស្រី និងឈ្មោះ សាន់ អង្គារិទ្ធបញ្ញារើន ភេទប្រុស កើតថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៥ ដោយសារតែខ្លួនជាអ្នកបង្កើតទាំងអស់ មានតាំងពីការបង្កើតផ្លាក លោហ្គោ លើកយីហោ និង ចាត់ចែងការងារផ្ទៃក្នុង ។

## សំអាងហេតុ

តាមលទ្ធផលនៃការសាកសួរសាមីភាគី ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល , ការទាញហេតុផលដោយផ្ទាល់មាត់ និង ការពិនិត្យភស្តុតាងឃើញថា:

-តាមពាក្យបណ្ដឹងចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២ របស់ដើមចោទមានលក្ខណៈត្រឹមត្រូវ បញ្ជាក់ឱ្យឃើញថា សាលាដំបូងខេត្តកំពង់ឆ្នាំង មានសមត្ថកិច្ចដើម្បីវិនិច្ឆ័យស្របច្បាប់នូវពាក្យបណ្ដឹង ហើយចេញសាលក្រមបានតាមមាត្រា ៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

-តាមពាក្យបណ្ដឹងចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២ ក៏ដូចជាការថ្លែងរបស់ដើមចោទទាមទារ :

១-សុំលែងលះ ។

២-សុំសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិរួមទាំងអស់ ។

៣-សុំសិទ្ធិគ្រប់គ្រងកូនពីរនាក់ ។

៤-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ ។

-តាមសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍លេខ:៣៤៨ ច.ល ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ របស់មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋានស្រុករលាប្អៀរ បញ្ជាក់ឱ្យឃើញថា ដើមចោទ និង ចុងចម្លើយ ពិតជាប្ដីប្រពន្ធនឹងគ្នាមែន ។

-តាមអង្គហេតុដែលនាំឱ្យគូភាគីលែងលះគ្នាកើតចេញពីការរស់នៅមិនចុះសម្រុងនឹងគ្នា អស់មនោសញ្ចេតនានឹងគ្នា ចំណុចនេះជាមូលហេតុដែលធ្វើឱ្យគូភាគី មិនអាចយកគ្នាជាប្ដីប្រពន្ធបានតទៅទៀត ។

-ទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបានឡើយ ដូចនេះ ការព្រមព្រៀងលែងលះគ្នារបស់ប្ដីប្រពន្ធតុលាការអាចពិចារណាបាន តាមមាត្រា៩៧៩នៃក្រមរដ្ឋប្បវេណី ដោយហេតុថា គូភាគីមានបំណងពិតប្រាកដ ក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ ។

-ក្នុងចំណោមប្ដីប្រពន្ធគូភាគីមានកូនពីរនាក់ គឺកូនឈ្មោះ សាន់ ហេងច័ន្ទសេរីរ័ត្ន ភេទស្រី កើតថ្ងៃទី០៨ ខែមិថុនា ឆ្នាំ ២០១១ និងកូនឈ្មោះ សាន់ អង្គារិទ្ធបញ្ញារើន ភេទប្រុស កើតថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៥ នៅអនីតិជននៅឡើយ ដែលគូភាគីបានព្រមព្រៀងគ្នា កូនស្រីឈ្មោះ សាន់ ហេងច័ន្ទសេរីរ័ត្ន ត្រូវបានគ្រប់គ្រងដោយ ដើមចោទជាម្ដាយជាអ្នកមានអំណាចមេបា និងកូនប្រុសឈ្មោះ សាន់ អង្គារិទ្ធបញ្ញារើន ត្រូវបានគ្រប់គ្រងដោយចុងចម្លើយជាឪពុកជាអ្នកមានអំណាចមេបា ដោយមិនទាមទារសោហ៊ុយសម្រាប់ចិញ្ចឹមកូននោះទេ ដែលគប្បីតុលាការយកការយកការព្រមព្រៀងរបស់គូភាគីទុកជាបានការ ។

-បើទោះបីជាដើមចោទជាម្ដាយ និងចុងចម្លើយជាឪពុក ពុំមានអំណាចមេបាគ្រប់គ្រង ចិញ្ចឹមបីបាច់ថែរក្សាកូនណាមួយក៏ដោយ ក៏ដើមចោទជាម្ដាយ និង ចុងចម្លើយជាឪពុក នៅតែមានសិទ្ធិក្នុងការចូលជួបប្រាស្រ័យទាក់ទងសួរសុខទុក្ខកូនបានគ្រប់ពេលវេលា ហើយគូភាគី ត្រូវបង្ករលក្ខណៈងាយស្រួលដល់គ្នាទៅវិញទៅមកផងដែរ តាមមាត្រា១០៤០ និង មាត្រា១០៤១នៃក្រមរដ្ឋប្បវេណី ។

-ក្នុងចំណោមប្តីប្រពន្ធគូភាគីមានទ្រព្យសម្បត្តិរួមគឺ:

១-ផ្ទះថ្មលេខ: R២២ មួយល្វែងពីរជាន់កន្លះមានទំហំទទឹង ៤.០១ម៉ែត្រ គុណនឹងបណ្តោយ១៦ម៉ែត្រ មានទីតាំងស្ថិតនៅផ្លូវលំ ភូមិ៦១ សង្កាត់ច្រាំងចំរេះ២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ: ភព ៣៣៧៤៤ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និង សុរិយោដី លោក សារិន វណ្ណា ។

២-ដីទំហំ ២៧៨៩ម៉ែត្រការ៉េ មានក្បាលដីលេខ:១០៣ មានទីតាំងស្ថិតនៅភូមិព្រៃមាន់ ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ:០៤០៦១១០៩-០១០៣ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី លោក លី សុភា ។

៣-ដីឡូត៍ទំហំទទឹង១៤.៥ម៉ែត្រ និងបណ្តោយ២០ម៉ែត្រ មានទីតាំងស្ថិតនៅភូមិទី៤ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។

៤-ដីទំហំ ១៨៤ម៉ែត្រការ៉េ មានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ:១៧៨/១៦ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ចេញដោយមេឃុំសំបួរមាស មានទីតាំងស្ថិតនៅភូមិអន្លង់ស្វែង ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្តាល ។

៥-ដីទំហំ ២(ពីរ) ហិចតា នៅខាងកើតវត្តព្រះឃ្លាំង មានទីតាំងស្ថិតនៅភូមិសិលា ឃុំស្វាយជ្រុំ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង (ឯកសារដីនៅចុងចម្លើយ) ។

៦-ក្រុមហ៊ុនសាលាបើកបរដៃចំណាប់ មានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម សាលាបង្រៀនបើកបរយានយន្តលេខ: ៧១៩ ដជគ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២ ចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន ។

៧- រថយន្តកាម៉ារី ពណ៌ទឹកប្រាក់ ស៊េរីឆ្នាំ២០០៧ ពាក់ស្លាកលេខ:ភ្នំពេញ 2BA ៨០៥២ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ ។

៨- រថយន្តម៉ាកហាយឡិនឌ័រ ពណ៌ទឹកប្រាក់ ស៊េរីឆ្នាំ២០០៣ ពាក់ស្លាកលេខ: ភ្នំពេញ ២ AO ៥៦៥៨ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ ។

៩-រថយន្តកាម៉ារី ចាឡែន ពណ៌ទឹកប្រាក់ ស៊េរីឆ្នាំ២០០២ ពាក់ស្លាកលេខ ភ្នំពេញ ២ AC ២៥០៦ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ។

១០-រថយន្តកាម៉ារីឆ្មាម ពណ៌ទឹកមាស ស៊េរីឆ្នាំ១៩៩៧ ពាក់ស្លាកលេខ: ២I ០៨៣១ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ ។

១១- រថយន្តកាម៉ារី ពណ៌បៃតងចាស់ ពាក់ស្លាកលេខ: ភ្នំពេញ ២G ៣៦៥៧ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្ត ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០២ ។

១២- រថយន្តកាម៉ារីស្វិត ពណ៌ខ្មៅ ពាក់ស្លាកលេខ: ឆ០៣៥៩ ភព២ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តនៅចុងចម្លើយ ។

១៣- រថយន្តលុចស៊ីស ៣៣០ ពណ៌ទឹកមាស ស៊េរីឆ្នាំ២០០៥ ពាក់ស្លាកលេខ: ភ្នំពេញ ២BL ២៦៨៣ ចំនួនមួយគ្រឿង មានប័ណ្ណសំគាល់យានយន្តនៅចុងចម្លើយ ។

**គូភាគីបានព្រមព្រៀងចែកគ្នារួមមាន:**

**ក-ភាគីដើមចោទត្រូវបានមាន:**

១-រថយន្តម៉ាកហាយឡិនឌ័រ ពណ៌ទឹកប្រាក់ ស៊េរីឆ្នាំ២០០៣ ពាក់ស្លាកលេខៈភ្នំពេញ ២ AO ៥៦៥៨ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ ។

២-រថយន្តកាម៉ារី បាឡែន ពណ៌ទឹកប្រាក់ ស៊េរីឆ្នាំ២០០២ ពាក់ស្លាកលេខៈ ភ្នំពេញ ២ AC ២៥០៦ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ។

៣-រថយន្តកាម៉ារី ពណ៌បៃតងចាស់ពាក់ស្លាកលេខៈភ្នំពេញ២G ៣៦៥៧ ចំនួន១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០២ ។

**ខ-ភាគីចុងចម្លើយត្រូវបានមានៈ**

១- រថយន្តកាម៉ារី ពណ៌ទឹកប្រាក់ ស៊េរីឆ្នាំ២០០៧ ពាក់ស្លាកលេខៈ ភ្នំពេញ 2BA ៨០៥២ ចំនួន១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ ។

២-រថយន្តកាម៉ារីឆ្លាម ពណ៌ទឹកមាស ស៊េរីឆ្នាំ១៩៩៧ ពាក់ស្លាកលេខៈ ២I០៨៣១ ចំនួន១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ ។

**គ-ទ្រព្យសម្បត្តិព្រមព្រៀងលក់យកប្រាក់ សងធនាគារ និងសល់ពីសងធនាគារចែកគ្នាពាក់កណ្ដាលម្នាក់មានៈ**

១-ផ្ទះថ្មលេខៈR២២ មួយល្វែងពីរជាន់កន្លះមានទំហំទទឹង ៤.០១ម៉ែត្រ គុណនឹងបណ្ដោយ១៦ម៉ែត្រ មានទីតាំងស្ថិត នៅផ្លូវលំភូមិខ១ សង្កាត់ច្រាំងចំរេះ២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខៈ ភព ៣៣៧៤៤ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និង សុរិយោដី លោក សារិន វណ្ណា ។

២-ដីឡូត៍ទំហំទទឹង ១៤.៥ម៉ែត្រ និងបណ្ដោយ២០ម៉ែត្រ មានទីតាំងស្ថិតនៅភូមិ៤ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។

៣-ដីទំហំ១៨៤ម៉ែត្រការ៉េ មានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខៈ ១៧៨/១៦ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ចេញដោយមេឃុំសំបួរមាស មានទីតាំងស្ថិតនៅភូមិអន្លង់ស្លែង ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្ដាល ។

**ឃ-ទ្រព្យសម្បត្តិប្រគល់ឱ្យកូនទាំងពីរមានៈ**

១-ដីទំហំ២៧៨៩ម៉ែត្រការ៉េ មានក្បាលដីលេខៈ១០៣ មានទីតាំងស្ថិតនៅភូមិព្រៃមាន់ ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។

ដែលតុលាការយកការព្រមព្រៀងគ្នានេះទុកជាបានការ ។

-ដោយឡែកទ្រព្យសម្បត្តិ ដែលគូភាគីមិនបានព្រមព្រៀងគ្នាមានៈ ក្រុមហ៊ុនសាលាបើកបរដៃចំណាប់ មានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម សាលាបង្រៀនបើកបរយានយន្តលេខៈ ៧១៩៥៨ជត ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២ ចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន និងត្រូវបានព្យួរលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មរយៈពេល៦ខែ កាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៣ គូភាគីមិនមានការព្រមព្រៀងគ្នាឡើយ តែមានឈ្មោះដើមចោទជាម្ចាស់អាជីវកម្ម បង្ហាញឱ្យឃើញថានេះជាទ្រព្យសម្បត្តិដោយឡែករបស់ដើមចោទ ហេតុនេះតុលាការធ្វើការសម្រេច ដោយផ្អែកលើមាត្រា ៩៨០នៃក្រមរដ្ឋប្បវេណី ។

-តាមការអះអាងរបស់គូភាគីបានបង្ហាញថា ដើមចោទ និង ចុងចម្លើយមានជំពាក់បំណុលធនាគារអេស៊ីលីដា មិនទាន់បានសងរួចនៅឡើយ តែគូភាគីបានព្រមព្រៀងគ្នារួមគ្នាចេញសងទៅធនាគារ ហេតុនេះតុលាការគប្បីយកការព្រមព្រៀងគ្នាទុកជាបានការ ។

-អនុវត្តតាមមាត្រា៦៤នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្តី គប្បីជាបន្ទុករបស់ចុងចម្លើយ ។

<u>**សេចក្តីសម្រេចបញ្ចប់**</u>

១-ឱ្យដើមចោទឈ្មោះ **នួន សុភារី** និង ចុងចម្លើយឈ្មោះ **សាន់ ម៉ារ៉ៃឡូ** លែងលះគ្នាតាមការព្រមព្រៀង តាមមាត្រា៩៧៩ នៃក្រមរដ្ឋប្បវេណី ។

២-ប្រគល់កូនឈ្មោះ **សាន់ រេហ្វចន្ទសេរីវត្ត** ភេទស្រី កើតថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១ ឱ្យទៅដើមចោទឈ្មោះ **នួន សុភារី** ជាម្តាយមានអំណាចមេបាគ្រប់គ្រង ចិញ្ចឹមបីបាច់ថែរក្សា រហូតដល់កូនមាននីតិភាព តាមការព្រមព្រៀងគ្នា តាមមាត្រា ១០៣៧នៃក្រមរដ្ឋប្បវេណី។

៣-ប្រគល់កូនឈ្មោះ **សាន់ អង្គារិទ្ធបញ្ញារ៉េន** ភេទប្រុស កើតថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៥ ឱ្យទៅចុងចម្លើយឈ្មោះ **សាន់ ម៉ារ៉ៃឡូ** ជាឪពុកមានអំណាចមេបាគ្រប់គ្រង ចិញ្ចឹមបីបាច់ថែរក្សា រហូតដល់កូនមាននីតិភាព តាមការព្រមព្រៀងគ្នា តាមមាត្រា ១០៣៧នៃក្រមរដ្ឋប្បវេណី។

៤-ដើមចោទឈ្មោះ **នួន សុភារី** ជាម្តាយ និងចុងចម្លើយឈ្មោះ **សាន់ ម៉ារ៉ៃឡូ** ជាឪពុក ដែលពុំមានអំណាចមេបាលើកូន ក្រោយពេលលែងលះគ្នា មានសិទ្ធិចូលជួបប្រាស្រ័យទាក់ទងជាមួយកូន តាមការនឹករលឹកគ្រប់ពេលវេលា។ ភាគីដើមចោទជាម្តាយ និង ភាគីចុងចម្លើយជាឪពុក ត្រូវបង្កលក្ខណៈងាយស្រួលដល់គ្នាទៅវិញទៅមកផងដែរ តាមមាត្រា ១០៤០នៃក្រមរដ្ឋប្បវេណី ។

**៥-ប្រគល់ទ្រព្យសម្បត្តិរួមមាន:**

-រថយន្តម៉ាកហាយឡិនឌ័រ ពណ៌ទឹកប្រាក់ ស៊េរីឆ្នាំ២០០៣ ពាក់ស្លាកលេខ: ភ្នំពេញ ២AO ៥៦៥៨ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ ។

-រថយន្តកាម៉ារី បាំឡែន ពណ៌ទឹកប្រាក់ ស៊េរីឆ្នាំ២០០២ ពាក់ស្លាកលេខ ភ្នំពេញ ២AC ២៥០៦ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ។

-រថយន្តកាម៉ារី ពណ៌បៃតងចាស់ពាក់ស្លាកលេខ: ភ្នំពេញ ២G ៣៦៥៧ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០២ ។

ទៅឱ្យដើមចោទឈ្មោះ **នួន សុភារី** គ្រប់គ្រង តាមការព្រមព្រៀងរបស់គូភាគី តាមមាត្រា៩៨០នៃក្រមរដ្ឋប្បវេណី ។

**៦-ប្រគល់ទ្រព្យសម្បត្តិរួមមាន:**

- រថយន្តកាម៉ារី ពណ៌ទឹកប្រាក់ ស៊េរីឆ្នាំ២០០៧ ពាក់ស្លាកលេខ: ភ្នំពេញ 2BA ៨០៥២ ចំនួន១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ ។

-រថយន្តកាម៉ារីឆ្លាម ពណ៌ទឹកមាស ស៊េរីឆ្នាំ១៩៩៧ ពាក់ស្លាកលេខ: ២I០៨៣១ ចំនួន១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ ។

ទៅឱ្យចុងចម្លើយឈ្មោះ **សាន់ ម៉ារ៉ៃឡូ** គ្រប់គ្រង តាមការព្រមព្រៀងរបស់គូភាគី តាមមាត្រា៩៨០នៃក្រមរដ្ឋប្បវេណី ។

**៧-ប្រគល់ទ្រព្យសម្បត្តិរួមមាន:**ដីទំហំ២៧៨៩ម៉ែត្រការ៉េ មានក្បាលដីលេខ:១០៣ មានទីតាំងស្ថិតនៅភូមិព្រៃមាន់ ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ឱ្យទៅកូនឈ្មោះ **សាន់ រេហ្វចន្ទសេរីវត្ត** ភេទស្រី កើតថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១ និងកូនឈ្មោះ **សាន់ អង្គារិទ្ធបញ្ញារ៉េន** ភេទប្រុស កើតថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៥ ជាអ្នកគ្រប់គ្រង នៅ

ពេលកុមារទាំងពីរមានអាយុនីតិភាព ដោយមានដើមចោទឈ្មោះ ឱ្ ខូច សុភារី និងចុងចម្លើយឈ្មោះ សាន់ ម៉ារៃឡា ជាអ្នកមើលថែទាំក្នុងកំឡុងពេលកុមារទាំងពីរនៅអនីតិជននៅឡើយ ។

**៨-ប្រគល់ទ្រព្យសម្បត្តិមាន:** ក្រុមហ៊ុនសាលាបើកបរដៃចំណាប់មានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មសាលាបង្រៀនបើកបរយានយន្តលេខ: ៧១៩ ជជត ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២ ទៅឱ្យដើមចោទឈ្មោះ **ខូច សុភារី** ចាប់ពីពេលនេះតទៅ ។

**៩-ទ្រព្យសម្បត្តិរួមត្រូវលក់សងទៅធនាគារអេស៊ីលីដារួមមាន:**

-ផ្ទះថ្មលេខ:R២២ មួយល្វែងពីរជាន់កន្លះមានទំហំទទឹង ៤.០១ម៉ែត្រ គុណនឹងបណ្តោយ១៦ម៉ែត្រ មានទីតាំងស្ថិតនៅផ្ទះវល់ភូមិ៦១ សង្កាត់ច្រាំងចំរេះ២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ: ភព ៣៣៧៤៤ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និង សុរិយោដី លោក សារិន វណ្ណា ។

-ដីឡូត៍ទំហំទទឹង ១៤.៥ម៉ែត្រ និងបណ្តោយ២០ម៉ែត្រ មានទីតាំងស្ថិតនៅភូមិ៤ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។

-ដីទំហំ១៨៤ម៉ែត្រការ៉េ មានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ: ១៧៨/១៦ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០១៦ ចេញដោយមេឃុំសំបួរមាស មានទីតាំងស្ថិតនៅភូមិអន្លង់ស្វែង ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្តាល ។

តាមការព្រមព្រៀងរបស់គូភាគី តាមមាត្រា ៩៨០នៃក្រមរដ្ឋប្បវេណី ។

១០-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

សាលក្រមនេះ ប្រកាសជាសាធារណៈនៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ។

ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។៩

ចៅក្រម

ហត្ថលេខា និង ត្រា: **គីម វ័ត្ថណារិន**

---

បានឃើញ

ចៅក្រម

គីម វ័ត្ថណារិន

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ១២រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

កំពង់ឆ្នាំង ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣

ក្រឡាបញ្ជី

ឡុប សាមីនី